ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រវត្តិសាស្ត្រកម្ពុជា

## ពីបុព្វសម័យដល់សតវត្សទី៨



ព្រះនរាយណ៍ ស.វ ទី ៧ នៅអង្គរបុរី ខេត្ត តាកែវ

ដោយបណ្ឌិត ម. ត្រាណោ

១៩៩៦

៥១១.
៣

LIBRARY

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

ព្រះរាជឧបត្ថម្ភដោយសម្ដេចក្រុមព្រះ នរោត្តមរណឫទ្ធិ
នាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

៥១១.៣

ព្រះរាជាណាចក្រកម្ពុជា . ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រវត្តិសាស្ត្រកម្ពុជា

## ពីបុព្វសម័យដល់សតវត្សទី៤

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
២៥០៧|៩៧

ដោយបណ្ឌិត ម. ត្រាណេ

១៩៩៦

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

« ជាច្រើនសតវត្សមកហើយ បុព្វបុរសដែលជាសាច់ឈាម ផ្ទាល់របស់សម្តេច *នរោត្តម សីហនុ* ព្រះមហាក្សត្រនៃកម្ពុជា ធ្លាប់ជាម្ចាស់ទឹកដីនៃភូមិភាគឥណ្ឌូចិនកណ្តាលទាំងមូល ហើយក៏ធ្លាប់គ្រប់គ្រង លើមហាប្រទេសមួយ ពោរពេញទៅដោយភាព ត្រចះត្រចង់ និង ប្រកបដោយអធិបតេយ្យភាព ក្នុងពេលដែលអ្នកជិតខាងរបស់ខ្លួន ( ជនជាតិ ថៃ លាវ និង យួន ) កំពុងថ្ងូរថ្ងួរយ៉ាងឈឺចាប់ ក្រោមនឹមជិះជាន់ របស់ចៅហ្វាយចិននៅឡើយ ។

អ្នកដែលទទួលមរតកវប្បធម៌ នៃអតីតកាលដ៏មហារុងរឿង ថ្កុំថ្កើងនេះ ត្រូវមានភារកិច្ច និង កាតព្វកិច្ច ចំពោះបុព្វបុរសរបស់ខ្លួន ក្នុងការផ្សព្វផ្សាយអោយមានឈ្មោះ បោះសំលេង ល្បីរន្ទឺខ្ចរខ្ចារ ដើម្បីរំលឹកឡើងវិញអំពីតួនាទីជាប្រវត្តិសាស្ត្រ ដែលប្រទេសរបស់ខ្លួន ធ្លាប់មាននៅលើភូមិភាគឥណ្ឌូចិនដែល នឹង មានតទៅទៀត » ។

*( ហ្សាក ស៊ីដែស សម្លេងនៃកម្ពុជា ព្រឹត្តប័ត្រ ហ្វ្រង់ - អាស៊ី លេខ : ៤៥ ខែ តុលា ១៩៤៩ )*

www.budinst.gov.kh www.elibraryofcambodia.org

« យើងអាចចាត់ទុកវត្ថុបុរាណ ជាប្រពៃណី ជាបេតិកភ័ណ្ឌ ជាប្រវត្តិសាស្ត្រជាតិ . . . . . យើងត្រូវមានករណីកិច្ច កាតព្វកិច្ច មិនត្រឹមតែស្ដារឡើងវិញ នូវប្រាង្គប្រាសាទរបស់យើងទេ ក៏ប៉ុន្តែមានកាតព្វកិច្ចដ៏ធំធេង ថែរក្សាឡើងវិញ ថែរក្សាឱ្យបានគង់វង្ស តកូន តចៅ ចាប់ពីពេលនេះរហូតតរៀងទៅ ជាអមតៈ ។ ព្រោះប្រទេសខ្មែរ ត្រូវតែមានវត្តមាន លើពិភពលោកនេះ ជាអមតៈ ។ ដូចឯកឧត្តមជ្រាបស្រាប់ហើយ ប្រជារាស្ត្រ ប្រជាពលរដ្ឋ ដែលមានស្នាដៃដ៏ធំធេង ស្ថាបនាបានឡើង នូវប្រាង្គប្រាសាទ ដូចជាក្រុមប្រាសាទអង្គរ ប្រាសាទអង្គរវត្ត ជាដើម ។ល។ នេះជាប្រជាពលរដ្ឋមួយ មិនមែនត្រឹមតែមានស្នាដៃតែប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវមានកម្រិតចេះដឹងគ្រប់បែបយ៉ាងទាំងអស់ដ៏ខ្ពង់ខ្ពស់បំផុត ។

យើងទាំងអស់គ្នាមុខជាមានលទ្ធភាពនឹងថែរក្សា ប្រទេសកម្ពុជាយើង ឱ្យបានគង់វង្ស ស្ថិតស្ថេរ ហើយល្អលាស់ រុងរឿង ថ្កុំថ្កើងដូចសម័យមហានគរ ដ៏រុងរឿងអញ្ចឹងដែរ ។

នេះមិនមែនជាការសង្ឃឹមទេ តែជាជំនឿរបស់ខ្ញុំ ដែលជាកូនខ្មែរមួយរូបដែលត្រូវតែមានជានិច្ចកាល » ។

*( ព្រះរាជបន្ទូលរបស់សម្ដេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១២-១១-១៩៩៦ ក្នុងពិធីប្រគល់វត្ថុបុរាណជូនសារមន្ទីរជាតិនៅភ្នំពេញ )*

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# មាតិការឿង

## ភាគទី ១

ទំព័រ

### សម័យបុរេប្រវត្តិសាស្ត្រ

លំនាំដើម .............................. ១
- បញ្ហាដែលចោទអំពីកំណើត របស់ជនជាតិខ្មែរ .................. ៥
- វប្បធម៌ខ្មែរនាបុព្វសម័យ .............................. ១០
- បុរេប្រវត្តិសាស្ត្រខ្មែរ .............................. ១៧

## ភាគទី ២

### សម័យប្រវត្តិសាស្ត្រខ្មែរ

- លំនាំដើម .............................. ៣០
- សម័យចេនឡា .............................. ៥៥
- ការបែកបាក់នៃនគរភ្នំគ្រាដំបូងបង្អស់នៃប្រទេសកម្ពុជា ឬ ចេនឡា

www.budinst.gov.kh www.elibraryofcambodia.org

( ៩៩០ - ៦៣០ ) .......................... ៥៧
- ការបែងចែកនៃប្រទេសកម្ពុជា ជាពីរ នៅដើមសតវត្សទី ៨ ចេនឡាគោក
និង ចេនឡាទឹក .......................... ៦៥
- វប្បធម៌ - អារ្យធម៌ នៃនគរភ្នំ និង ចេនឡា .......................... ៦៧
- របៀបគ្រប់គ្រង រៀបចំស្រុកទេសសម័យចេនឡា .......................... ៧១
- បំនៀមទម្លាប់ប្រពៃណី .......................... ៧៥
- វិស័យអក្សរសិល្ប៍ .......................... ៨៣
- សង្គមខ្មែរ .......................... ៨៨
- នយោបាយទឹក .......................... ៩០
- វិស័យសេដ្ឋកិច្ច .......................... ៩១

## ឯកសារស្តីអំពី សន្តិចបន្សនគរភ្នំ និង ចេនឡា
## របស់ ក្លូក ម៉ាក្ស៊ូល

- សេចក្តីបំភ្លឺ .......................... ៩៧
- កម្ពុជា ការបេប្រវត្តិវិទ្យានៃព្រះរាជាណាចក្រខ្មែរ រហូតមកដល់ពាក់កណ្តាល
សតវត្សទី ១៥ .......................... ១០១
- សក្តិវង្ស និង ព្រះរាជាណាចក្រខ្មែរ .......................... ១០៥
- ឯកសារយោង .......................... ១៣៥

www.budinst.gov.kh www.elibraryofcambodia.org

# មាតិការូបភាព

*****


ផ្ទាំងទី១ - ពូថៅយុគ្គវប្បធម៌ថ្មគ្រួសបំបែក (ដើមសម័យ)

ផ្ទាំងទី២ - យុគ្គវប្បធម៌សម័យថ្មគ្រួសបំបែក (កណ្ដាលសម័យ)

ផ្ទាំងទី៣ - យុគ្គវប្បធម៌សម័យថ្មបុរមបុរាណ (ចុងសម័យ)

ផ្ទាំងទី៤ - យុគ្គវប្បធម៌ថ្មបំបែកក្លាយ

ផ្ទាំងទី៥ - យុគ្គវប្បធម៌ថ្មរំលីង (នវៈសិលា)

ផ្ទាំងទី៦ - ភាជន៍សម័យនវៈសិលា

ផ្ទាំងទី៧-៩ - ភាជន៍សម័យលោហធាតុ

ផ្ទាំងទី១០ - ភាជន៍មានលាបល័ក្ខក្រហម

ផ្ទាំងទី១១ - ភាជន៍មានក្បាច់ជាគូសខ្សែពណ៌ក្រហម

ផ្ទាំងទី១២ - បំណែកភាជន៍លាបពណ៌ក្រហម

ផ្ទាំងទី១៣ - ប្រដាប់សំរាប់ធ្វើឆ្នាំង. ដីដុត ម្លូព្រៃ (កំពង់ធំ)

ផ្ទាំងទី១៤-១៥ - ការនិយមកងដៃ និងក្រវិលត្រចៀក

ផ្ទាំងទី១៦ - កងដៃសំរិទ្ធពំទ្ធថ្នាវែង

ផ្ទាំងទី១៧ - កងដៃសំរិទ្ធមានបន្តោង

ផ្ទាំងទី១៨ - កងដៃសំរិទ្ធពំឡូតលើគ្នា

ផ្ទាំងទី១៩ - កងដៃសំរិទ្ធ

ផ្ទាំងទី២០ - កងដៃសំរិទ្ធ និងបន្តោងសំរិទ្ធ

ផ្ទាំងទី២១ - បំណែកភាជន៍សំរិទ្ធ

ផ្ទាំងទី២២ - ដីងសំរិទ្ធ និងពុម្ពដីដុត

ផ្ទាំងទី២៣ - ដីង. កាំបិទស្នៀតសំរិទ្ធ


www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំងទី២៤ - ថូដាក់ទឹក និងប្រឡេយដាក់លោហធាតុ
ផ្ទាំងទី២៥ - ឧបករណ៍ដែក
ផ្ទាំងទី២៦-២៧ - គ្រឿងអលង្ការខ្យង
ផ្ទាំងទី២៨ - អង្កាំកែវសម្រាប់បន្តោងខ្សែក
ផ្ទាំងទី២៩ - គ្រឿងអលង្ការថ្ម
ផ្ទាំងទី៣០ - ក្រសាល់ត្រចៀក
ផ្ទាំងទី៣១ - វត្តមានរបស់ការប្រើសំលៀកបំពាក់
ផ្ទាំងទី៣២ - ការរំរែអំពោះ
ផ្ទាំងទី៣៣ - ពុម្ពសម្រាប់ប្រដាប់ក្បាច់
ផ្ទាំងទី៣៤ - ឧបករណ៍នេសាទ
ផ្ទាំងទី៣៥ - ខ្សែរដក់ថ្នាំ
ផ្ទាំងទី៣៦ - ស្នាមកញ្ចើនៅលើភាជន៍
ផ្ទាំងទី៣៧ - ការប្រើប្រាស់ស្នូរមហោធីកសិរិទ្ធ និងទូក
ផ្ទាំងទី៣៨-៣៩ - ឧបករណ៍ភ្លេង
ផ្ទាំងទី៤០-៤១ - ការផ្សាំងសត្វ
ផ្ទាំងទី៤២ - គំនូរពណ៌លើជញ្ជាំងភ្នំ
ផ្ទាំងទី៤៣ - ក្ការម្ជុស
ផ្ទាំងទី៤៤ - លិង្គ
ផ្ទាំងទី៤៥ - ការបូជាបុព្វបុរស
ផ្ទាំងទី៤៦ - មែនហៀរ
ផ្ទាំងទី៤៧ - ផុលម៉ែន
ផ្ទាំងទី៤៨ - ទូលថ្ម
ផ្ទាំងទី៤៩-៥០ - ផ្ទះបុរេប្រវត្តិ
www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំងទី៥១ - លំនៅស្ថានជាល្អាងភ្នំ
ផ្ទាំងទី៥២-៦៣ - ផ្ទាំងផែនទី និងប្លង់
ផ្ទាំងទី៦៤ - ព្រែកបុរាណ
ផ្ទាំងទី៦៥ - ទន្លេមេគង្គ និងទន្លេសែន
ផ្ទាំងទី៦៦ - ប្រាសាទថ្មរចនាបទភ្នំដា និងសំបូរណ៍ព្រៃគុក
ផ្ទាំងទី៦៧ - រចនាបទសម្បូរណ៍ព្រៃគុក
ផ្ទាំងទី៦៨ - ប្រាសាទសម្បូរណ៍ព្រៃគុក . ផង្គ និងក្បាច់ក្បូរ
ផ្ទាំងទី៦៩ - ប្រាសាទក្នុងរោងភ្នំ
ផ្ទាំងទី៧០ - រូបភាពស្ត្រី អប្សរ
ផ្ទាំងទី៧១ - បូជនីយដ្ឋានជីកក្នុងរោងភ្នំ នៅកំពត
ផ្ទាំងទី៧២ - ចេតិយស្តូបរចនាបទចេនឡា
ផ្ទាំងទី៧៣ - ស្រះបុរាណ
ផ្ទាំងទី៧៤ - រចនាបទភ្នំដា និងថាឡាបរិវ៉ត
ផ្ទាំងទី៧៥ - រចនាបទថាឡាបរិវ៉ត
ផ្ទាំងទី៧៦ - រចនាបទសម្បូរណ៍ព្រៃគុក
ផ្ទាំងទី៧៧-៧៨ - រចនាបទព្រៃក្មេង
ផ្ទាំងទី៧៩ - ផ្តែររចនាបទកំពង់ព្រះ
ផ្ទាំងទី៨០-៨២ - ក្បាច់ក្បូរតុបតែងប្រាសាទ
ផ្ទាំងទី៨៣ - រូបភាពជនជាតិខ្មែរនាសម័យនគរភ្នំ - ចេនឡា
ផ្ទាំងទី៨៤ - ក្បាច់ក្បូរតុបតែងប្រាសាទ-រចនាបទព្រៃក្មេង
ផ្ទាំងទី៨៥ - ក្បាច់ក្បូរតុបតែងប្រាសាទ
ផ្ទាំងទី៨៦ - ក្បាច់ក្បូរតុបតែង
ផ្ទាំងទី៨៧ - ក្បាច់រចនាបទសម្បូរណ៍ព្រៃគុក

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំងទី៨៨ - ក្បាច់ក្បូ តុបតែងប្រាសាទ
ផ្ទាំងទី៨៩ - កូនអណ្ដូង-រចនាបទសម្បូរណ៍ព្រៃគុក
ផ្ទាំងទី៩០ - ផែនទីនៃរាជធានី អង្គរបុរី
ផ្ទាំងទី៩១ - កំផែងទីក្រុង
ផ្ទាំងទី៩២ - ភាជន៍ដីដុត
ផ្ទាំងទី៩៣ - ភាជន៍ដីដុត. ឥតពណ៌ និងមានពណ៌
ផ្ទាំងទី៩៤ - ភាជន៍ដីដុតពណ៌ខ្មៅ
ផ្ទាំងទី៩៥ - ភាជន៍ដីដុតមានជើង និងឥតជើង
ផ្ទាំងទី៩៦ - ចង្កៀងប្រេង. ដីដុតវប្បធម៌នគរភ្នំ
ផ្ទាំងទី៩៧ - គ្រឿងអលង្ការថ្ម សម័យនគរភ្នំ
ផ្ទាំងទី៩៨ - អង្កាំ. ក្រវិលត្រចៀកការ
ផ្ទាំងទី៩៩ - កងដៃសំរិទ្ធ និងចង្កៀងសំរិទ្ធ
ផ្ទាំងទី១០០ - ឧបករណ៍ប្រើប្រាស់
ផ្ទាំងទី១០១ - ឥដ្ឋ និងគ្រឿងបុរាណ
ផ្ទាំងទី១០២ - កាក់បុរាណបរទេស : រ៉ូម៉ាំង
ផ្ទាំងទី១០៣-១០៤ - កាក់បុរាណខ្មែរសម័យនគរភ្នំ
ផ្ទាំងទី១០៥-១០៦ - គ្រឿងអលង្ការធ្វើអំពីកែវ
ផ្ទាំងទី១០៧ - ក្រវិលត្រចៀក. បន្តោងខ្សែក និងចិញ្ចៀន
ផ្ទាំងទី១០៨ - វត្ថុមានរបស់សំលៀកបំពាក់
ផ្ទាំងទី១០៩ - វត្ថុមាននៃជំនឿលើបុព្វបុរស
ផ្ទាំងទី១១០ - វត្ថុមាននៃការគោរពអ្នកតាចាស់ស្រុក
ផ្ទាំងទ១១១ - ចម្លាក់សំរិទ្ធរបស់អច្ឆរិយៈបុគ្គល
ផ្ទាំងទី១១២ - ព្រះព្រហ្ម

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំងទី១១៣_១១៥ - ព្រះវិស្ណុ
ផ្ទាំងទី១១៦ - ទេវរូប
ផ្ទាំងទី១១៧ - ព្រះហរិហរៈ
ផ្ទាំងទី១១៨_១១៩ - ព្រះក្រិស្ណ
ផ្ទាំងទី១២០ - ព្រះពលរាម
ផ្ទាំងទី១២១ - ព្រះអរធានារិស្វារៈថ្ម
ផ្ទាំងទី១២២ - ព្រះស្កន្ទ
ផ្ទាំងទី១២៣ - ព្រះសូរិយា
ផ្ទាំងទី១២៤ - ព្រះនាងឧមាឬទុគ៌ា
ផ្ទាំងទី១២៥ - ព្រះគណេស
ផ្ទាំងទី១២៦ - ព្រះគោនន្ទិន
ផ្ទាំងទី១២៧ - សិង្ហតោ
ផ្ទាំងទី១១២៨ - ព្រះកល្កិន
ផ្ទាំងទី១២៩ - ព្រះសិវលិង្គលក្ខណៈធម្មជាតិ
ផ្ទាំងទី១៣០ - ព្រះសិវលិង្គ
ផ្ទាំងទី១៣១ - លិង្គ. លិង្គនិងស្នាទ្រោនី
ផ្ទាំងទី១៣២ - ត្រីសូល៍. ខ្យងស័ង្ខ. កងចក្រ
ផ្ទាំងទី១៣៣ - ព្រះស្នាទ្រោនី
ផ្ទាំងទី១៣៤ - ឯកសារចិន
ផ្ទាំងទី១៣៥ - ព្រះពុទ្ធអង្គសិរីទ្ធទ្រង់ឈរ
ផ្ទាំងទី១៣៦ - ព្រះកេសព្រះពុទ្ធអង្គទ្រង់
ផ្ទាំងទី១៣៧ - ព្រះពុទ្ធអង្គទ្រង់អង្គុយ
ផ្ទាំងទី១៣៨- ព្រះពុទ្ធអង្គថ្មទ្រង់ឈរ

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំងទី១៣៩ - ព្រះពុទ្ធអង្គទ្រង់បង្រៀន
ផ្ទាំងទី១៤០ - ព្រះពុទ្ធអង្គទ្រង់ឈរ សំរិទ្ធ និងថ្ម
ផ្ទាំងទី១៤១ - ព្រះពុទ្ធអង្គទ្រង់អង្គុយ. ថ្ម
ផ្ទាំងទី១៤២ - ព្រះពុទ្ធបាទ
ផ្ទាំងទី១៤៣ - ព្រះចេតិយថ្ម. ព្រះពុទ្ធអង្គសំរិទ្ធ និងព្រះបដិមាពុទ្ធ
ផ្ទាំងទី១៤៤ - ស្តូបតូចសំរាប់អបកិច្ច
ផ្ទាំងទី១៤៥ - កងចក្រខ្មែរ និង មន
ផ្ទាំងទី១៤៦ - ផ្កាឈូក
ផ្ទាំងទី១៤៧ - ព្រះពុទ្ធអង្គចូលព្រះនិព្វាន. ថ្ម
ផ្ទាំងទី១៤៨ - ព្រះសិមាថ្ម
ផ្ទាំងទី១៤៩-១៥០ - ព្រះសិមា
ផ្ទាំងទី១៥១ - ព្រះអវលោកតេស្វរៈ សំរិទ្ធ
ផ្ទាំងទី១៥២ - ព្រះអវលោកតេស្វរៈ និងប្រាជ្ញាបារមិត
ផ្ទាំងទី១៥៣ - ព្រះអវលោកតេស្វរៈ សំរិទ្ធ និងថ្ម
ផ្ទាំងទី១៥៤ - ព្រះអវលោកតេស្វរៈ សំរិទ្ធ
ផ្ទាំងទី១៥៥ - សិលាចារិកសម័យនគរភ្នំ និងចេនឡា
ផ្ទាំងទី១៥៦ - សិលាចារិក វត្តភូ
ផ្ទាំងទី១៥៧ - សិលាចារិកសម័យមុនអង្គរ
ផ្ទាំងទី១៥៨-១៥៩ - ផ្ទាំងផែនទី
ផ្ទាំងទី១៦០ - ជនជាតិថៃ - វៀតណាម អម្បូរចិន
ផ្ទាំងទី១៦១ - ផែនទី
ផ្ទាំងទី១៦២ - ជនជាតិខ្មែរនៅស្រុកសៀម និងយួនខាងត្បូងបច្ចុប្បន្ន
ផ្ទាំងទី១៦៣-១៦៤ - ជនជាតិខ្មែរលើ

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

ភាគទី ១

# សម័យ

# បុរេប្រវត្តិសាស្ត្រ

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ប្រវត្តិសាស្ត្រខ្មែរ

**សំនាំដើម៖**

ក្នុងលោកនេះ ប្រទេសណាក៏ដូចជាប្រទេសណាដែរ ទោះធំក្តី តូចក្តី សុទ្ធសឹងតែមានប្រវត្តិសាស្ត្រប្រចាំជាតិរៀង ៗខ្លួនទាំងអស់ ។

រីឯប្រទេសខ្មែរវិញ ដែលបានកកើតឡើងហើយមានរូបរាងបន្តិចម្តង ៗ ដោយញើសឈាម និង ពលិកម្មគ្រប់បែបយ៉ាងទាំងអស់ ពីព្រោះបុព្វបុរសខ្មែរ បានតស៊ូប្រឆាំង និង ធម្មជាតិដើម្បីកសាងសំណង់សង្គមជាតិរបស់ខ្លួនឡើង មានរូបរាងតាំងពីសម័យបុរេប្រវត្តសាស្ត្រ ក៏មានពង្សាវតាជាមូលដ្ឋានជាតិ ឬ អត្តសញ្ញាណជាតិ របស់ខ្លួនឯងដែរ ។

គួរកត់សំគាល់ថា ប្រវត្តិសាស្ត្រខ្មែរបានទទួលឥទ្ធិពលអារ្យធម៌ពីឥណ្ឌា ចាប់តាំងពីសតវត្សទី ១ នៃគ.ស ហើយធ្លាប់មានឈ្មោះល្បីល្បាញ ក្រអូបឈ្ងុយឈ្ងប់ជាងគេបង្អស់នៅក្នុងភូមិភាគអាស៊ីប៉ែកអាគ្នេយ៍ ។

បូជនីយដ្ឋាន ប្រាង្គប្រាសាទ បដិមា ស្ពាន ថ្នល់ ផ្ទាំងសិលាចារឹកពីបុរាណ រាប់ពាន់ផ្ទាំង ដែលមាននៅសេសសល់ដេរដាសពាសពេញផ្ទៃប្រទេសកម្ពុជាសព្វថ្ងៃនេះ និង នៅក្នុងទីតាំងនានា នៃអតីតព្រះរាជាណាចក្រកម្ពុជា ដែលសព្វថ្ងៃនេះស្ថិតក្នុង



www.budinst.gov.kh www.elibraryofcambodia.org

បរិវេណទឹកដីរបស់អ្នកជិតខាង ជាពិសេសគឺប្រទេសយួនខាងត្បូង ឈាវ និង ថៃឡង់ដ៍ ជាភស្តុតាង នៃកិរិតវប្បធម៌ របស់ខេមរជនដ៏មហារុងរឿង ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម ត្រចះត្រចង់ផុតកំពូល ។

អាស្រ័យហេតុនេះហើយ ចំពោះកូនខ្មែរ ការស្គាល់ដឹងប្រវត្តិសាស្ត្រប្រចាំជាតិរបស់ខ្លួន ជាពិសេសក្នុងគ្រាលំបាកលំបិននេះ ដែលមាតុភូមិរបស់ខ្លួនកំពុងហែលកាត់ គឺជាអត្តភាពទី១យ៉ាងសំខាន់បំផុត ពីព្រោះប្រវត្តិសាស្ត្រគឺជាឧបករណ៍តែមួយគត់ ដើម្បីទ្រទ្រង់នូវមោទនភាពជាតិ សតិសម្បជញ្ញៈជាតិ ពោលគឺសេចក្តីស្នេហាជាតិយ៉ាងពិតប្រាកដ ។ បើនិយាយម្យ៉ាងទៀត យើងពុំអាចស្រឡាញ់ ឬការពារនូវអ្វីៗ ទាំងអស់ ឱ្យគង់វង្សបាន បើសិនជាយើងពុំស្គាល់នូវតម្លៃដ៏ពិតៗ របស់វត្ថុនោះ ។ ក្នុងន័យនេះហើយ បានជាអ្នកសង្គមវិទូបានសន្និដ្ឋានយ៉ាងត្រឹមត្រូវ *ថាជនជាតិណាដែលមិនស្គាល់អតីតកាលរបស់ខ្លួន ជនជាតិនោះពិតជាគ្មានអនាគតទេ ហើយអាចបាត់បង់នូវ អត្តសញ្ញាណជាតិរបស់ខ្លួនថែមទៀតផង* ។ រួមសេចក្តីមក ប្រវត្តិសាស្ត្រមានសារៈសំខាន់ណាស់ ដោយហេតុថាជាកញ្ចក់ដើម្បីឆ្លុះបញ្ចាំង នូវព្រឹត្តិការណ៍សំខាន់ៗ របស់ជាតិ ឧទាហរណ៍ ពីការបង្កបង្កើនប្រទេស ឬ ពីភាពរុងរឿង ថ្កុំថ្កើងដល់ភាពជួចត់ ខ្លោចផ្សារ ឬភាពចុះទន់ខ្សោយបណ្តាលឡើងដោយការបែកបាក់សាមគ្គីគ្នា ឬ សង្គ្រាមវាតទីនិយម លេបទឹកដី របស់ប្រទេសជិតខាង ពោលប្រវត្តិសាស្ត្រ គឺជាប្រភពនៃវប្បធម៌ អារ្យធម៌ ។ ដោយសារមូលហេតុនេះហើយបានជាមានពាក្យស្លោកមួយថា ៖« *អ្នកណាក្តោបប្រវត្តិសាស្ត្ររបស់ប្រទេសណា*



www.budinst.gov.kh www.elibraryofcambodia.org

*ឲ្យបាន អ្នកនោះពិតជា នឹងត្រួតត្រាប្រទេសនោះបានពុំខាន* » ។ ប្រហែលក្នុងមិជ្ឈភាពនេះហើយដែលជនឈ្នះសង្គ្រាម រមែងតែងចំផ្លាញប្រវត្តិសាស្ត្រ ឬ ក៏សរសេរប្រវត្តិសាស្ត្ររបស់ជនដែលចាញ់សង្គ្រាមសារជាថ្មីឡើងវិញទេដឹង ? ។

ចំពោះយើងដែលជាកុលបុត្រ កុលធិតាខ្មែរ គប្បីត្រូវឈ្វេងយល់ អំពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ប្រចាំជាតិរបស់ខ្លួន ដូចជាសមិទ្ធិផលសំខាន់ៗ របស់បុព្វបុរសយើង ដែលបានបង្កើតឡើងតាំងតែពីសម័យបុរេប្រវត្តិសាស្ត្រ ពោលគឺមុនសម័យដែល « *ប្រទេសកម្ពុជាក្លាយទៅជាព្រះរាជាណាចក្រកម្ពុជា* » ដូចជាការរកឃើញនូវលោហធាតុការផ្សាំងសត្វ ឬ ត្បាញ ល្អី កញ្ជើ ឬសំលៀកបំពាក់ជាដើម ដែលជាកេរ្តិ៍មរតកវប្បធម៌ ។

ថ្វីត្បិតតែសព្វថ្ងៃនេះ បុរាណស្ថានមួយចំនួនធំ ដែលជាមជ្ឈមណ្ឌលវប្បធម៌នាសម័យមុនប្រវត្តិសាស្ត្រនិង សម័យប្រវត្តិសាស្ត្រ របស់ជនជាតិខ្មែរ ត្រូវស្ថិតក្នុងខ័ណ្ឌសីមានៃប្រទេសជិតខាងក៏ដោយ ក៏ប៉ុន្តែស្ថានីយ៍វប្បធម៌ទាំងនោះ នៅតែផ្តល់ចំពោះយើង នូវអត្ថប្រយោជន៍ យ៉ាងធំមហិមា ក្នុងការស្រាវជ្រាវ រាវរក នូវឫសគល់ របស់វប្បធម៌ អារ្យធម៌ខ្មែរ ។

ដូចបានពោល ការវិភាគ សិក្សាដោយវិធីប្រៀបធៀប នូវសំភារៈបុរាណទាំងអស់នោះមិនត្រឹមតែ ពង្រឹង ពង្រីក ឬ អភិវឌ្ឍន៍ នូវចំណេះដឹង ផ្នែកវិទ្យាសាស្ត្រ របស់មិត្តអ្នកអាន តែប៉ុណ្ណោះទេ វាថែមទាំងជាសកម្មភាពមួយយ៉ាងសំខាន់ដើម្បីបញ្ជាក់នូវភាពចំណាស់នៃប្រវត្តិសាស្ត្រកម្ពុជា ។ ព្រោះថា វាជាការពិតណាស់ ដែលការ



www.budinst.gov.kh www.elibraryofcambodia.org

កំណត់នូវវិវ័យចំណាស់របស់វប្បធម៌ អារ្យធម៌ខ្មែរ ត្រូវពឹងពាក់ទាំងស្រុងទៅលើវត្ថុបុរាណទាំងឡាយ ដែលជាមូលដ្ឋាននៃសំណង់សង្គមខ្មែរនាអតីតកាល ក៏ដូចបច្ចុប្បន្នកាល ។ ជានិច្ចកាល អតីតកាលបំភ្លឺបច្ចុប្បន្នកាល ។

ថ្វីបើការស្រាវជ្រាវនេះ នៅមានការខ្វះខាតយ៉ាងណាក៏ដោយ អ្នកសិក្សា ពិតជាអាច និង ដឹងច្បាស់ នូវគោលសំខាន់ៗ ឬលក្ខណៈវិសេសវិសាលរបស់ជនជាតិខ្មែរយើងពុំខាន ដែលជាជនជាតិចាស់ជាងគេបង្អស់ នៅក្នុងភូមិភាគឥណ្ឌូចិនយើងនេះ ។

ក្នុងការតែងសៀវភៅនេះ យើងបានពឹងផ្អែកទៅលើកំណត់ហេតុចិន និង បុរាណវិទ្យា ដែលជាឯកសារមូលដ្ឋាន នៃប្រវត្តិសាស្ត្រកម្ពុជា ។ ម្យ៉ាងទៀតសូមបញ្ជាក់ថា ខុសពីអ្នកនិពន្ធស្រាវជ្រាវជំនាន់មុន ក្នុងអត្ថបទនេះ យើងសូមយកពាក្យខ្មែរ - មន មកប្រើជំនួសពាក្យ មន - ខ្មែរ ទៅវិញ ដែលជាពាក្យបង្កើតដោយលោក William Schmidt ដោយហេតុថា បងប្អូន មន ដែលរួមពូជសាសន៍ជាមួយខ្មែរ បានបង់នូវអធិបតេយ្យភាពរបស់ខ្លួនហើយ ហើយនគររបស់ខ្លួន ដែលត្រូវបង្កើតឡើងនៅចុងសតវត្សទី ៦ ដើមសតវត្សទី ៧ នៃ គ.ស នៅលើទឹកដីរបស់នគរភ្នំ ក៏ត្រូវគេលប់បំបាត់ចោលហើយដែរ ។ រីឯព្រះរាជាណាចក្រកម្ពុជាវិញ ថ្វីត្បិតតែទឹកដីដ៏ធំធេងរបស់ខ្លួនត្រូវសង្គ្រាមវាតទីនិយមបង្រួញឱ្យតូចដូចសព្វថ្ងៃនេះយ៉ាងណាក៏ដោយ ក៏ជនជាតិខ្មែរនៅតែរក្សាបាន នូវព្រះរាជនគរ និង ជនជាតិរបស់ខ្លួន មិនឱ្យសាបសូន្យបាន ។



www.budinst.gov.kh www.elibraryofcambodia.org

# បញ្ហាដែលចោទអំពីកំណើតរបស់ជនជាតិខ្មែរ

ចំពោះបញ្ហាកំណើតនៃជនជាតិខ្មែរ មានទ្រឹស្តីជាច្រើន ដែលមិនចុះសំរុងគ្នា ។ អ្នកនិពន្ធខ្លះសរសេរថា « *ខ្មែរជាឥណ្ឌាទី ២* » ដោយឃើញខ្មែរកាន់សាសនា និង ទំនៀមទម្លាប់បែបឥណ្ឌា ដូចជាពិធីកោរជុក ពិធីបូជាសពជាដើម ។ មានអ្នកស្រាវជ្រាវខ្លះទៀតបារះអាងថា ខ្មែរបានធ្វើដំណើរនៅសម័យបុរេប្រវត្តិសាស្ត្រ ពីទិសខាងជើង គឺប្រទេសទីបេ ចុះមកតាំងទីលំនៅ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ ។ ទន្ទឹមនេះក៏មានអ្នកប្រាជ្ញមួយចំនួន បានសន្និដ្ឋានថា ខ្មែរជាអ្នកកើតនៅលើទឹកដីឥណ្ឌូចិននេះ តែគ្រាន់តែបានទទួលនូវឥទ្ធិពលវប្បធម៌ពីពួកឥណ្ឌា នៅសតវត្សទី ១ នៃគ.ស តែប៉ុណ្ណោះ ។

ចំពោះបញ្ហាដ៏សំខាន់នេះ តើការពិតស្ថិតនៅត្រង់ណា ? តើយើងមានភស្តុតាងអ្វីសំរាប់គាំទ្រ ឬ បដិសេធការវិភាគព្រឹត្តិការណ៍ខាងលើនេះដែរឬទេ ? ។

**មតិទី ១ :**

ដោយសារតែអ្នកនិពន្ធបរទេសមួយចំនួន សង្កេតឃើញថា ខ្មែរ



www.budinst.gov.kh www.elibraryofcambodia.org

ប្រកាន់យកនូវសាសនាឥណ្ឌា គឺព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនា ហើយថែមទាំងបានប្រើអក្សរសំស្ក្រឹត និង ទំនៀមទម្លាប់ក្លិង្គខ្លះដើម្បីគ្រប់គ្រងស្រុកទេស តាមរបៀបឥណ្ឌា ដោយយករបបរាជានិយម ជារបបនយោបាយ គេក៏បានសរសេរថា ខ្មែរជាជនជាតិឥណ្ឌាទី ២ ៖_ *ជនជាតិខ្មែរ ឬ កាសេគៀរ បានរត់ចេញពីប្រទេសកំណើតរបស់ខ្លួន ហើយបានចូលមកនៅក្នុងទឹកដីខ្មែរសព្វថ្ងៃនេះ។* ចំពោះមតិរបស់លោក Adhemard Leclere និង លោកបណ្ឌិត Chatra Premrudee ។ អ្នកនិពន្ធខ្លះទៀតថែមទាំងហ៊ានអះ_អាងថា ខ្មែរមានទីតាំងដើមនៅជើងភ្នំទីបេ ចុះមកភូមិភាគអាស៊ីអាគ្នេយ៍ នាដើមសត_វត្សទី ១ នៃគ.ស ដូចជាទស្សន របស់លោក H. Kern និង លោក Etienne Aymonier ។

## មតិទី ២ ៖

ក្នុងមតិទី ២ អ្នកវិភាគវិទ្យាសាស្ត្រ មានការយល់ឃើញ ខុសប្លែកពីមតិទី១ តាមទ្រឹស្តីរបស់លោកវេជ្ជបណ្ឌិត George Olivier ខ្មែរជាជនជាតិពិសេសមួយស្ថិតក្នុងអំបូរ ខ្មែរ_មន ហើយជនជាតិនេះ បានកើតឡើងនៅលើជ្រោយឥណ្ឌូចិននេះតែម្តង ខុសពីជនជាតិ យួន ចិន លាវ និង ភូមា ដែលមានទីលំនៅដើមរបស់ខ្លួននៅស្រុកចិនភាគខាងត្បូង ហើយស្ថិតក្នុងអំបូរចិនបុរាណ ( Population paleo-mon



www.budinst.gov.kh www.elibraryofcambodia.org

gole ) ឬម៉ុងហ្គោលោអ៊ិត ( Mongoloïde ) ម្យ៉ាងទៀតអ្នកស្រាវជ្រាវនេះ បានបន្ថែមទៀតថា អំបូរខ្មែរ_មន កើតមកពីការផ្សំកាត់ រវាងពួកមេឡាណេស៊ីយាង និងពួកឥណ្ឌូណេស៊ីយាង ( Mélanésien-Indonésien ) ដែលរស់នៅពាសពេញលើសុវណ្ណភូមិ និង នៅលើកោះនានា នៃឈូងសមុទ្រប៉ាស៊ីហ្វិកមានសម្បុរខ្មៅស្រអែម ។ មូលហេតុដែលបណ្ដាលឱ្យគេសន្និដ្ឋានដូច្នោះ គឺមកពីការ រកឃើញនូវ លលាដ៍ក្បាល ដែលដែលមានលក្ខណៈជាមេឡាណេស៊ីយាងនៅឥណ្ឌូចិន ។ លលាដ៍ក្បាល នៃពួកមេឡាណេស៊ីយាង មានអាយុចាស់ច្រើនជាងលលាដ៍ក្បាលនៃពួកឥណ្ឌូណេស៊ីយាង ។

តាមការពិត បើនិយាយអំពីផ្នែកមនុស្សសាស្ត្រវិទ្យា យើងអាចសន្និដ្ឋានថា ពួកឥណ្ឌូណេស៊ីយាងគឺពួក ខ្មែរ_មន តែម្ដង ពីព្រោះ ខ្មែរ_មន ស្ថិតក្នុងក្រុមមនុស្សឥណ្ឌូណេស៊ីយាង គ្រាន់តែមានភាសាខុសគ្នាតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតពួកគេគឺជាលទ្ធផលនៃការវិវឌ្ឍន៍កុលសម្ព័ន្ធនានា ដែលបានរស់នៅតៗ គ្នាពីសម័យមុនៗ មក ។ មូលហេតុនេះអាចបណ្ដាលមកពីការឃ្លាតឆ្ងាយពីគ្នាជាច្រើនម៉ឺនឆ្នាំ ក្រោយពីជ្រោយឥណ្ឌូចិន បានត្រូវផ្ដាច់ចេញពីអាំងស៊ូឡាំង ( Insulinde ) ដោយទឹកជំនន់ ដែលជាលទ្ធផលនៃការផ្លាស់ប្ដូរនូវអាកាសធាតុ ពីត្រជាក់មៅជាក្ដៅដូចសព្វថ្ងៃ ។

ចំពោះលោកវេជ្ជបណ្ឌិត George Olivier ខ្មែរមិនមែនជាជនជាតិ ចិន យួន ឬ ឥណ្ឌាទេ ។ សាសន៍ខ្មែរស្ថិតក្នុងអំបូរខ្មែរ_មន ហើយចំពោះអ្នកប្រាជ្ញរូបនេះ ក្នុងពាក្យពូជសាសន៍ឥណ្ឌូណេស៊ីយាង យើងត្រូវបញ្ចូលជនជាតិឥណ្ឌូណេ_


www.budinst.gov.kh www.elibraryofcambodia.org

ស៊ីយាង ដែលសព្វថ្ងៃនៅប្រទេសឥណ្ឌូណេស៊ី ខ្មែរ_មន និង ពួកខ្មែរលើទាំងអស់ ដូចជាពួកព្នង ស្ទៀង ខា រដែ ច្រាយ កួយ ឬ ព័រ ព្រមទាំងពួកមនុស្សរស់នៅតាមព្រៃភ្នំនៅហ្វីលីពីន ដូចជាពួក កាសាយ សូយ និង ពួកដាយាក នៅប្រទេសឥណ្ឌូណេស៊ីផង ។

ម្យ៉ាងទៀតគួររំលឹកឡើងវិញថា ការសន្និដ្ឋានរបស់លោក វេជ្ជបណ្ឌិតខាងលើនេះ ពឹងពាក់ទៅលើការសិក្សាយ៉ាងហ្មត់ចត់ ឆ្អឹងខ្មោច និង លលាដ៍ក្បាល ដែលគេបានរកឃើញនៅក្នុងភូមិភាគឥណ្ឌូចិន ។ ជាការពិតណាស់ ដែលពួកមេឡាណេស៊ីយាង ជាបុព្វបុរសរបស់ឥណ្ឌូណេស៊ីយាង ខ្មែរ_មន ។ បើនិយាយម្យ៉ាងទៀត មនុស្សបុរាណទាំងអស់នោះ ថ្វីត្បិតតែរស់នៅឆ្ងាយពីគ្នាក៏ដោយ ក៏ប៉ុន្តែស្ថិតនៅក្នុងក្រុមមនុស្សដែលរួមពូជសាសន៍តែមួយ ។

លើសពីនេះទៀត កត្តាដ៏សំខាន់មួយ ដែលបញ្ជាក់នូវការឯកភាពផ្នែកពូជសាសន៍នៃជនជាតិខ្មែរ_មន គឺប្រភេទឈាមម្យ៉ាង ( Hémoglobine E ) ដែលគេបានរកឃើញក្នុងសរសៃឈាមរបស់ពួកគេ ។ ពោលគឺខ្មែរដែលរស់នៅតាមខ្ពង់រាប ឬតាមកោះ ដែលមិនបានទទួលវប្បធម៌ពីក្រៅ មានខ្មែរដែលរស់នៅតាមវាលទំនាប ដែលស្ថិតក្រោមឥទ្ធិពលវប្បធម៌ ហើយបានក្លាយជាពុទ្ធសាសនិកជន ក្រុមមនុស្សទាំងនេះសុទ្ធសឹងតែមានប្រភេទឈាមជ័រ តែមួយ ។ គប្បីសំគាល់ត្រង់នេះថា ក្រៅពីរង្វង់ព្រំដែនខ្មែរ នាសម័យបច្ចុប្បន្ននេះ នៅមានជនជាតិខ្មែរយើងជាច្រើនលាននាក់នាក់ទៀត ដែលកំពុងរស់នៅក្នុងប្រទេសថៃ និង វៀតណាមខាងត្បូង ។ សហគមខ្មែរ



www.budinst.gov.kh www.elibraryofcambodia.org

ទាំងអស់នោះ នៅតែរក្សានូវ ទំនៀមទម្លាប់ និង ភាសារបស់ខ្លួនយ៉ាងជាប់លាប់នៅឡើយ ។ សូមបញ្ជាក់ត្រង់នេះថា ជនជាតិចាម ដែលសព្វថ្ងៃនេះកាន់សាសនាអ៊ិស្លាម ក៏មានប្រភេទឈាមដ៏ពិសេសនេះដែរ ជាហេតុបណ្ដាលឱ្យគេសន្និដ្ឋានថា ពួកគេរួមពូជសាសន៍ ឬអម្បូរជាមួយគ្នា និងខ្មែរ ។



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ចប្បធម៌ខ្មែរ នាបុព្វសម័យ

ការសិក្សាវប្បធម៌ នាសម័យបុរេប្រវត្តិសាស្ត្រ បានបង្ហាញឱ្យយើងដឹងថា មុនគ្រិស្តសករាជ ជនជាតិខ្មែរ មានវប្បធម៌ និង អារ្យធម៌ របស់ខ្លួនយ៉ាងពិតប្រាកដ ។

ក្នុងវប្បធម៌ យើងអាចសង្កេតឃើញនូវការចេះដឹង គ្រប់វិស័យដូចសេចក្តីអធិប្បាយខាងក្រោមនេះ ដែលយើងដកស្រង់ពីការ ស្រាវជ្រាវ អំពីវប្បធម៌ខ្មែរ ។

ក_ *ការចេះដឹងរបស់ខ្មែរ មុនសម័យបុរេប្រវត្តិសាស្ត្រ* ៖

បុព្វបុរសរបស់ជនជាតិខ្មែរ បានបង្កើតការចេះដឹងគ្រប់បែបយ៉ាងមុនសម័យក្លិង្គចូលស្រុក កត្តានេះសឱ្យឃើញថា ខ្លួនមានអារ្យធម៌មួយប្រចាំជាតិរបស់ខ្លួន យ៉ាងពិត ១ ។ សេចក្តីសន្និដ្ឋាននេះ យោងទៅលើសម្ភារៈវប្បធម៌ ដែលបានមកពី ស្ថានីយ៍បុរេប្រវត្តិសាស្ត្រនានា ដែលយើងបានរកឃើញ នៅក្នុងស្រុក និងក្រៅស្រុក ខ្មែរបច្ចុប្បន្ន ។

យើងអាចសង្ខេបសមិទ្ធិផល នាសម័យមុនគ្រិស្តសករាជ ដូចតទៅនេះ ៖_



www.budinst.gov.kh www.elibraryofcambodia.org

- ចេះប្រើឧបករណ៍ គ្រឿងអលង្កា ធ្វើអំពីថ្ម
- ចេះរំលីងថ្ម ដើម្បីធ្វើពូថៅ ពន្លាក ញញួរ
- ចេះធ្លាក់ធ្វើពុម្ពថ្មសម្រាប់ធ្វើកងដៃ កងជើង និង ក្រវិលត្រជាក់សំរឹទ្ធិ
- ចេះប្រើឆ្អឹងសត្វសំរាប់ធ្វេគ្រឿងអល្កងា ផ្លែសន្ទូច ចុងព្រួញ
- ចេះស្ងូនដីធ្វើ លិង្គរូបបុព្វបុរសសំរាប់បូជា
- ចេះត្បាញញើ កន្ទ្រក ឈ្នាង និង ឫស្សី វល្លិ ផ្ដៅ
- ចេះប្រើសំបកខ្យងដើម្បីធ្វើ អង្កាំ ចំហឹ ការត្រចៀក ផ្លែសន្ទូច និង ចិញ្ចៀនដៃ
- ចេះប្រើដីដុត សំរាប់ធ្វើឆ្នាំង ចាន ក្អម ចានទាប ចានមានជើង ចាន ក្រឡូម រូបសត្វ ត្បាល់ ក្រសាលត្រចៀក គ្រា ។ ល ។
- ចេះគូររូបលើជញ្ជាំងភ្នំ ក្នុងគុហា ដោយប្រើពណ៌ស និង ពណ៌ក្រហម
- ចេះផាត់ពណ៌ឆ្នាំង និង ក្រឡ ធ្វើអំពីដីដុត ជាសញ្ញានិមិត្តរូបនៃឈាម ឬ ជីវិត ។
- ចេះស្លលង្ហិន សំរឹទ្ធ ដែក សម្រាប់ធ្វើកណ្ដៀវ ពន្លាក ពូថៅ ខ្សែក កងដៃ កងជើង ជួង ផ្លែសន្ទូច ចុងព្រួញ ។
- ចេះបង្កើតរបាំប្រជាប្រិយ៍ដូចជា រាំត្រុដ រាំកន្ទ្បោង ។ល។ សម្រាប់ ថ្វាយដូនតា ថែរក្សាស្រុក ភូមិ ។


www.budinst.gov.kh www.elibraryofcambodia.org

- ចេះបង្កើតភូមិស្រុក ដោយបានសង់ផ្ទះខ្ពស់ពីដី សម្រាប់ការពារនិងសត្វសាហាវ ឬ ទឹកជំនន់ ។
- ចេះធ្វើស្រែនិងទឹកជំនន់ ចេះប្រើ គោ ក្របីជាយានជំនិះ ឬ សម្រាប់ភ្ជួរស្រែ ចេះធ្វើគ្រឿងភ្លេង និង ប្រើទូក ។
- ចេះប្រើត្បូង ធ្វើប្រហុក ទឹកត្រី ស្រា ទឹកត្នោតជូរ
- ចេះផ្សាំងសត្វព្រៃឱ្យក្លាយទៅជាសត្វស្រុក ដូចជា ដំរី គោ ក្របី ឆ្កែ មាន់ ។ ល ។
- ចេះបូជាសព នៅក្រោមផ្ទាំងថ្មធំ១ ក្នុងក្ពាមឈ្ងស ឬ ក្នុងក្រឡធ្វើអំពីដីដុត ។ ល ។

ខ_ *ជំនឿផ្សេង១ :*

នាបុព្វសម័យ ខ្មែរមានជំនឿហើយ ។ ជំនឿទាំងនោះជាមធ្យោបាយ ធ្វើឱ្យខ្មែរមានសាមគ្គីធមិរវាងគ្នា ពីព្រោះកាលបើគេមានជំនឿដូចគ្នា ការប្រា_ស្រ័យទាក់ទង ក៏មានសភាពស្និទ្ធស្នាល ជិតស្និទ្ធឡើងក្នុងសង្គម ។ លើសពីនេះទៀត ជំនឿញុំាងឱ្យមនុស្សដឹងបុណ្យ ដឹងបាប ស្គាល់សេចក្តីល្អ អាក្រក់ ។ បើបុព្វបុរសខ្មែរយើងជឿថា ដើមឈើមួយណា ដែលជាទីស្នាក់នៅរបស់ អារក្សអ្នកតា



www.budinst.gov.kh www.elibraryofcambodia.org

ដែលជាខ្មោចរបស់ជូនតាស្លាប់ គេក៏រាប់រកគ្នា ដើម្បីគោរពបូជាដើមឈើនោះ នៅតាមភូមិ ស្រុកទៅ ។

គ_ *ទំនៀមទម្លាប់ :*

គេអាចនិយាយបានថា ទំនៀមទម្លាប់ គឺការចូលចិត្ត ការនិយមនូវរបស់អ្វីមួយ ហើយរបស់នោះក៏បានថ្កិតភ្ជាប់ ក្នុងរូបភាពអារ្យធម៌ ពិបាករំលាយបានងាយ ដូចជាជំនឿ ខ្មោច អារក្ស អ្នកតា ឬជំនឿលើធម្មជាតិ ឧទាហរណ៍ កាលណាឃើញផ្កាយដុះកន្ទុយ គេសន្និដ្ឋានថាស្រុក ពិតជាកើតកោលាហលពុំខាន ដូចជាមានសង្គ្រាមឬទឹកជំនន់ ។ យើងអាចលើកឧទាហរណ៍ច្រើនទៀតមកបង្ហាញ ដូចជាត្រណមខ្លះ ៗ ដែលទាក់ទងទៅនិង ការទាក់ដីរ ឧទាហរណ៍ ពេលប្ដីចេញទៅទាក់ដីរ ប្រពន្ធមិនត្រូវវាយកូន សិតសក់យំ ជាដើម ។

ឃ_ *សីលធម៌ :*

ថ្វីត្បិតតែខ្មែរនាសម័យបុរេប្រវត្តិ ពុំបានបង្កើតតួអក្សរនៅឡើយ ដើម្បីសរសេរក្បួនខ្នាតក៏ដោយ តែការកប់ឧបករណ៍ប្រើប្រាស់ ម្ហូបអាហារក្នុងផ្នូរខ្មោច បង្ហាញឱ្យយើងដឹងថា គេមានសីលធម៌ក្នុងទម្លាប់គោរពអ្នកដែលបាត់បង់ជីវិតទៅហើយ។ ពោល គឺគេដឹងខុស ដឹងត្រូវ ដឹងគុណ ដឹងទោស ដឹងបុណ្យដឹងបាប ។

ទាំងនេះជាហេតុដែល បណ្ដាលឱ្យខ្មែរនាសម័យនោះយកសពរបស់គ្រួសាររួមឈាមហិតទៅកប់ដោយភ្ជាប់ជាមួយសព នូវសំណែនផ្សេង ៗ សម្រាប់បរិភោគ ឬប្រើប្រាស់ទៅបរលោក ។



www.budinst.gov.kh www.elibraryofcambodia.org

ង_ *ទស្សនៈវិជ្ជា* ៖

ក្នុងវប្បធម៌និមួយ ១ មនុស្សតែងមានទស្សនៈវិជ្ជា ដែលជាប្រដាប់សញ្ជឹងត្រិះរិះ ហើយទស្សនៈវិជ្ជា មានទាក់ទងក្នុងទំនៀមទម្លាប់ទាំងអស់ ។ ឧទាហរណ៍ ៖ ការដែលបុព្វបុរសយើងកប់ខ្មោចឱ្យអង្គុយចោងហោងក្នុងក្រឡ បញ្ជាក់អោយឃើញថា គេមានការយល់ឃើញថា មនុស្សដែលស្លាប់ទៅ អាចចាត់ទុកថាជាទារកនៅក្នុងផ្ទៃម្ដាយមុននឹងកើត ។ បើគេយកខ្មោចទៅកប់ក្នុងដី ដូចទារកនៅក្នុងផ្ទៃម្ដាយ មានន័យថា គេជឿថាជីវិតមិនសាបសូន្យក្រោយពេលស្លាប់ ។ បើនិយាយម្យ៉ាងទៀត ព្រលឹងត្រូវចាប់ជាតិឡើងវិញ ។

គឺទស្សនៈវិជ្ជានេះហើយ ដែលធ្វើឱ្យពួកគេ សាកល្បងពន្យល់កំណើតនៃសត្វលោកឬមនុស្សតាមទស្សនៈរបស់ខ្លួន ហើយចំពោះបញ្ហា ដែលទាក់ទងមៅនឹងវេទកថានេះ យើងមានរឿងព្រេងខ្មែរជាច្រើនជាសក្ខីភាពស្រាប់ ។

ច_ *ភាសា* ៖

ជាធម្មតាដែលសង្គមនិមួយ ១ គេតែងមានភាសារបស់ខ្លួនដើម្បីទាក់ទងគ្នា និង ផ្សព្វផ្សាយចំណេះវិជ្ជា ការចេះដឹង និង ទំនៀមទម្លាប់ ។ ហេតុនេះ ភាសាខ្មែរត្រូវបានបង្កើតឡើងមុនក្លិង្គចូលស្រុក សម្រាប់ប្រាស្រ័យទាក់ទងគ្នា ។ ភាសាខ្មែរស្ថិតក្នុងអំបូរ ខ្មែរ_មន តែមានការវិវត្តន៍ក្រោមឥទ្ធិពលវេយ្យាករណ៍សំស្ក្រឹត និង បាលីខុសពីជនជាតិខ្មែរដទៃទៀត ដែលរស់នៅតាមព្រៃភ្នំ ពុំដែលបានមានទំនាក់ទំនង និងវប្បធម៌បរទេស ។



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# បុរេប្រវត្តិសាស្ត្រខ្មែរ

**សេចក្តីផ្តើម ៈ**

ប្រទេសកម្ពុជា ជាប្រទេសចាស់ ដែលវប្បធម៌ អារ្យធម៌របស់ខ្លួន បានចាប់ផ្តើមច្រើនសែនឆ្នាំមកហើយ អ្នកប្រវត្តិសាស្ត្រវិទូបានបែងចែកប្រវត្តិសាស្ត្រខ្មែរជាពីសម័យធំ១ ៈ

សម័យមុនបង្កើតតួអក្សរ ឬសម័យបុរេប្រវត្តិ និងសម័យប្រវត្តិសាស្ត្រ ឬសម័យ ដែលខ្មែរចេះប្រើតួអក្សរឥណ្ឌាបង្កើតជាអក្សរខ្មែរ ដើម្បីកត់ត្រាព្រឹត្តិការណ៍នានា ឬពង្សាវតារ ។ល។ ប្រចាំជាតិខុសពីពួកខ្មែរលើ ដែលមិនបានទទួលឥទ្ធិពលពីឥណ្ឌា ឬប្រទេសជិតខាង ហើយរស់នៅតាមរបៀបព្រៃភ្នំ ។

បុរេសម័យ ជាសម័យមួយ ដែលមានអាយុជាយូរលង់ណាស់មកហើយ ហើយជាសម័យមួយ ដែលប្រវត្តិវិទូពិបាកនឹងតាំងអាយុដោយទៀងទាត់ តែដោយសារសំណង់នៃសំភារៈ ឬ ឆ្អឹងមនុស្សសម័យដើមក៏អាចដឹងពីចំណាស់ នៃសំណល់ទាំងអស់នោះដែរ ។ បុរេប្រវត្តិនៃកម្ពុជាបានចាប់ផ្តើមតាំងពីប្រមាណ ៦៨០.០០០ ឆ្នាំមុនគ្រិស្តសករាជ មកដល់សតវត្សទី១ នៃគ្រិស្តសករាជ ។ ក្នុងរយៈពេលដ៏យូរអង្វែងនេះ បុព្វបុរសរបស់ជនជាតិខ្មែរមិនទាន់ចេះសរសេរនៅឡើយទេ ។ រីឯសម័យប្រ



www.budinst.gov.kh www.elibraryofcambodia.org

វត្តិសាស្ត្រវិញ ដែលបានចាប់បដិសន្ធិឡើង នៅដើមសតវត្សទី១ នៃគ្រិស្តសករាជ ខ្មែរចេះប្រើប្រាស់នូវតួអក្សរ ដើម្បីកត់ត្រាហេតុការណ៍ផ្សេង ១ ដែលទាក់ទង និង សង្គមជាតិរបស់ខ្លួន ។ ចំពោះបញ្ហានេះ កំណត់ហេតុចិន បានបញ្ជាក់ថា នៅនគរភ្នំ មានឃ្លាំងឯកសារ និង ព្រះរាជពង្សាវតា របស់ខ្លួនយ៉ាងច្បាស់លាស់ នាសតវត្សទី ៣ នៃគ្រិស្តសករាជ ។

ចំពោះប្រវត្តិសាស្ត្រខ្មែរ គួរកត់សំគាល់ថា ខ្មែរបានខ្ចីអក្សរឥណ្ឌាភាគខាងត្បូងហៅថា អក្សរបល្លវៈ មកកត់ត្រាពាក្យពេចន៍ សំដីវាចា ឆ្លើយឆ្លងរបស់ខ្លួន ដែលជាភាសាស្ថិតក្នុង អំបូរភាសា ខ្មែរ_មន ពេលដែលជនជាតិក្លឹង្គ វិត្ថារកម្មមកលើភូមិភាគមួយ ដែលគេឱ្យឈ្មោះថា ប្រទេសនគរភ្នំ នាសតវត្សទី ១ នៃគ្រិស្តសករាជយើងនេះ ។ ពោលគឺជនជាតិខ្មែរ ដែលមានភាសារបស់ខ្លួន ក្នុងបំណងធ្វើវាក្យស័ព្ទឱ្យកាន់តែធំធាត់ រីកចំរើនឡើងតែប៉ុណ្ណោះ ។

មយ៉ាងទៀតចំពោះពាក្យសំស្ក្រឹត បាលីទាំងឡាយ ដែលខ្មែរបានខ្ចីពីបរទេស ខ្មែរអានបញ្ចេញសូរសៀងទៅតាមសូរស័ព្ទខ្មែរ ពីព្រោះខ្មែរចេះកាឡៃពាក្យខ្ចីទាំងអស់នោះ ឱយក្លាយទៅជាពាក្យខ្មែរ ។



www.budinst.gov.kh www.elibraryofcambodia.org

## ការចងក្រងបុរេប្រវត្តិសាស្ត្រនៃកម្ពុជា ៖

ការចងក្រងប្រវត្តិសាស្ត្រខ្មែរ មុនសតវត្សទី ៧ នៃគ្រឹស្តសករាជជាកិច្ចការមួយ ដែលពោរពេញទៅដោយឧបសគ្គគ្រប់បែបយ៉ាងទាំងអស់ ។ ហេតុដែលនាំអោយមាន ការពិបាកយ៉ាងក្រៃលែង ក្នុងការស្រាវជ្រាវពុំមែនបណ្តាលមកពីកង្វះឯកសារទេ ដែល ជាមូលដ្ឋាននៃប្រភពវប្បធម៌ អារ្យធម៌ខ្មែរដូចជាបុរាណវត្ថុ នៃស្ថានីយ៍បុរេប្រវត្តិ ឬក៏ ផ្ទាំងសិលាតាមគុហាជាដើម ប៉ុន្តែមកអំពីបុព្វហេតុធំមួយ គឺការពុំទាន់ប្រើប្រាស់នូវតួ អក្សរ ដើម្បីកត់ត្រាក្បួនខ្នាតទំនៀមទម្លាប់ ឬព្រឹត្តិការណ៍សំខាន់ៗ ដោយបុព្វបុរស ខ្មែរក្នុងសម័យដ៏យូរអង្វែងនោះនៅឡើយ ។ ឧបសគ្គមួយទៀត បណ្តាលមកពីភាព រាត់រាយនៃទីលំនៅដើមនៃបុព្វបុរសខ្មែរ ដែលស្ថិតនៅពាសពេញ លើជ្រោយសុវណ្ណ ភូមិនេះ ។ ដើម្បីធ្វើអោយការសិក្សា មានប្រយោជន៍ដ៏ប្រសើរ អ្នកប្រាជ្ញខាងបុរេ ប្រវត្តិ ត្រូវប្រមូលប្រជុំបុរាណវត្ថុ មុនសម័យបង្កើតតួអក្សរទាំងអស់នោះ ហើយ ចាត់ទុកជាបេតិកភណ្ឌ ឬជាកេរដំណែលពីដូនតានៃពួកខ្មែរ_មន ។

ថ្វីត្បិតតែមានឧបសគ្គធំៗខាងលើនេះក៏ដោយ ការចងក្រងទំព័របុរេប្រវត្តិកម្ពុជា ក៏អាចប្រព្រឹត្តទៅឡើងបានដែរ ដោយការធ្វើសំយោគនូវកំណាយទាំងអស់ ។ បើ និយាយម្យ៉ាងទៀត ក្នុងការរិះរកស្រាវជ្រាវវប្បធម៌ខ្មែរមុនសម័យក្លឹងចូលស្រុក យើង នឹងត្រូវពឹងផ្អែកទាំងស្រុងទៅលើវត្ថុបុរេប្រវត្តិ ដែលជាប្រភពនៃអារ្យធម៌ វប្បធម៌



www.budinst.gov.kh www.elibraryofcambodia.org

ខ្មែរ ។ ម៉្យាងទៀតការស្រាវជ្រាវនេះពិតជានៅមានការខ្វះខាតជាដំណាំពុំខាន តែយើងជឿជាក់យ៉ាងមាំមួនថា វាពិតជាផ្តល់ចំពោះការសិក្សានូវផល ផ្លែ ឬអត្ថប្រយោជន៍ បើពុំច្រើនក៏តិចដែរ ។

**វប្បធម៌ - អារ្យធម៌នាសម័យបុរេប្រវត្តិនៅកម្ពុជា ៖**

មុនដំបូងបង្អស់គួរកត់សំគាល់ថា ខុសពីសត្វ មនុស្សចេះបង្កើតរបស់ប្រើប្រាស់ឧបករណ៍គ្រប់ប្រភេទ ។ ការស្ថាបនា ឬការនិយមនូវគ្រឿងសំភារៈនេះ សរអោយឃើញថា មនុស្សយើងចេះគិតពិចារណា ពោលគឺប្រកបដោយបញ្ញា ឬប្រាជ្ញា ។ អាស្រ័យហេតុនេះហើយ បានជាក្នុងការស្រាវជ្រាវរករប្រភពអរិយធម៌នៃសញ្ជាតិនីមួយៗ អ្នកប្រាជ្ញផ្នែកបុរេប្រវត្តិ ត្រូវពឹងផ្អែកទៅលើ វត្ថុបុរាណដែលជាផលិតកម្មរបស់មនុស្សសុទ្ធសាធ ។

ថ្វីបើបុរេប្រវត្តិនៃប្រទេសកម្ពុជា មានអាយុតិចជាងបុរេប្រវត្តិនៃប្រទេសអាហ្វ្រិកខ្លះក៏ដោយ ជាពិសេសប្រទេស Tanzanie ដែលមានអាយុប្រមាណ១លានឆ្នាំកន្លះ ក៏បុរេប្រវត្តិខ្មែរ មានចំណាស់ស្មើនឹងប្រទេសនានាក្នុងសាកលលោកដែរ ដោយសម្ភារៈថ្មដំបូងបំផុតដែលគេបានរកឃើញ មានអាយុប្រហែលជា ៦០០.០០០ ឆ្នាំមុនគ្រឹស្តសករាជ ។

អាងលើការរកឃើញ នូវគ្រឿងប្រើប្រាស់ឧបករណ៍បុរាណជាច្រើនប្រភេទទាំងអស់នោះ យើងអាចសន្និដ្ឋានយ៉ាងប្រាកដថា នៅលើទឹកដីកម្ពុជាយើងនេះ មាន



www.budinst.gov.kh www.elibraryofcambodia.org

មនុស្សរស់នៅតាំងតែសម័យបុរេប្រវត្តិសាស្ត្រម្ល៉េះ ហើយជនជាតិខ្មែរ ជាជនជាតិដែលកើតឡើងនៅលើជ្រោយសុវណ្ណភូមិនេះ ។

ម៉្យាងវិញទៀត ដោយសារកំណាយជាច្រើន ដែលគេបានរកឃើញនៅលើទឹកដីកម្ពុជាបច្ចុប្បន្ននេះ គេអាចអះអាងថា បុរេប្រវត្តិខ្មែរ មានការរីកចំរើនល្អណាស់ និងការវិវឌ្ឍន៍ ពីយុគថ្មគ្រួសរហូតដល់យុគលោហធាតុ ដូចប្រទេសនានា ក្នុងសកលលោកនេះដែរ ។

ប្រភពវប្បធម៌ អារ្យធម៌ខ្មែរ បានកើតឡើងមុនឥទ្ធិពលឥណ្ឌា ដែលជះកាំរស្មីលើសង្គមខ្មែរតូច ដែលស្ថិតនៅក្រោមការដឹកនាំត្រួតត្រារបស់មេកន្ត្រាញ ។ ដោយការប្រៀបធៀប សិក្សាប្រភេទគ្រឿងឧបករណ៍ទាំងអស់នោះ ធ្វើឡើងក្នុងយុគ ឬសម័យថ្មបុរេប្រវត្តិវិទ្យាខ្មែរ ចែកបុរេប្រវត្តិខ្មែរជា ៥សម័យសំខាន់ៗដែលមានដូចតទៅ ៖

១. **សម័យថ្មបរមបុរាណ ៖** Paléolithique

**សម័យថ្មគ្រួសបំបែក ៖** Galet aménagé

ពីអាយុ ៦០០.០០០ ឆ្នាំ ដល់ ១២០.០០០ ឆ្នាំ មុនគ្រឹស្តសករាជ យុគនេះអាចទុកជាដើមសម័យអារ្យធម៌ខ្មែរ ហើយការចងក្រងទំព័រប្រវត្តិសាស្ត្រកម្ពុជាត្រូវស្ថិតនៅលើ សម្ភារះវប្បធម៌ដ៏បូងបង្អស់នេះជាមូលដ្ឋាន ។

នៅក្នុងសម័យនោះ មនុស្សប្រើថ្មឬគ្រួសធំៗ មានទំហំប៉ុនកដៃកជើង ធ្វើជាអាវុធ ឬគ្រឿងឧបករណ៍ ដោយបំបែកអោយមានមុខមុតដូចជា ពូថៅ ឬពន្លាកជា



www.budinst.gov.kh www.elibraryofcambodia.org

ដើម ។ គ្រួសធំៗដែលគេយកមកធ្វើជាប្រដាប់ប្រដាប្រើ ភាគច្រើនជាគ្រួសសាមញ្ញ ដែលគេជួបប្រទះនៅតាមដងស្ទឹង ឬមាត់ទន្លេផ្សេងៗ ។

ដោយសំអាងទៅលើអាវុធ ឬឧបករណ៍ក្នុងសម័យនោះ ដែលធ្វើឡើងដោយគ្រួសថ្មបំបែក គេក៏តាំងឈ្មោះថា ជាសម័យវប្បធម៌គ្រួសថ្មបំបែក ។

វប្បធម៌នេះ ចាប់ផ្ដើមឡើង ប្លេអ៊ី ស្តូសែន ដែលជាសម័យចុងក្រោយបំផុតនៃចតុត្ថសក ដែលចាប់ផ្ដើមពី ១០០.០០០ ឆ្នាំ ដល់សព្វថ្ងៃនេះ ។ នៅកម្ពុជាយើង វប្បធម៌គ្រួសថ្មបំបែកនេះ ផ្ដើមនៅពាក់កណ្ដាល ប្លេអ៊ី ស្តូសែន ហើយបញ្ចប់នៅចុងសម័យនេះរវាង ៦០០.០០០ ឆ្នាំ និង ១២០.០០០ ឆ្នាំ ។

សម័យនេះ មនុស្សពុំទាន់មានសេចក្ដីរីកចំរើន ដូចសម័យក្រោយទេ ពោលគឺពុំទាន់ចេះដាំដើមឈើសំរាប់ហូបផ្លែឬក៏ចិញ្ចឹមសត្វពាហនៈ ដើម្បីយកសាច់ធ្វើជាចំណីអាហារនៅឡើយទេ ។ គេគ្រាន់តែចេះចាប់សត្វព្រៃ ហែកស្បែកវាដោយធ្មេញទទេ ហើយបរិភោគឆៅតែម្តងប៉ុណ្ណោះ ឬក៏បេះស្លឹកឈើ ឬគាស់រកមើមឈើតាមព្រៃភ្នំ

ម្យ៉ាងទៀតបុព្វបុរសយើង ប្រហែលជាពុំទាន់ចេះប្រើភ្លើងនៅឡើយពេរោះព្រោះរហូតដល់ពេលនេះ ឯកសារវប្បធម៌ ដែលគេជួបប្រទះទាំងប៉ុន្មាន ពុំអាចជំរុញអោយឃើញ បានសន្និដ្ឋានអំពីបញ្ហានេះអោយច្បាស់លាស់ដែរ ។

លោកបុរេប្រវត្តិវិទូ អេតមុងស្សូរាំង បានជួបប្រទះ ឧបករណ៍នេះជាលើកដំបូងបំផុតនៅឆ្នាំ ១៩៦៣ នៅលើទឹកដីកម្ពុជាសព្វថ្ងៃនេះនៅក្នុងភូមិភាគដែលស្ថិតនៅតាមដងទន្លេមេគង្គ រវាងស្ទឹងត្រែង និងសំរោងជាពិសេសនៅភូមិស្សូវ ឬភូមិឫស្សី ។ល។



www.budinst.gov.kh www.elibraryofcambodia.org

តាមអ្នកស្រាវជ្រាវបារាំងសែសនេះ វត្ថុបុរាណទាំងអស់នោះមានអាយុប្រហែល ៦០០.០០០ -៥០០.០០០ ឆ្នាំមុនគ្រិស្តសករាជ ។

សូមបញ្ជាក់ថា អ្នកប្រាជ្ញដដែលនេះ ក៏បានរកឃើញនូវឧបករណ៍ថ្មបំបែកនេះ ក្នុងប្រទេសយួនខាងត្បូង ឬកម្ពុជាក្រោមនៅតាមដងស្ទឹងដូនណៃ ។

ម្យ៉ាងទៀត យើងអាចសំគាល់ថា យួនខាងជើង *ឧ. នៅតំបន់ហ៊្វឺ* ប្រទេសលាវ *ឧ. នៅចាំហាង* ប្រទេសភូមា *ឧ. នៅតាមដងទន្លេ អៀរ៉ាក្វាឌី* ប្រទេសឥណ្ឌូណេស៊ី *ឧ. កោះជ្វាហ្សាវ៉ា* - ប្រទេសទាំងអស់នេះ ក៏មានឧបករណ៍ថ្មបំបែកដូចគ្នានឹងកម្ពុជាដែរ ។ រីឯអាយុវិញក៏ប្រហាក់ប្រហែលគ្នា នឹងឧបករណ៍ដែលគេរកឃើញនៅកម្ពុជានិងកម្ពុជាក្រោមដែរ ។ ដោយហេតុថាក្នុងបុព្វសម័យដ៏យូរអង្វែងនោះ ពុំទាន់មានព្រំដែននយោបាយ ឬជាតិសាសន៍នៅឡើយទេ ។

ក្នុងសម័យនេះមនុស្សមានការចំរើនផ្នែកវប្បធម៌ ហើយដូចជាការរកឃើញធាតុភ្លើង សម្រាប់ចំអិនម្ហូបអាហារប្រចាំថ្ងៃ និងការស្គាល់បានឧបករណ៍ប្រើប្រាស់ជាសក្តិ-ភាព ។

**២. ពី ១២០.០០០ ដល់ ១២.០០០ ឆ្នាំមុនគ្រិស្តសករាជ :**

ខុសពីសម័យមុន ដែលគេគ្រាន់តែរើសយកថ្មធម្មជាតិ មកពុះជាពីរឬជាបី ដើម្បីយកមុខមុតធ្វើជាអាវុធ ក្នុងសម័យនេះមនុស្សចេះចាំងថ្មធ្វើជាស្នាប់ដៃមានរូបសំប៉ែត ។ មិនតែប៉ុណ្ណោះ គេចេះធ្វើអាវុធបំបែកតូចៗ ដូចជាខ្មោសជាដើមសំ.



www.budinst.gov.kh www.elibraryofcambodia.org

វាប់កោសស្បែកសត្វ ឬរចនាគ្រឿងឧបករណ៍ផ្សេងៗ ។ ឧស្សាហកម្មថ្មមានទ្រង់ទ្រាយល្អិតល្អន់ជាងមុន ។ គេជួបប្រទះក្នុងសម័យនេះ នូវពូថៅថ្មមានរូបរាងជាត្រីកោណ ចតុកោណ ឬចតុកោណកែង ដែលមានលក្ខណៈល្អប្រណិត ។

ការរកឃើញនូវឧបករណ៍ព្រមទាំងសំណល់ម្ហូបអាហារ ដូចជាឆ្អឹងសត្វជាដើម ភ្ជាប់ជាមួយនិងខ្មោច បញ្ជាក់អោយឃើញថា មនុស្សចេះគោរពសព ចេះសែនព្រេនបុព្វបុរសរបស់គេ ដែលបានចែកឋានទៅ ។ គួរបញ្ជាក់ថាមនុស្សរស់នៅតាមខ្ពង់រាបតាមវាល ឬ ក្នុងរូងភ្នំនានា ។

ក្នុងវិស័យសេដ្ឋកិច្ច ការសិក្សាគ្រឿងសំភារៈប្រើប្រាស់ដែលគេរកឃើញ បង្ហាញអោយយើងដឹងថា ក្នុងយុគនេះមនុស្សពុំទាន់ចេះរំលីងថ្ម ត្បាញ ចិញ្ចឹមសត្វ ឬដាំដើមឈើ-ស្រូវនៅឡើយទេ ។

## ២. សម័យថ្មបំបែកក្លាយ : Mésolithique

ពី ១២.០០០ ដល់ ៨.០០០ ឆ្នាំ មុន គ្រិស្តសករាជ វប្បធម៌នេះមានកំណើតចេញពីវប្បធម៌មុន ។ នៅតាមគុហាភ្នំខ្លះ គេបានជួបប្រទះនូវសំភារៈប្រើប្រាស់ ដែលធ្វើអំពីថ្មក្នុងស្រទាប់ដី ដែលលាយឡំជាមួយសរីរាង្គមនុស្សផង ។

លក្ខណៈនាសម័យនេះមិនខុសពីសម័យមុនទេ គ្រាន់តែមានរូបរាងប្រសើរជាងមុន ។

គួរគប្បីបញ្ជាក់ថា ឆ្អឹងលលាដ៏ក្បាលមនុស្សដែលគេរកឃើញ មាន



www.budinst.gov.kh www.elibraryofcambodia.org

លក្ខណៈជា ឥណ្ឌូណេស៊ីអែន ខ្មែរ-មន មិនខុសពីពួកខ្មែរលើឬខ្មែរសព្វថ្ងៃទេ ។ ដោយសំអាងទៅលើកត្តានេះហើយ បានជាគេអាចសន្និដ្ឋានថា ពួកមនុស្សទាំងអស់នេះជាបុព្វបុរសរបស់ជនជាតិខ្មែរសព្វថ្ងៃនេះ ។

តាមឯកសារ ដែលគេបានស្រាវជ្រាវ មនុស្សចេះស៊ីគ្រាប់ធញ្ញជាតិព្រៃ ចាប់ផ្ដើមចេះរំលីងថ្ម ឬផ្សាំងសត្វព្រៃ ។ លើសពីនេះទៀត ការសិក្សាពីបុព្វប្រវត្តិនាសម័យនេះ បង្ហាញអោយយើងដឹងថា ជនជាតិខ្មែរដើម ឬខ្មែរ-មន នៅចុងយុគនេះ បានចាប់ផ្ដើមធ្វើផ្លាំងចានដោយដីដុត ។ តែភាជន៍ដីទាំងអស់នោះពុំទាន់មានសភាពរីកចំរើន ឬគុណភាពល្អដូចសម័យក្រោយទេ ។

" *ក្នុងសម័យនេះ ខ្មែរពុំទាន់ចេះរំលីងថ្មនៅឡើយ* "

## ៤. យុគវប្បធម៌នវៈសិលា ឬយុគថ្មរំលីង : Neolithique

ពី ៨.០០០ ដល់ ២.០០០ ឆ្នាំ មុនគ្រិស្តសករាជ គួរបញ្ជាក់ថាសម័យនេះកើតក្រោយពីសម័យមុន ហើយក្នុងសម័យនេះដែលអ្នកបុរាវិទូ ចាត់ទុកថាជាសម័យបដិវត្តន៍ផ្នែកសេដ្ឋកិច្ច Révolution économique មានការផ្លាស់ប្ដូរគ្រប់វិស័យផ្នែកជំនឿក៏ដូចផ្នែកសង្គមកិច្ច ។ មនុស្សចេះដាំរុក្ខជាតិ ដូចជាស្រូវ ។

យ៉ាងណាមិញ ខ្មែរបុរាណក្នុងសម័យនោះ ចេះរស់ដោយកសិកម្មនិងដោយការចិញ្ចឹមសត្វ ដើម្បីយកសាច់និងពងមកទទួលទាន ។ កំណាយមកពីស្ថានីយ៍បុរេ បង្ហាញអោយយើងដឹងថា គេចេះបូជាសពដោយកប់ ក្នុងផ្នូរខ្មោចនូវគ្រឿង



www.budinst.gov.kh www.elibraryofcambodia.org

អលង្ការ ឬឧបករណ៍ផ្សេងៗគ្រប់បែបយ៉ាងទាំងអស់ ។ សំណល់វប្បធម៌បានអោយពតិមានថា មនុស្សចូលចិត្តធ្វើផ្ទះខ្ពស់ពីដី ហើយរស់ផ្តុំជាភូមិស្រុក ។ ខ្លះទៀតក៏រស់នៅក្នុងរូងភ្នំ ឬខ្ពង់រាប ។

លើសពីនេះទៀត គេចេះត្បាញសំពត់ប៉ុង ហើយចេះធ្វើគ្រឿងលំអកាយ ដូចជាទងការ ឬក្រសាលធ្វើអំពីភ្លុក ខ្យង ឈើ ត្បូង ថ្ម និងដីដុត ។ ការវិវឌ្ឍន៍មួយដ៏ធំ ផ្នែកបច្ចេកទេសគឺការរំលីងថ្មដោយខ្មែរដើម ។ គួររំលឹកឡើងវិញថា ពូថៅថ្មក្នុងយុគថ្មថ្មីនេះ មានលក្ខណៈរលោង ។ ឧ. *ត្បាល់និងអង្រែ និងរូបសត្វដែលគេបានរកឃើញក្នុងស្ថានីយ៍បុរេ* ។

ក្នុងជំនឿសាសនា គេសង្កេតឃើញមានការគោរពបូជាបុព្វបុរស ។ មនុស្សនាជំនាន់នោះសន្និដ្ឋានថា សត្វជាដើមសន្តតិវង្សដូចជា ទុង កុក ត្រី ត្រកួត ពស់ ប្រើស... ។ បុព្វហេតុដែលជំរុញអោយយើងហ៊ានអះអាងដូច្នេះ បណ្តាលមកពីការរកឃើញនូវរូបសត្វ ធ្វើអំពីដីដុតជាច្រើនក្នុងផ្នូរខ្មោច ដូចជា មាន់ បង្កួយ គោ ក្របី ដំរី ក្អែប ពស់ជាដើម ។ យ៉ាងណាមិញក្នុងច្បាប់ ព្រះរាជពង្សាវតារខ្មែរ ជាពិសេសនៅក្នុងភាគទី១ យើងឃើញមានការពណ៌នាពីសត្វត្រកួតនិងភុជង្គនាគ ដែលយើងអាចសន្និដ្ឋានថា ជាសំណល់នៃជំនឿនាសម័យមុនក្លិង្គចូលស្រុក ។

ការសិក្សាឧបករណ៍ធ្វើអំពីលោហធាតុក្នុងសម័យនេះ អោយដឹងថាខ្មែរដើមចេះរកឃើញនូវជាតិរ៉ែ ដូចជា កណ្តៀវ លំពែង កងជើង កងដៃ ធ្វើអំពីសំរិទ្ធិឬស្ពាន់ ។ គួរកត់ត្រាថានៅចុងយុគនេះ មនុស្សបានរកឃើញពណ៌ ហើយគេ



www.budinst.gov.kh www.elibraryofcambodia.org

យកមកផាត់ភាជន៍ដីទាំងអស់នោះ ដើម្បីអោយមានទ្រង់ទ្រាយល្អប្រណិត ។

**៥. សម័យលោហធាតុ :** Métallurgie

ពី ២.០០០ ដល់ ១០០ ឆ្នាំ មុនគ្រិស្តសករាជ ។

ក្នុងសម័យនេះ ប្រដាប់ប្រដាដែលគេប្រើប្រាស់ ភាគច្រើនគេធ្វើអំពីស្ពាន់ ដែក សំរិទ្ធ ទង់ដែង សំណ និងភក់ ។

គេចេះយកដីឥដ្ឋទៅជាពុម្ពត្រា ហើយនៅលើមុខត្រាគេឆ្លាក់រូប ឬក្បាច់ក្បូរ ហើយយកទៅប្រថាប់នៅលើសំពត់ជាលំអ ។

គេក៏បានប្រទះឃើញដែរនូវផ្នូរធំៗ សង់អំពីថ្មាំងថ្ម សំរាប់បញ្ចុះខ្មោច *រូបភាព* ។ ស្ថានីយ៍បុរេសំខាន់ៗនៃកម្ពុជា ដែលស្ថិតនៅតាមវាលទំនាប គឺសំរោងសែន អន្លង់ផ្តៅ ម្លូព្រៃ ល្អាងព្រៃកន្លង សាហ៊ីញ ស៊ីងឡុក កោះអណ្តើក និង អូរកែវ " *កម្ពុជាក្រោម* " ។ល។

រួមសេចក្តីទៅ សម័យចុងក្រោយនេះជាសម័យមួយជឿនលឿនបំផុត ហើយការរស់នៅក៏មិនខុសពីជីវភាពសព្វថ្ងៃតាមជនបទនៃកម្ពុជាដែរ ដែលពុំទាន់មានការទាក់ទងនឹងអឺរុប ។



www.budinst.gov.kh www.elibraryofcambodia.org

## សេចក្តីសន្និដ្ឋាន ៖

ការសិក្សាវប្បធម៌នាសម័យមុនក្លិង្គចូលស្រុក បញ្ជាក់អោយយើងដឹងថា អតីតប្រទេសខ្មែរ ជាប្រទេសមួយដែលមានវ័យចំណាស់ជាងគេ ។ រីឯជនជាតិខ្មែរវិញក៏ជាជនជាតិមួយដែលគេបានកើតឡើងនៅក្នុងភូមិភាគឥណ្ឌូចិននេះដែរ ហើយជាជនជាតិចាស់ខុសពីជនជាតិនិងភាសាជាមួយខ្មែរ ជាហេតុដែលនាំអោយអ្នកប្រាជ្ញចាត់ទុកថា ខ្មែរស្ថិតក្នុងអំបូរ ខ្មែរ_មន ។

ចំពោះវិធីកម្លាយពាក្យនេះ ខ្មែរបានប្រើតាំងពីមុនសម័យអង្គរវត្តមកម្ល៉េះ ដូចជាសិលាចារឹកជាសក្ខីភាពស្រាប់ ។

<u>ឧទាហរណ៍</u> ៖

| | |
|---|---|
| ល្ងង_ ល្បួង | លេច_ បន្លេច_ រំលេច |
| តែង_ តំណែង | រួញ_ ជ្រួញ_ បង្រួញ |
| តាំង_ តំណាំង | លួច_ លម្លួច |
| ត្រូវ_ តម្រូវ | វែង_ លវែង_ ខ្វែង |
| ចុំ_ បន្ចុំ | អង្វែង_ ប្រវែង |
| ប្រែ_ បំប្រែ | សិត_ សសិត_ ស្និត |



www.budinst.gov.kh www.elibraryofcambodia.org

រួម- បង្រួម- សង្រួម      សិន- ខ្សិន

សំរួម      ដាច់- ស្តេច- សម្តេច

សូមបញ្ជាក់ថានៅក្នុងភូមិភាគអាស៊ីភាគអាគ្នេយ៍ មានតែខ្មែរមនទេ ដែលប្រើវិធីកម្លាយនេះ តាំងតែពីបុរាណកាលមក ។ នេះជាលក្ខណៈមួយពិសេសក្នុងភាសាសាស្ត្ររបស់អំបូរខ្មែរ-មន ។



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

ភាគទី ២

# សម័យ

# ប្រវត្តិសាស្ត្រ

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ភាគទី ២ៈ សម័យប្រវត្តិសាស្ត្រ

**សេចក្តីផ្តើមៈ**

ប្រវត្តិសាស្ត្រខ្មែរ មានវឌ្ឍនាការពោះដំហានទៅមុខជានិច្ច ។ យោងទៅលើឯកសារប្រវត្តិសាស្ត្រ យើងអាចដឹងពិតប្រាកដថា នាដើមសតវត្សទី១នៃគ្រិស្តសករាជ ជនជាតិខ្មែរដែលស្ថិតនៅតាមវាលទំនាប នៃដងទន្លេមេគង្គផ្នែកខាង ក្រោម ផ្នែកកណ្តាល រហូតដល់ផ្នែកធំនៃទន្លេចៅព្យា ព្រមទាំងជ្រោយម៉ាឡាកាក្នុងបច្ចុប្បន្ននេះ បានទទួលឥទ្ធិពលឥណ្ឌាយ៉ាងសកម្ម ។

ការផ្សព្វផ្សាយអារ្យធម៌ឥណ្ឌានេះហើយ ធ្វើអោយតំបន់ទាំងប៉ុន្មានខាងលើនេះ ដែលជាទីតាំងនៃជនជាតិខ្មែរ_មន តាំងតែពីសម័យមុនប្រវត្តិសាស្ត្រ ក្លាយជាចក្រភពមួយយ៉ាងធំ គឺអាណាចក្រភ្នំ រុងរឿងថ្កុំថ្កើងបំផុត នៅអាស៊ីភាគអាគ្នេយ៍ ដែលចិនហៅថា នគរ ហ្វូណន ។

ជាមួយគ្នានឹងការបង្កើតរដ្ឋខ្មែរដំបូងបង្អស់នេះ ជនជាតិខ្មែរនៃនគរភ្នំ ដែលពីបុព្វសម័យមានជំនឿលើឫទ្ធានុភាពរបស់ធម្មជាតិ ក្នុងសម័យនេះក៏បានស្គាល់នូវសាសនាថ្មីពីរទៀតដែលមានកំណើតនៅឥណ្ឌា គឺ ព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនា ។



www.budinst.gov.kh www.elibraryofcambodia.org

គួរកត់សំគាល់ថា សាសនាក្លិង្គទាំងពីរនេះ ចាក់ឫសគល់យ៉ាងជ្រៅក្នុងសង្គមខ្មែរ បន្ទាប់ពីរលាយក្នុងពុទ្ធខ្មែរ ហើយក៏ក្លាយទៅជាមូលដ្ឋាននៃអារ្យធម៌វប្បធម៌ខ្មែររហូតដល់សព្វថ្ងៃនេះ ។

១. ឥណ្ឌូបនីយ៍កម្មនៃនគរភ្នំ ដើមសតវត្សទី១នៃ គ.ស ៖

ដែនដីសុវណ្ណភូមិក្នុងបុរេប្រវត្តិ ពិតជាមានការទាក់ទងនឹងប្រទេសឥណ្ឌពុំខាន ពីព្រោះគេបានរកឃើញនូវវត្ថុបុរាណនៅសម័យនោះជាច្រើន ដូចជា ពូថៅ ថ្មអង្កាំថ្ម ។ល។ ដែលមានលក្ខណៈស្រដៀងនឹងឧបករណ៍ ដែលស្ថិតក្នុងស្ថានីយ៍បុរេនានានៃឥណ្ឌា ។ តែការទាក់ទងផ្នែកពាណិជ្ជកម្ម ត្រូវបង្កើតសកម្មភាពឡើង យ៉ាងខ្លាំងក្លាបំផុត នៅដើមសតវត្សទី១ នៃ គ.ស ។

សូមបញ្ជាក់ថា នាបុព្វសម័យក្នុងភូមិភាគឥណ្ឌូចិននេះ គេពុំទាន់ស្គាល់របៀបគ្រប់គ្រងតាមរបៀបរាជានិយម ឬសាធារណរដ្ឋនិយមដោយហេតុថា គេរស់នៅជាក្រុម១ ហើយមានមេកន្ទ្រាញដឹកនាំ ។ ម៉្យាងទៀតសុវណ្ណភូមិ ជាពិសេសប្រទេស ភូមានាសម័យបច្ចុប្បន្ននេះដែលមានព្រំប្រទល់ជាប់នឹងឥណ្ឌា ជាទីតាំងចាស់របស់ពួកខ្មែរ_មន ។

រហូតដល់សព្វថ្ងៃ ប្រទេសនេះក៏ដូចប្រទេសខ្មែរ_លាវនិងយួនខាងត្បូងនៅមានបក្សសម្ព័ន្ធ នៅតែពុំទាន់បានទទួលឥទ្ធិពលផ្នែកវប្បធម៌ឥណ្ឌានៅឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

### ការហូរចូលក្នុងជ្រោយសុវណ្ណភូមិ នៃវប្បធម៌-អារ្យធម៌ឥណ្ឌា៖

នាដើមសតវត្សទី១នៃគ្រិស្តសករាជ ដែនដីសុវណ្ណភូមិទាំងមូល ឬឧត្តរគោកធ្លក ឬទ្វីបនៃដើមម៉ៃសាក បើហៅតាមឥណ្ឌា "សាកទ្វីប" ព្រមទាំងឥណ្ឌូណេ. ស៊ី និងម៉ាឡេស៊ី បានទទួលនូវវប្បធម៌ឥណ្ឌាទាំងអស់ លើកលែងតែប្រទេសវៀត. ណាមខាងជើងដែលស្ថិតនៅក្រោមអានុភាពរបស់ចិន ។

គួរកត់សំគាល់ថា នៅដើមសតវត្សទី១នៃគ្រិស្តសករាជ ជនជាតិយួនដែលមានទីលំនៅដើម នៅក្វាន់តុង ឯចិនខាងត្បូង បានមករស់នៅ។យួនខាងជើងហើយ តែសម័យនោះគេពុំទាន់ដណ្តើបបានយួនកណ្តាល និងយួនខាងត្បូងពីចាមនៅឡើយទេ ។

តើការហូរចូលនៃវប្បធម៌-អារ្យធម៌ឥណ្ឌាក្នុងភូមិភាគនេះបណ្តាលមកពីបុព្វហេតុអ្វីខ្លះ ? ហើយតាមរបៀបណាដែរ ? ។ ម្យ៉ាងទៀតតើយើងមានឯកសារសារអ្វីសំរាប់សំអាង ជាភស្តុតាងចំពោះវត្តមាននៃជនជាតិឥណ្ឌានៅជ្រោយឥណ្ឌូចិន ?

### ១. បុព្វហេតុនៃការហូរចូលនៃវប្បធម៌ឥណ្ឌាក្នុងសុវណ្ណភូមិ៖

មានសម្មតិកម្មជាច្រើនស្តីពីបញ្ហានេះ តែសម្មតិកម្មដែលត្រឹមត្រូវជាងគេគឺការស្វែងរកនូវភោគទ្រព្យដូចជា មាស និងគ្រឿងទេស ពោលគឺប្រភពនៃការចាក់ឫសគល់នៃវប្បធម៌-អារ្យធម៌ឥណ្ឌានៅអាស៊ីអាគ្នេយ៍ បណ្តាលមកពីការធ្វើជំនួញ ។

ករណីនេះជំរុញអោយជនជាតិក្លិង្គ បានផ្សព្វផ្សាយវប្បធម៌ - អារ្យធម៌



www.budinst.gov.kh www.elibraryofcambodia.org

ឥណ្ឌាក្នុងទ្វីបអាស៊ី ត្រូវបានសម្រួលដោយការល្អួតលោស់ផ្នែកនាវាចរតាមសមុទ្រឥណ្ឌា ដោយគេចេះធ្វើសំពៅធំៗនៅដើមសតវត្សទី១នៃគ្រិស្តសករាជ ។

មិនតែប៉ុណ្ណោះសោត ជនជាតិឥណ្ឌាដែលបើកបរសំពៅ ថែមទាំងស្គាល់ភាពផ្លាស់គ្នានៃខ្យល់ មូស្សុងយ៉ាងច្បាស់លាស់ ពោលគឺខុសពីសម័យមុនៗដែលគេគ្រាន់តែធ្វើគមនាគមន៍តាមផ្លូវគោកប៉ុណ្ណោះ ។

ចាប់តាំងពីដើមសតវត្សទី១នៃគ្រិស្តសករាជមក សុវណ្ណភូមិបានក្លាយទៅជាទីប្រជុំនៃពួកឈ្មួញក្លិង្គ ក្រិក និងរ៉ូម៉ាំង ដែលមកទិញ គ្រឿងទេស កប្បាស មាស សំណប៉ាហាំង ភ្លុក ខ្មៅរមៀត ។ល។

ក្នុងការធ្វើដំណើរឆ្ពោះមកសុវណ្ណភូមិ ឈ្មួញទាំងអស់នោះត្រូវពឹងពាក់ទៅលើខ្យល់រដូវទាំងស្រុង ហើយត្រូវស្នាក់អាស្រ័យជាច្រើនខែផងក្នុងភូមិភាគនៃអាស៊ីអាគ្នេយ៍ ។ បើគេមកពីស្រុកក្លិង្គ គេត្រូវប្រើខ្យល់រដូវនារតី ។ ខ្យល់នេះចាប់ផ្ដើមមានឡើងពី ខែ មិថុនា ដល់ ខែ សីហា ។ គេក៏អាចប្រើខ្យល់រដូវឦសានដែលចាប់ផ្ដើមពីខែវិច្ឆិកា ទៅ ខែ មេសា ដើម្បីត្រឡប់ទៅស្រុកឥណ្ឌាវិញ ។ រួមសេចក្ដីមក ការប្រើសំពៅខ្យល់ " ក្លាយជាមធ្យោបាយមួយដ៏សំខាន់បំផុតសំរាប់ការរីកចំរើន និង ការដុះដាលនៃអាណាចក្រផ្សេងៗក្នុងឧបទ្វីបអាស៊ីអាគ្នេយ៍ ដែលស្ថិតនៅក្រោមឥទ្ធិពលសាសនា ដែលជាកត្តាបង្រួបបង្រួបប្រជាពលរដ្ឋទាំងអស់ជាធ្លុងមួយ ដោយគេប្រារព្ធជឿអាទិទេពដូចគ្នា ។

ប្រសិនបើយើងពិនិត្យ ផែនទីនៃប្រទេសឥណ្ឌា យើងអាចសំគាល់


www.budinst.gov.kh www.elibraryofcambodia.org

ឃើញថា កំពង់ផែធំៗរបស់ប្រទេសឥណ្ឌា ដូចជា តាម្លុក កានជីពូរ៉ា អមរាវតី ។ល។ ស្ថិតនៅតាមឆ្នេរសមុទ្រឥណ្ឌា ។ កាលពីដើមពួកឈ្មួញឥណ្ឌា គ្រាន់តែស្នាក់អាស្រ័យក្នុងទីស្នាក់ឬបន្ទាស់នានានៃកំពង់ផែប៉ុណ្ណោះ ។ យូរៗទៅគេក៏រៀបការ ជាមួយស្ត្រីខ្មែរ ដែលជាកត្តាមួយយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយអារ្យធម៌ឥណ្ឌា ។ តែទោះបីយ៉ាងណាក៏ដោយក៏អ្នកស្រុកនៅតែប្រកាន់ខ្ជាប់នូវចំនៀមទម្លាប់របស់ខ្លួនដែលមានពីបុព្វសម័យរហូតដល់សព្វថ្ងៃនេះ ដូចជាជំនឿរារក្ស អ្នកតា ការសែនព្រេនបុព្វបុរស ជំនឿទៅលើទឹក ភ្លៀង ខ្យល់ ។ល។

## ២. ការបង្កើតរដ្ឋខ្មែរដំបូង ៖ នគរភ្នំ ឬ " ហ្វូណន " ៖

**សេចក្តីផ្តើម ៖**

បើយើងពឹងផ្អែកទៅលើ ឯកសារប្រវត្តិសាស្ត្រចិននិងទៅលើខ្មែរ-មន បុរាណវត្ថុនានាដែលស្ថិតក្នុងភូមិភាគឥណ្ឌូចិនសព្វថ្ងៃនេះ យើងអាចសង្កេតឃើញថា ក្នុងកុលសម្ព័ន្ធខ្មែរ-មនទាំងអស់ មានតែជនជាតិខ្មែរ-មននិងចាមទេ ដែលបានបង្កើតរដ្ឋជាលើកដំបូងបង្អស់ គឺ ខ្មែរនិងចាម នៅដើមសតវត្សទី៧នៃគ្រិស្តសករាជ ពោលគឺនៅក្នុងកម្លុងក្រោយពីការបែកបាក់នគរភ្នំ ក្នុងជំនាន់នោះ ពេលនេះហើយដែលមនបែកពីខ្មែរ ហើយបានតាំងនគររបស់ខ្លួនឈ្មោះថា ទ្វារវតីនៅចុងសតវត្សទី ៦ ។

ម្យ៉ាងទៀតគេអាចសំគាល់ថាមានតែខ្មែរទេ ដែលមានចំនួនច្រើនជាងគេ ក្នុងកុលសម្ព័ន្ធខ្មែរ-មន ហើយដែលបានរក្សារដ្ឋ របស់ខ្លួនអោយបានគង់វង្ស



www.budinst.gov.kh www.elibraryofcambodia.org

ស្ថិតស្ថេររហូតដល់សព្វថ្ងៃនេះ ថ្វីត្បិតតែទំហំទឹកដីដ៏ធំធេងរបស់ខ្មែរបានត្រូវរួញស្វិតតូចជាងអតីតកាលយ៉ាងណាក៏ដោយ ។ រីឯនគរមននិងចាម បានរលត់សាបសូន្យវិនាសអន្តរាយក្រោមភ្លើងសង្គ្រាមដោយការបែកបាក់សាមគ្គីសាមគ្គានិងលទ្ធិវាតទីរបស់ពួកបរទេស ។

ចំពោះការបង្កើតរដ្ឋខ្មែរ គួរកត់សំគាល់ថា ដើម្បីទទួលនូវវប្បធម៌-អារ្យធម៌ឥណ្ឌាបាន ដែលជាមូលដ្ឋានជាតិ ទាល់តែបុព្វបុរសខ្មែរមានលទ្ធភាព និងសមត្ថភាពដ៏ពេញលេញបរិបូរណ៍ ពោលគឺមានប្រាជ្ញា ភាពឈ្លាសវៃ និងស្ថេរភាពគ្រប់វិស័យទាំងអស់ ។

**នគរភ្នំ : " ហ្វូណន " :**

តើរដ្ឋខ្មែរដំបូងបង្អស់ បានកើតឡើងយ៉ាងដូចម្តេចដែរ ឬតាមវិធីណានៅដើមសតវត្សទី ១ នៃគ្រិស្តសករាជ ? តើខ្មែរបុរាណបានខ្ចីអ្វីខ្លះពីឥណ្ឌា ដែលជាអរិយធម៌ប្រទេសក្នុងអតីតកាល ដើម្បីពោះឈានជើងចូលក្នុងសម័យប្រវត្តិសាស្ត្រ ដូចប្រទេសបារាំងសែស ក្នុងកម្លុងពេលជាមួយគ្នានោះ ដែលបានទទួលវប្បធម៌ពីពួករ៉ូម៉ាំង ? ។

មុននឹងលើកបញ្ហាបង្កើតរដ្ឋខ្មែរ គឺនគរភ្នំមកវែកញែក តាមរបៀបវិ-ទ្យាសាស្ត្រ គួរយើងរំលឹកឡើងវិញថា មុនគ្រិស្តសករាជជនជាតិខ្មែរ-មនមានវប្បធម៌អារ្យធម៌របស់យើងនាសម័យមុនក្លិងចូលស្រុកបានបង្ហាញជាភស្តុតាងស្រាប់ ។



www.budinst.gov.kh www.elibraryofcambodia.org

ហេតុដែលមានឧកុលសម្ព័ន្ធមន_ខ្មែរ ដូចជា កួយ ព័រ ស្អូច ស្មៀង ខា ព្នង គ្រឹង ទ្រុំ (*នៅ ភូមា*) ដែលរស់តាមចុងកាត់មាត់ញក ឬតាមព្រៃភ្នំ ហើយពុំទាន់បានទទួលអានុភាពវប្បធម៌ឥណ្ឌានៅឡើយ អាចបំភ្លឺអោយឃើញនូវលក្ខណៈវប្បធម៌ខ្លះ ដូចជាការរស់នៅរបស់សង្គមខ្មែរនាសម័យបុរេប្រវត្តិសាស្ត្រ ។

ម្យ៉ាងទៀត គេអាចអះអាងតាមលោក George Coedès អ្នកប្រវត្តិសាស្ត្រវិទូបារាំងសែសដ៏ល្បីល្បាញម្នាក់ថា " ខ្មែរគឺព្នង " ឬ " ខ្មែរដើម " "*ខ្មែរលើ*" គ្រាន់តែបានទទួលវប្បធម៌ពីឥណ្ឌាប៉ុណ្ណោះ " le Cambodgien est un Pnong hindouisé " ។

រីឯជនជាតិមនវិញក៏ដូច្នោះដែរ ។ ព្រោះថា មុនក្លិង្គចូលស្រុក ពុំទាន់មានការបែងចែកថាអ្វីជាមន អ្វីជាខ្មែរនៅឡើយ ហើយរហូតដល់សព្វថ្ងៃនេះ ថ្វីត្បិតតែមនបានបែកឆ្ងាយពីខ្មែរប្រមាណជិត ១.៥០០ ឆ្នាំ មកហើយក៏ដោយ ក៏ភាសាមនវប្បធម៌មន ទំនៀមទម្លាប់មនខ្លះនៅតែមានទ្រង់ទ្រាយដូចខ្មែរដដែល ។ ដូច្នេះគេអាចសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ៖ នាបុព្វសម័យមន និងខ្មែរជាពូជសាសន៍តែមួយ ។ ចំពោះបញ្ហាដ៏សំខាន់នេះ លោកសាស្ត្រាចារ្យ **កេង វ៉ាន់សាក់** បានបញ្ជាក់យើងថា " ដោយហេតុដែលនាំអោយជាតិមួយហៅថា *មន* ហើយជាតិមួយទៀតហៅថា*ខ្មែរ* គឺមកអំពីការរស់នៅតាមទីកន្លែងប្លែកគ្នា ដែលជាហេតុនាំអោយមានឈ្មោះប្លែកគ្នា" ។ ឧទាហរណ៍ ៖ ដូចជានៅស្រុកខ្មែរយើង ជាតិនៅតែជនជាតិខ្មែរ_មនដដែល " លោក



www.budinst.gov.kh www.elibraryofcambodia.org

*សំដៅពួកខ្មែរភ្នំ* " ប៉ុន្តែទីកន្លែងរស់នៅប្លែកគ្នា មួយនៅលើភ្នំ " *ខ្មែរលើ* " មួយតាមជ្រោយសមុទ្រ ឬមួយនៅតាមជនបទឆ្ងាយៗ មានទំនៀមទម្លាប់មិនខុសគ្នាទេ គ្រាន់តែមួយកាន់ព្រះពុទ្ធសាសនា មួយកាន់សាសនាមួយទៀត "*ជំនឿលើធម្មជាតិ*" ក៏មានឈ្មោះហៅថា ព្នង ហៅថា ជង ហៅថា កួយ ហៅថា ស្ទួច ហៅថា ព័រ ទៅវិញ ។ ប៉ុន្តែពួកទាំងអស់សុទ្ធតែជាជនជាតិខ្មែរដូចយើងដែរ " *ដែលពុំទាន់ស្ថិតក្រោមអានុភាពវប្បធម៌ អារ្យធម៌បរទេសនៅឡើយ* " ។

រួមសេចក្តីមក ទស្សនៈខាងលើនេះមានន័យត្រឹមត្រូវហើយទូលំទូលាយណាស់ ព្រោះវាមិនគ្រាន់តែសំដៅខ្មែរនិងមន ដែលបានក្លាយទៅជាអារ្យបុគ្គលក្រោមឥទ្ធិពលវប្បធម៌របស់ឥណ្ឌាឬចិនទេ ថែមទាំងបញ្ចូលនូវអំបូរខ្មែរ_មន ទាំងអស់ ដែលមានការរស់នៅតាមរបៀបចាស់បុរាណទៀតផង ។ ម្យ៉ាងទៀតការសិក្សារបស់អ្នកប្រាជ្ញជាច្រើន ដូចជាសាស្ត្រាចារ្យ L. Brumpt លើឈាមក្រហម Hémoglobine E នៃពួកខ្មែរនិងខ្មែរលើដែលពុំទាន់ទទួលអានុភាពវប្បធម៌ឥណ្ឌានៅឡើយ ក៏អាចឆ្លុះអោយឃើញនូវភាពត្រឹមត្រូវរបស់គំនិតខាងលើនេះដែរ ។

គួរយើងបញ្ជាក់ថា មុនពេលដែលឥណ្ឌាបានធ្វើវិត្តារកម្មមកដល់ទឹកដីនានារបស់ពួកខ្មែរ_មន ខ្មែរមិនទាន់បង្កើតរដ្ឋឬព្រះរាជាណាចក្រនៅឡើយទេ ។ ម្យ៉ាងទៀតការបង្កើតរដ្ឋជាការមួយវែងឆ្ងាយ តែយើងអាចអធិប្បាយដោយសង្ខេប ដោយយកតែគោលៗដូចខាងក្រោមនេះ :

ដូចបានពោលមកហើយ នាដើមសតវត្សទី ១នៃគ្រិស្តសករាជ វប្បធម៌



www.budinst.gov.kh www.elibraryofcambodia.org

•

អារ្យធម៌ឥណ្ឌាបានហូរចូលយ៉ាងសកម្ម តាមរយៈអ្នកជំនួញឥណ្ឌា ក្នុងជ្រោយឥណ្ឌូចិន ដែលហៅថា សុវណ្ណភូមិ *"ដែនមាស"* ។ តាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញ G.Coedès ការហូរចូលនៃ វប្បធម៌-អារ្យធម៌ក្លិង្គ បណ្តាលអោយមានការបង្កើតរដ្ឋជាច្រើន ជាពិសេសរដ្ឋខ្មែរក្នុងភូមិភាគនេះ ។ គឺនៅក្នុងពេលជាមួយគ្នា និងការរស់នៅជាមួយខ្មែរ ក្លិង្គបានសាបព្រោះផ្សព្វផ្សាយវប្បធម៌-អារ្យធម៌របស់ខ្លួន ។ ជាហេតុធ្វើអោយសង្គមខ្មែរ ទទួលសន្ទុះវប្បធម៌ថ្មីមួយ គឺការខ្ចីនូវផ្នែកវប្បធម៌-អារ្យធម៌នានា ដែលខ្មែរខ្វះពោលគឺរបបនយោបាយ ដូចជាការរៀបចំផ្នែកសង្គមកិច្ច សេដ្ឋកិច្ច នយោបាយ សាសនា ។ល។ ដែលជាមូលដ្ឋាននៃរដ្ឋខ្មែរដំបូងបង្អស់ ។

តាមពិតក្នុងការបង្កើតរដ្ឋ ឬនគរ អ្នកដឹកនាំខ្មែរនាដើមសតវត្សទី១ ត្រូវការនូវមនោគមវិជ្ជា រាជានិយមដែលមានស្តេចចក្រពត្រ Idéologie monarchique à caractère cakravatin ដែលខ្លួនខ្វះសំរាប់បង្រួមកូនសង្គមតូចៗ អោយក្លាយទៅជាចក្រភពដែលមាន ព្រះចៅអធិរាជដឹកនាំគឺ នគរភ្នំ ។ ផ្ទុយពីពួកក្រិក ឬរ៉ូម៉ាំងដែលបានធ្វើសង្គ្រាមលុកលុយ ឈ្លានពានកាន់កាប់ប្រទេសជិតខាង ដើម្បីកេងប្រវ័ញ្ចនូវភោគទ្រព្យ និងពង្រីកទឹកដីអោយកើតជាចក្រភព ។ ចម្បាំងនាដើមសតវត្សក្នុងភូមិភាគនេះ ជាចម្បាំងរវាងខ្មែរ និង ខ្មែរ រវាងអ្នកដឹកនាំ និង អ្នកដឹកនាំ ធ្វើឡើងដើម្បីបង្រួបបង្រួមស្រុកទេស ។ ព្រោះថាមាននគរភ្នំដែលជាអាណាចក្រមួយយ៉ាងធំធេងបានកើតឡើងដោយការផ្តុំគ្នានៃកុលសម្ព័ន្ធ ខ្មែរ-មន នានា ឬកូនសង្គមតូចៗ ទូទាំងផ្ទៃឥណ្ឌូចិនដោយមានអំណាចកណ្តាលជា ត្រើះឬស្សីរ ។ ដូច្នេះបក្សសម្ព័ន្ធទាំងអស់នោះ



www.budinst.gov.kh www.elibraryofcambodia.org

សុទ្ធតែជាបងប្អូន ជាលោហិតជាមួយគ្នា ដោយបេតុំរវាងទៅលើសិរីភោគវ៉ារីក តែមាន ការប្រយុទ្ធបង្ហូរឈាម ប្រម្ទូស្តវ៉ាយេនិងគ្នាជារឿយៗ ដើម្បីរាជសម្បត្តិ ឬអំណាច កណ្តាល ។ ចំពោះបញ្ហានេះ អ្នកទូតចិនដែលបានចូលមកនគរភ្នំនៅសតវត្សទី៣នៃ គ្រឹស្តសករាជបានកត់សម្គាល់ថា ៖

ដើមឡើយហ្វូណនមានទំហំ ៣.០០០ លី ហើយក្រោយមកក៏ពង្រីកធំ ដល់ ៥.០០០ ឬ ៦.០០០ លី ។

## ព្រះរាជវង្សានុវង្សខ្មែរមុនដំបូង

តាមការកំណត់របស់រាជទូតចិនឈ្មោះ កាំង ថៃ ដែលបានមកទស្សនានគរភ្នំ នៅពាក់កណ្តាលសតវត្សទី៣ នៅដើមសតវត្សទី១នៃគ្រឹស្តសករាជ មានជនជាតិព្រា-ហ្មណ៍ម្នាក់ឈ្មោះ ហ៊ុន ទៀន "*កោណ្ឌញ្ញ*" បានធ្វើដំណើរពីប្រទេសឥណ្ឌា ឬពី ជ្រោយ ម៉ាឡាយូ ឬក៏ពី "*កោះខាងត្បូង*" មកកាន់ប្រទេសភ្នំ ។

ដោយសំអាងទៅលើព្រះរាជពង្សាវតារខ្មែរ ស៊ីពីពួកថ្វាព្រាហ្មណ៍ ដោយសំដៅ លើពួកព្រាហ្មណ៍ឥណ្ឌានៃកោះជ្វា យើងអាចសន្និដ្ឋានថាកោះភាគខាងត្បូង ពណ៌នា ដោយលោក កាំង ថៃ គឺជាកោះជ្វានៃប្រទេសឥណ្ឌូណេស៊ី ។ សរុបសេចក្តីមក ព្រះបាទ ហ៊ុន ទៀន ពិតជាមកដល់ស្រុកខ្មែរតាមរយៈកោះនេះ ឬ ជ្រោយម៉ាឡាយូ ។

ចំពោះការមកកាន់ប្រទេសភ្នំនេះ រាជទូតខាងលើនេះ បានកត់ត្រាថា ៖ យប់



www.budinst.gov.kh www.elibraryofcambodia.org

មួយព្រះបាទ ហ៊ុន ទៀន បានយល់សប្តិឃើញទេវតាដែលបីបាច់ថែរក្សាព្រះអង្គធ្វើអំណោយធ្នូចិត្តមួយ ហើយបញ្ជាអោយព្រះអង្គឡើងជិះសំពៅជិន្នូញមួយយ៉ាងធំ ។

លុះព្រឹកឡើង ព្រះអង្គក៏ស្តេចយាងទៅកាន់ទេវស្ថាន ដើម្បីធ្វើសក្ការៈបូជា ស្រាប់តែឃើញធ្នូចិត្តដូចសុបិន្តមែន ។ បន្ទាប់ពីនេះ ព្រះអង្គក៏ធ្វើដំណើរតាមសមុទ្រមកកាន់រាជអាណាចក្រភ្នំ តាមបទបញ្ជារបស់ទេវតា ។

មកដល់ស្រុកនគរភ្នំ ព្រះអង្គត្រូវធើបប្រយុទ្ធជាមួយរាជនីរដ្ឋនេះគឺនាង លិវ យី តែដោយឫទ្ធានុភាពរបស់ធ្នូជ័យព្រះអង្គ ក៏បានទទួលជ័យជំនះទៅលើព្រះនាង លិវ យី ដែលជាម្ចាស់ស្រុក ក្រោយពីបានបាញ់ធ្លាយសំពៅរបស់ព្រះនាងពីម្ខាងទៅម្ខាង ។ ដូច្នេះព្រះនាងក៏សុខចិត្តចុះចាញ់និងមហិទ្ធិឫទ្ធិរបស់ព្រះបាទ ហ៊ុន ទៀន ហើយក៏ទទួលព្រះអង្គធ្វើជាព្រះស្វាមី ។

គួររំលឹកឡើងវិញថា ចាស់ៗនៃ ភូមិពួន ស្រុកសង្កៈ ខេត្ត ស៊ុរិន្ទ្រ ដែលមានពូជពង្សតមកពីសម័យនគរភ្នំមកនៅចងចាំនៅឡើយ នូវការមកដល់នៃព្រាហ្មណ៍ក្លិង្គនេះ ។ គេមានសេចក្តីដំណាលដូចតទៅនេះ ៖

*ពីដើមស្រុកភូមិគេ គ្រប់គ្រងដោយមេគន្លងញស្រី ម្នាក់មានឈ្មោះថា នាងដោះធំ ដែលមានរូបឆោមល្អក្រៃលែង ។ នាងដោះធំនេះឈ្លាសវៃអង់អាចក្លាហានផុតលេខ ។ ឧទាហរណ៍ ៖ ព្រះនាងបានឈ្នះពួកប្រុសៗទាំងអស់ក្នុងការប្រលងប្រជែងសាងប្រាសាទទីមួយគឺ ប្រាសាទភូមិពួន នៅគង់វង្សរហូតដល់សព្វថ្ងៃ ។ តែអកុសលថ្ងៃមួយព្រះនាងត្រូវចាញ់បារមីធ្នូរបស់ព្រាហ្មណ៍ម្នាក់ដែលជិះសេះមកពីទិសខាងត្បូង ។*



www.budinst.gov.kh www.elibraryofcambodia.org

ក្រោយពីចាញ់ល្បែងឈ្នះ ព្រះនាងដោះធំ ដោយព្រះអង្គបានបាញ់បំផ្លាញបំបាក់កំពូលប្រាសាទភ្នំមិត្តនេះ ព្រះអង្គក៏ចាប់យកនាងដាក់លើសេះបរបាត់ទៅ ។ ចាស់ៗនៃភូមិស្រុកនេះបានបន្ថែមទៀតថា ៖ ដោយហេតុនេះហើយបានជាស្ត្រីភេទចុះទន់ខ្សោយចាប់ពីពេលនោះរហូតមកដល់បច្ចុប្បន្ននេះ ។ តែព្រះនាងបានផ្តាំថា ថ្ងៃណាព្រះនាងត្រឡប់មកវិញ ស្រុកនេះនឹងរុងរឿងដូចដើមវិញ ។

តាមលោក Bernard-Philippe Groslierការចូនកសាងប្រាសាទនេះត្រូវប្រព្រឹត្ត ឡើងនៅដើមសតវត្សទី៦ នៃគ្រិស្តសករាជ ។

ព្រឹត្តិការខាងលើនេះ ក៏គេត្រូវរំលឹកឡើងនៅលើផ្ទាំងសិលាចារឹកចាមមួយផ្ទាំង គឺសិលាចារឹកមុីសើង ។ ឯកសារនេះដែលត្រូវចារឡើង នៅឆ្នាំ៦៥៨ អោយដឹងថា ព្រាហ្មណ៍កោណ្ឌញ្ញ បានទទួលលំពែងមួយពីព្រាហ្មណ៍ អស្វត្ថាម័ន ហើយក៏ចួយអាវុធនោះ ដើម្បីរកកន្លែងស្ថាបនារាជធានីថ្មី ។ បន្ទាប់ពីនេះ ព្រះអង្គក៏រៀបរាជាភិសេកនឹងព្រះនាងសោមា ដែលជាព្រះរាជបុត្រីរបស់ស្តេចភុជង្គនាគ ។ ការរួមសង្វាស់រវាងព្រះបាទកោណ្ឌញ្ញ និងព្រះនាងសោមាបង្កើតបានជារាជវង្សសោមវង្ស ។ ប្រវត្តិរបស់ព្រះបាទកោណ្ឌញ្ញនិងព្រះនាងសោមាដដែលនេះ ក៏ត្រូវបានគេចារទុកដែរក្នុងសិលាចារឹកខ្មែរមួយនៅសតវត្សទី១០ គឺសិលាចារឹក បក្សីចាំក្រុង ។

រីឯរឿងនិទានខ្មែរបុរាណ ដែលចារនៅលើសិលាស្លឹករឹត គេថា ព្រះថោង នាងនាគ ជាបុព្វបុរសរបស់ខ្មែរទៅវិញ ។



www.budinst.gov.kh www.elibraryofcambodia.org

ហេតុចិនបន្តិចក៏ដោយ តែសាច់រឿងនៅតែដដែល គឺការមកដល់នៃព្រាហ្មណ៍ក្លឹង្គនេះ និងការរួមសង្វាស់ជាមួយអ្នកស្រុកក្រោយចម្បាំង បានធ្វើអោយមានការបន្តព្រះរាជវង្សានុវង្សនៃរាជក្សត្រប្រទេសកម្ពុជាចាប់តាំងពីសម័យនោះមក ។ ម៉្យាងទៀតការមកដល់នៃ ព្រះបាទ *ហ៊ុន ទៀន* ក្នុងតំបន់នៃពួកខ្មែរ_មន ជាជំហានទី១នាំមកនូវភាពរុងរឿង ។ ពេលគឺនាសម័យមុនក្លឹង្គចូលស្រុក មេបាបុរសខ្មែរគ្រាន់តែជាមេកន្ទ្រាញគ្រប់គ្រងនៅលើស្រុកនីមួយ១ ឥឡូវនេះប្រកបដោយមហិទ្ធិឫទ្ធិខ្លាំងក្លាអស្ចារ្យ ដោយមនោគមវិជ្ជាឥណ្ឌា ដែលបង្រួបបង្រួមស្រុកភូមិអោយក្លាយជាអាណាចក្រ ហើយពីអាណាចក្រទៅជាចក្រភព ។

ពង្សាវតារ *លាង* បានអោយដឹងថា ព្រះបាទ កោណ្ឌញ្ញមានព្រះរាជបុត្រមួយព្រះអង្គ សោយរាជ្យនៅលើភូមិភាគមួយយ៉ាងធំធេង ដោយមានក្រុងធំ១ *"ព្រាំពីរ"* ។ ប្រភពឯកសារនេះពោលទៀតថា ក្នុងនគរខ្មែរជំនាន់នោះ មាននាម៉ឺន មន្ត្រី ព្រមទាំងព្រះរាជវាំង ។ រីឯផ្នែកសង្គមវិញ មានវណ្ណៈ៤ ។ ក្នុងចំណោមស្តេចសោយរាជ្យតពីព្រះបាទកោណ្ឌញ្ញ គេដឹងថាមានស្តេចមួយព្រះអង្គ ព្រះនាមព្រះបាទ *ហ៊ុន ព៉ានហួង*

ពោរពេញទៅដោយល្បិចកលផ្នែកយុទ្ធសាស្ត្រ មុននឹងធ្វើសង្គ្រាមបង្ក្រាបបច្ចាមិត្ត ព្រះអង្គរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីបំបាក់បំបែកសាមគ្គីធម៌សត្រូវ ហើយក្រោយពីច្បាំងឈ្នះ ព្រះអង្គតាំងព្រះរាជបុត្ររបស់ព្រះអង្គឡើងសោយរាជ្យជំនួសវិញ ។

ក្នុងរជ្ជកាលរបស់ព្រះអង្គ ព្រះអង្គបានបង្ក្រាប នគរ១០ ដូចជា ទៀនស៊ុន



www.budinst.gov.kh www.elibraryofcambodia.org

គិវទ្ធគុន កៀវគេ ចាញ់ស្វ័ន ឈិនលិន "*សុវណ្ណភូមិ*" ស៊្វិន្ន ស៊្វិយ៉ាញ់ ។ល។ ម្យ៉ាងទៀត តាមឯកសារនៃរាជវង្សានុវង្សចិនខាងត្បូង យើងដឹងថាទឹកដីខ្មែរធំជាងមុន ហើយមានប្រវែងពី ២.៨៨០ គីឡូម៉ែត្រ ដល់ ៣.៤៥៦ គីឡូម៉ែត្រ ។

ដោយការបង្រួបបង្រួមរបស់ព្រះអង្គ អាណាចក្រខ្មែរ ដ៏អាន់ដ៏រុងរឿងនោះ លាតសន្ធឹងលើភូមិភាគខាងក្រោមទន្លេមេគង្គ ភូមិភាគខាងជើងបឹងទន្លេសាប តំបន់ខាងកើតចាប់តាំងពីវាលចំនាបនៃដងទន្លេមេគង្គ ផ្នែកកណ្តាលរហូតដល់តំបន់ខាងជើងទន្លេ ចៅប្រែន "*ចៅព្រះយ៉ា*" ដែនដីតំបន់ជ្រោយម៉ាឡាយូ រហូតដល់ឈូងសមុទ្របន់ដុង ។

ស្តេចអង្គនេះ សោយរាជ្យនៅនគរភ្នំ ហើយបានចូលទិវង្គត ពេលដែលព្រះ-អង្គមានព្រះជន្មាយុជាង ៩០ ព្រះវស្សា ។

បើយើងពិនិត្យឯកសារចិនដ៏នាន់នោះ យើងឃើញថាសម័យនោះ ជាសម័យអសន្តិសុខ ។ ក្រោយពីព្រះបាទ ហ៊ុន ប៉ាន់ហួង ត្រូវឡើងសោយរាជ្យសម្បត្តិ តែដោយមានការបះបោរ ពីសំណាក់អ្នកគ្រប់គ្រងជាច្រើន ព្រះអង្គក៏ប្រគល់អំណាចកណ្តាលអោយមេទ័ពម្នាក់ឈ្មោះ ហ្វាន់ ឆេម៉ាន់ ដែលខ្លាំងពូកែ ។

ក្រោយពីបានសោយរាជ្យបាន ៣ ឆ្នាំ ព្រះបាទ ប៉ាន ប៉ាន ក៏ចូលសុវណ្ណគត ហើយប្រជារាស្ត្រនៃនគរភ្នំក៏ព្រមព្រៀងគ្នា លើកទ័ពដ៏ខ្លាំងពូកែ ហ្វាន់ ឆេម៉ាន់ ខាងលើនេះអោយឡើងសោយរាជ្យនៅនគរភ្នំ ។ ដោយអំណាចសេចក្តីក្លាហាន និងភាពស្ទាត់ជំនាញក្នុងវិធីយុទ្ធសាស្ត្រ ព្រះបាទ ហ្វាន់ ឆេម៉ាន់ ឬស្រីមារៈ តាមសិលា



www.budinst.gov.kh www.elibraryofcambodia.org

•

ចារឹកវ៉ូកាញ់ នៅកម្ពុជាក្រោម បានជាព្រះចៅចិនតាំងព្រះនាមជា *មហារាជ-ចិនហ្វាណន* ។ ក្នុងការចម្បាំង និងកុលសម្ព័ន្ធតូចៗនានា ដែលស្ថិតនៅ ជ្រោយម៉ា-ឡាកា ឬប្រទេសឥណ្ឌូណេស៊ី ព្រះអង្គប្រើនាវាចម្បាំងជាច្រើន យ៉ាងណាមិញ ព្រះអង្គក៏មានសំពៅធំៗដែរ ដើម្បីធ្វើជំនួញសំរាប់ទាក់ទងតាមផ្លូវទូត និងបរទេស មានចិន ឥណ្ឌា ជាដើម ។

នៅពាក់កណ្ដាលទសវត្សទី២ នៃសតវត្សទី៣ នៃគ្រិស្តសករាជ ព្រះបាទ ហ្វាន គេម៉ាន់ ឬស្រីមេរះ ចូលទិវង្គត ។ ចំពោះមរណៈភាពរបស់ព្រះបាទហ្វាន់ គេម៉ាន់ កំណត់ហេតុចិនមិនបានពោលថា ព្រះអង្គសោយទិវង្គតនៅចន្លោះឆ្នាំ ២២៥ និង២៥០ នៃគ្រិស្តសករាជ ហើយនៅក្នុងកម្លុងពេលនោះព្រះបាទ ហ្វាន់ ស៊ីយុន ឡើងសោយរាជ្យ ។

តាមសាស្ត្រាចារ្យ George Coedès ព្រះអង្គហ្វាន់ គេម៉ាន់ សោយទិវ-ង្គត ក្នុងពេលដែលព្រះអង្គ លើកទ័ពទៅវាយទីក្រុងកុលសម្ព័ន្ធ គិន លិន ត្រូវនឹងសុវណ្ណភូមិ ដែលស្ថិតនៅប្រទេសភូមាខាងត្បូង ។ រាជបល្ល័ង្កក៏ធ្លាក់ក្នុងកណ្ដាប់ដៃរបស់ព្រះបាទ ហ្វាន់ ឈិនម៉េន ។ តែមេទ័ព ហ្វាន់ ឆាន់ ដែលជាក្មួយរបស់ព្រះបាទ ហ្វាន់ ស៊ិម៉ាន់ បះបោឡើង ហើយធ្វើឃាត ហ្វាន់ ឈិនម៉េន ។

ប្រភពឯកសារចិនបានអោយដឹងទៀតថា នៅក្នុងសម័យនោះនគរភ្នំមានការទាក់ទង ជាអន្តរជាតិយ៉ាងតត្រឹតតគ្រេង តាមផ្លូវទូត និងពាណិជ្ជកម្ម ជាមួយឥណ្ឌូនិង



www.budinst.gov.kh www.elibraryofcambodia.org

ចិន ។ គួរកត់ត្រាថាក្នុងរាជ្យរបស់ព្រះបាទ ហ្វាន់ ឆាន់ នគរភ្នំមានការទាក់ទងនិងរាជវង្សមុរុណ្ឌនៃប្រទេសឥណ្ឌា ហើយមានការបញ្ជូនទូតខ្មែរជាលើកដំបូងបង្អស់ នៅស្រុកចិន ក្នុងសម័យ សាមកុក ។ ឯកសារចិនបានបន្ថែមទៀតថា រាជវង្សមុរុណ្ឌបានផ្ញើពូជសេះ អាជីនេយ្យចំនួន ៤ មានតម្លៃជាអនេក ថ្វាយព្រះបាទ ហ្វាន់ ឆាន់ ព្រមទាំងជនជាតិឥណ្ឌាម្នាក់ឈ្មោះ ឆេង សុង ដែលជាអ្នកនាំសេះទាំងអស់នោះផង ។

ចំណែកការទាក់ទងរវាងខ្មែរនិងចិន គួរកត់ត្រាថា ក្នុងសម័យនោះព្រះរាជវង្សវ៉ូ អាណាចក្រចិន ស្ថិតនៅភាគខាងត្បូងមានបុគ្គលម្នាក់ បានធ្វើសេចក្ដី អធិប្បាយថ្វាយព្រះបាទ ហ្វាន់ ឆាន់ អំពីវឌ្ឍនភាពដ៏ត្រចះត្រចង់នៃប្រទេសឥណ្ឌា ។ ក្រោយពីនោះព្រះអង្គក៏បានបញ្ជូនប្រតិភូទូត ដែលដឹកនាំដោយព្រះញាតិវង្សរបស់ព្រះអង្គឈ្មោះ ស៊ូវ ទៅកាន់ប្រទេសឥណ្ឌា ។ ប្រតិភូទូតរូបនេះបានចុះសំពៅនៅកំពង់ផែ តួវគីវឡី ប្រហែលត្រូវនឹងទីក្រុង តក្កោល ។

ព្រឹត្តិការណ៍ខាងលើនេះ សរអោយឃើញថា អាណាចក្រខ្មែរក្នុងខណៈនោះមានឈ្មោះពោះសម្លេងរហូតដល់មហាសមុទ្រឥណ្ឌា ។

តាមការស្រាវជ្រាវរបស់លោក G. Coedes ព្រះបាទ ហ្វាន់ ឆាន់ នេះប្រហែលជាអ្នកចារសិលាចារឹក វ៉ូកាញ់ ជាភាសាសំស្ក្រឹត ។ គួរបញ្ជាក់ត្រង់នេះថា សិលាចារឹកនេះអោយដឹងថា ព្រះបាទ ហ្វាន់ ឆាន់ ជាកូនរបស់បងស្រីរបស់ ព្រះបាទ ហ្វាន់ ឆេម៉ាន់ ឬស្រីមារៈ ដូច្នេះព្រះបាទ ហ្វាន់ ឆាន់ អាចអះអាងថា ព្រះអង្គជាក្មួយរបស់ព្រះបាទ ហ្វាន់ ឆេម៉ាន់ ។



www.budinst.gov.kh www.elibraryofcambodia.org

តាមព្រះរាជពង្សាវតារ សាមកុក គឺព្រះអង្គដដែល ដែលបានបញ្ជូនទូតខ្មែរទៅកាន់ស្រុកចិននៅឆ្នាំ ២៤៣ ដោយមានជង្វាយជាវង់តន្ត្រី ព្រមទាំងរបស់របរនៃនគរភ្នំ ។

ស្ដេចដែលបានសោយរាជ្យពីព្រះអង្គគឺ ព្រះបាទហ្វាន់ ស៊ីយុន ដែលជាអ្នកជ្រែករាជ្យ ។ ឯកសារចិនបានបំភ្លឺថា ព្រះអង្គបានសោយរាជ្យ ក្រោយពីបានធ្វើឃាតព្រះរាជបុត្រមួយព្រះអង្គ របស់ព្រះបាទ ហ្វាន់ គេម៉ាន់ ។

យើងអាចដឹងពតិមានខ្លះៗ ដែលទាក់ទងនិងព្រះរាជបុត្ររបស់

ក្នុងការវាយប្រហារ ដើម្បីដណ្ដើមអំណាចពីនគរភ្នំ ព្រះបាទ *ភវវរ្ម័ន "ទី១"* បានទទួលជំនួយពីព្រះអនុជរបស់ព្រះអង្គដែលព្រះនាមថា ចិត្រ សេន ប្រកបដោយសេចក្ដីអង់អាចយ៉ាងសម្បើម ។

យើងដឹងថា រាជទូតខ្មែរចុងក្រោយបង្អស់របស់ព្រះបាទ រុទ្រវរ្ម័នដែលបានទៅចិនបានប្រព្រឹត្តឡើងនៅឆ្នាំ ៥៣៩ ។ រីឯកំណត់ហេតុចិននៃរាជវង្ស តាំងវិញនៅតែពិពណ៌នាពីរាជទូតខ្មែរដទៃៗទៀតរហូតដល់ពាក់កណ្ដាលសតវត្សទី៧ ។ ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ឯកសារចិនបានកត់សម្គាល់ថា មានការប្រែប្រួលយ៉ាងធំណាំក្នុងនគរខ្មែរ ។

តាមឯកសារចិន មានការផ្លាស់រាជធានីខ្មែរ *"ស្ដេចមានរាជធានីនៅទីក្រុងតូមូ"* ។ ស្រាប់តែដោយមិនដឹងទុកជាមុន ទីក្រុងនេះត្រូវទទួលវិនាសកម្ម ហើយស្ដេចក៏ភៀសខ្លួនទៅភាគខាងត្បូង នៃប្រទេស នៅទីក្រុង ណាភូណា ។ ឯកសារចិនស្ដីពីប្រទេសចេនឡា ដែលរាយប៉ុច្រើនជាងគេ គឺពង្សាវតារនៃរាជវង្ស *"ស៊ូ"* ប្រទេស



www.budinst.gov.kh www.elibraryofcambodia.org

ចេនឡាស្ថិតនៅទិសនិរតី នៃប្រទេស លិន យី ។ ដើមឡើយជាព្រះរាជអាណាចក្រចំណុះនៃនគរភ្នំ ត្រកូលនៃរាជវង្សានុវង្សគឺក្សត្រ ព្រះនាមរបស់ព្រះអង្គគឺ ចិត្រ សេន ។ អំណាចបុព្វបុរសរបស់ព្រះអង្គ បានលាតសន្ធឹងបន្តិចម្តងៗទូទាំងប្រទេស ។ ព្រះអង្គក៏ដណ្តើមនគរភ្នំ ហើយធ្វើជាស្រុកចំណុះ ។

យើងអាចដឹងទីតាំងរបស់ចេនឡាយ៉ាងច្បាស់ ដោយសារពង្សាវតារនៃ រាជវង្សស៊ុយមុនឆ្នាំ ៥៨៩ នៃគ្រិស្តសករាជ ពោលគឺមុនការដណ្តើមបាន នគរភ្នំ ទាំងមូលដោយចេនឡាដឹងការផ្លាស់រាជធានីទៅកាន់ភូមិភាគខាងត្បូង ។ គួរបញ្ជាក់ថានគរចេនឡា ស្ថិតនៅត្រង់ផ្នែកខាងត្បូងប្រទេស លាវ តំបន់ពាសាក់ ដោយមានរាជធានីឈ្មោះ ភវៈបុរៈ នៅត្រង់ម្តុំប្រាសាទខ្មែរបុរាណ វត្ត ភូ ប្រទេស លាវសព្វថ្ងៃ ។

តាមសិលាចារឹកបក្សីចាំក្រុងនាសតវត្សទី១០ ដែលទាក់ទងពីព្រះរាជវង្សានុវង្សខ្មែរ ដែលសោយរាជ្យនៅនគរភ្នំ យើងអាចដឹងថា ព្រះបាទ ភវវរ្ម័ន ជាចៅរបស់ស្តេចចក្រវាលដែលជាស្តេចនៃនគរភ្នំ ។

ម៉្យាងទៀតយើងក៏បានពត៌មានថា ព្រះរាជធានីរបស់ព្រះបាទ ភវវរ្ម័ន គឺ ភវៈបុរៈ ដែលស្ថិតនៅតាមដងទន្លេសាបផ្នែកខាងត្បូង ហើយអង្គដែលជាប់ពូជពង្សជាមួយព្រះមហាក្សត្រខ្មែរនៃនគរភ្នំ បានឡើងសោយរាជ្យសម្បត្តិ ក្រោយពីបានរៀបអភិសេកជាមួយក្សត្រីមួយនៃនគរភ្នំ ។

គេបានរកឃើញនៅក្នុងទីតាំងនានា ដូចជានៅតាមដងទន្លេមេគង្គ ខេត្ត ក្រចេះ នៅខេត្ត បុរីរម្យ រវាងទន្លេមូននិងជួរភ្នំដងរែកនៅមង្គលបូរី នៅខាងលិចនៃទន្លេសាប



www.budinst.gov.kh www.elibraryofcambodia.org

នូវសិលាចារឹកជាច្រើន ដែលព្រះអនុជរបស់ព្រះអង្គបន្សល់ទុក ។ ដោយហេតុនេះហើយបានជាព្រះរាជអាណាចក្រភ្នំ ត្រូវផ្លាស់ប្ដូររាជធានី ត្វម៉ូ " *វ្យាធបុរៈ* " គឺបាភ្នំទៅក្នុងភូមិភាគមួយថ្មីទៀត ដែលស្ថិតនៅខាងត្បូងមានឈ្មោះថា ណាភូណា ដែលស្ថិតនៅអង្គរបុរី ។

តាមការពិតការវាយប្រហារខាងលើនេះ រវាងនគរភ្នំនិងចេនឡាមហាយានមានឥទ្ធិពលយ៉ាងខ្លាំងបំផុតនៅក្នុងសង្គមខ្មែរ ។ យើងពុំសូវមានពត៌មានចិនស្ដីពីនគរភ្នំទេដោយហេតុថា ការធ្វើពាណិជ្ជកម្មតាមផ្លូវសមុទ្រ រវាងខ្មែរ និងចិនត្រូវរអាក់រអួលដោយវិបត្តិផ្ទៃក្នុងរបស់ចិន ឯកសារគ្រាន់តែបញ្ជាក់ថា នៅពាក់កណ្ដាលសតវត្សទី ៤ មានមហាក្សត្រខ្មែរមួយព្រះអង្គ ព្រះនាម ចន្ទនៈ ឡើងសោយរាជ្យនៅអាណាចក្រភ្នំ ។ ក្នុងសម័យនេះមានការនាំចេញទៅបរទេស នូវដំរីស្រុកនិងសត្វពាហនៈ ។



www.budinst.gov.kh www.elibraryofcambodia.org

" La verite est que la race khmère a eu une histoire millénaire et disposait d'une splendide richesse culturelle. Le peuple Khmer a connu des heures de gloire puis un effondrement progressif notamment dans sa propre securite, sa prosperité dont les raisons historiques et sociales sont connues dans leurs grandes lignes. "

" En effet si les Cambodgiens sont solidaires, ils seront tres forts et pourront resoudre leurs propres problèmes par exemble contrer l'invasion venant de l'exterieur. "

" Les Cambodgiens doivent croire en eux-mêmes et aimer leurs compatriotes. Car personne aimera les Cambodgiens plus que les Cambodgiens eux-mêmes. "

Discours de S.A.R. Samdech Krom Preas NORODOM RANARIDDH, Premier Premier Ministre, à l'occasion de la fermeture de la Conference internationale sur la Khmerologie ( le 28 Aout 1996 )

## ឥណ្ឌូបនិយកម្ម លើកទី ២ :

ដំណាក់ការនេះយើងសង្កេតឃើញ សន្ទុះថ្មីមួយនៃការផ្សាយ អារ្យធម៌ វប្បធម៌ឥណ្ឌាក្នុងចក្រភពខ្មែរ ។

តាមពង្សាវតារចិន ក្នុងចំណោមស្តេចសោយរាជ្យ៧មកពីឆៀងឈ្វ សន



www.budinst.gov.kh www.elibraryofcambodia.org

ដែលជាឋានន្តរនាមរបស់ពួក ឥណ្ឌ-ស៊ីថរបស់រាជវង្ស កុសាណៈ ។ ពោលគឺចាប់តាំងពីពាក់កណ្តាលសតវត្សទី ៤ ដល់ពាក់កណ្តាលសតវត្សទី ៥ មានស្តេចខ្មែរមួយព្រះអង្គទៀត ព្រះនាម គាវ ឆេងយូ ឬ ព្រាហ្មណ៍កោណ្ឌញ្ញ ជ័យវរ្ម័ន "៤៧៨-៥១៤" ដោយមានកំណើតនៅឥណ្ឌាខាងត្បូង មកសោយរាជ្យក្នុងប្រទេសខ្មែរ ។

ក្រោយពីព្រះអង្គបានយាងមកនគរភ្នំ អ្នកស្រុកក៏លើកព្រះអង្គធ្វើជាស្តេច ។ ព្រះអង្គក៏បានរៀបចំក្បួនច្បាប់ខ្មែរ តាមរបៀបឥណ្ឌាទាំងអស់ក្នុងសម័យនោះ ។ រាជធានីរបស់ខ្មែរ ជំនាន់នោះគឺ វ្យាធបុរៈ ដដែលដែលស្ថិតនៅបាភ្នំ ខេត្ត ព្រៃវែង ។

ក្នុងចំណោមស្តេចសោយរាជ្យតៗមកទៀត គេសង្កេតឃើញមានព្រះបាទ ឆេលីតោប៉ាហ្វៀ ឬព្រះឥន្ទ្រវរ្ម័ន ឬស្រេស្ធវរ្ម័ន "៥១៤-៥៣៩" ដែលបានធ្វើសារនិងជង្វាយទៅព្រះបាទក្រុងចិន ជាស្ពានមេត្រីនៅឆ្នាំ ៤៣៤-៤៣៥ និង ៤៣៨ ។ ម៉្យាងទៀតស្តេចអង្គនេះហ៊ានប្រកែកមិនព្រមជួយចម្ប៉ាក្នុងការចូលរួមមួយ ដើម្បីវាយយកខេត្តតុងកឹងរបស់ចិនវិញ ។ ព្រោះថាព្រះអង្គមានវីរភាព និងថាមពលគ្រប់គ្រាន់បរិបូរណ៍ក្នុងសម័យនោះ ។ លើសពីនេះការដែលខ្មែរជួយចាម ដើម្បីច្បាំងនឹងចិន លក្ខណៈនេះអាចនាំមកនូវផលវិបត្តិ ចំពោះខ្មែរផ្នែកនយោបាយ និងផ្នែកសេដ្ឋកិច្ច ។

ពង្សាវតាររាជវង្ស ស៊ុំខាងត្បូងបានអោយដឹងថា ប្រហែលជា ១០ឆ្នាំក្រោយមកទៀត កាលកំណត់ ៤៣១-៤៣៤ មានស្តេចខ្មែរមួយព្រះអង្គទៀត ព្រះនាមព្រះបាទចេយេប៉ាមោ ឬ ជ័យវរ្ម័ន សោយរាជ្យនៅនគរភ្នំទៀត ។ ស្តេចអង្គនេះមាននាមត្រកូលថា គាវ ឆេនយូ ពោលគឺព្រះអង្គស្ថិតក្នុងត្រកូលរាជវង្ស កោណ្ឌញ្ញដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

ដោយហេតុនេះហើយបានជាគេតាំងព្រះនាមព្រះអង្គថា "កោណ្ឌញ្ញ" ឬ ជ័យវរ្ម័នទី២ ។ បើយើងសំអាងទៅលើការស្រាវជ្រាវរបស់លោក  យើងអាចដឹងព្រឹត្តិការណ៍មួយយ៉ាងសំខាន់  កើតឡើងក្នុងរជ្ជកាលរបស់ព្រះបាទ ជ័យវរ្ម័នទី២ ទ្រង់បានបញ្ជូនឈ្មួញទៅខេត្ត កង់តុង  ហើយពេលដែលត្រឡប់មកវិញ សំពៅឈ្មួញព្រះអង្គនោះក៏ត្រូវខ្យល់ព្យុះបោកបក់ធ្វើអោយធ្លាយធ្លុះច្រានអោយជាប់នឹងច្រាំងសមុទ្រនៃ ប្រទេស លិន យិ ឬជាមួយនឹងព្រះភិក្ខុឥណ្ឌា នាគ សេន ដែលធ្វើដំណើររួមគ្នា ។ ព្រះភិក្ខុអង្គនេះបានធ្វើដំណើរទៅកាន់ស្រុកនគរភ្នំ តាមផ្លូវកាត់នៅឆ្នាំ ៤៨៤នៃគ្រិស្តសករាជ ។ ប្រភពឯកសារចិនដដែលបានអោយដឹងទៀតថា ព្រះបាទជ័យវរ្ម័នបានបញ្ជាព្រះ នាគ សេន បញ្ជូនរាជបណ្ណាការជាច្រើនទៅថ្វាយព្រះចៅចិននៃរាជវង្ស សុង ដូចជាចេតិយភ្លុក ២ និងព្រះពុទ្ធអង្គផ្កាថ្ម១ នៅឆ្នាំ ៥០៣ ។ ព្រះអង្គមានគោលបំណងមួយយ៉ាងច្បាស់លាស់គឺការសុំជំនួយទ័ពពីចិន ដើម្បីយកមកវាយមន្ត្រីខ្មែរម្នាក់ដែលក្បត់និងព្រះអង្គ ហើយរត់ទៅជ្រករាជ្យនៅចម្ប៉ា ។ តែព្រះអង្គពុំបានសំរេចតាមសំណូមពរទេ ដោយហេតុថាស្តេចចិនមិនយល់ស្របតាម ។ ស្តេចចិនគ្រាន់តែជូនត្រឡប់មកវិញសំពត់ព្រៃជាច្រើនដែលមានពណ៌ប្លែកៗប៉ុណ្ណោះ ដើម្បីថ្វាយព្រះអង្គ ។

ម៉្យាងទៀតពង្សាវតារចិនអោយដឹងថា ក្នុងកម្លុងពេលនេះហើយ ដែលព្រះភិក្ខុខ្មែរពីរអង្គ គឺព្រះភិក្ខុសង្ឃបាល - ប្រសូតនៅឆ្នាំ ៤៦០ នៃគ្រិស្តសករាជ ហើយសុគតនៅឆ្នាំ ៥០៦ ។ ស្របនិងព្រឹត្តិការណ៍ដ៏សំខាន់នេះ យើងក៏អាចដឹងដូចពោលខាងលើមកហើយ ព្រះបាទជ័យវរ្ម័នបានថ្វាយព្រះពុទ្ធរូបមួយធ្វើអំពីផ្កាថ្ម ថ្វាយព្រះចៅ



www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

ក្រុងចិន ។

ដោយសំអាងទៅលើឯកសារចិន យើងអាចសន្និដ្ឋានដោយមិនអាចភ័ន្តច្រឡំថា រជ្ជកាលរបស់ព្រះបាទកោណ្ឌញ្ញ ជ័យវរ្ម័នទី ២ គឺជារជ្ជកាលមួយដែលប្រកបដោយភាពជឿនលឿនរុងរឿងអស្ចារ្យ ។ បានជានៅគ្រឹស្តសករាជ ៥០៣ ព្រះចៅចិនបានមានព្រះឱង្ការថា " ព្រះរាជានៃនគរភ្នំ ព្រះអង្គមានព្រះនាមថា កោណ្ឌញ្ញ ជ័យវរ្ម័ន ប្រថាប់នៅចុងខេត្តផុតពីសមុទ្រ " *ហើយដើម្បីសំដែងនូវភាពស្មោះត្រង់ សុចរិត ព្រះអង្គបញ្ជូនរាជបណ្ណាការថ្វាយស្តេចយើងមិនឈប់ឈរ* " ។ កំណត់ហេតុចិនខាងលើនេះសអោយឃើញថា នគរភ្នំមានកេរ្តិ៍ល្បីល្បាញ និងមានសន្តិសុខយ៉ាងប្រាកដ ក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ដែលជាមហារាជនៃអាណាចក្រ ក្នុងរជ្ជកាលរបស់ព្រះអង្គនេះ ។ នគរភ្នំបានឈ្មោះចម្ប៉ាហើយ ប្រទេសនេះក៏ក្លាយទៅជាស្រុកចំណុះ ។

ព្រះអង្គអស់ព្រះជន្មនៅគ្រឹស្តសករាជ ៥១៤ ដោយពុំបានបន្សល់ចារឹកអ្វីទេ មានតែអគ្គមហេសីរបស់ព្រះអង្គគឺ កុលប្រះភាវតី និងរាជបុត្ររបស់ព្រះអង្គ ព្រះនាមគុណវរ្ម័ន ដែលបានទុកជាកេរដំណែល នូវចារឹកមួយរៀង១ខ្លួន ។

តាមសិលាចារឹកនៃប្រាសាទប្រាំល្វែង ចារឡើងនៅចុងសតវត្សទី៥ នៅកម្ពុជាក្រោមដែលស្តីពីបុណ្យអភិសេកជើងព្រះវិស្ណុ ព្រះបាទគុណវរ្ម័ន ជាព្រះឱរសរបស់ព្រះរាជា ដែលជាដួងច័ន្ទនៃព្រះរាជវង្ស កោណ្ឌញ្ញ ។

ព្រះអង្គបានធ្វើជាមេក្លោងក្នុងតំបន់វាលភក់ល្បប ក្រោយពីបានធ្វើអោយភក់ល្បាប់នៃតំបន់នោះ ក្លាយទៅជាទីមានប្រជាពលរដ្ឋរស់នៅយ៉ាងកុះករ ។ ព្រះបាទគុណ



www.budinst.gov.kh www.elibraryofcambodia.org

LIBRARY INSTITUT

វរ្ម័ន បានត្រូវបងរបស់ព្រះអង្គធ្វើគត ហើយឡើងសោយរាជ្យជំនួស ។ រីឯសិលាចារឹករបស់ព្រះនាង កុលប្រភាវតីវិញ ដែលគេរកឃើញក្នុងភាគខាងត្បូងបរិវេណនៃខេត្ត តាកែវ សព្វថ្ងៃ "សិលាចារឹកអ្នកតាដំបងដែក" មានការពិពណ៌នាអំពីបំណងទៅបំពេញសីលរបស់ព្រះនាង និងវណ្ណកម្មដូចជាសាងអាស្រមនិងស្រះទឹកជាដើម ។ អោយព្រះអង្គរួបរួមគម្ពីរផ្នែកព្រះពុទ្ធសាសនា ហើយផ្ញើទៅកាន់ប្រទេសចិន ។ នៅឆ្នាំ ៥៤៦ នៃ គ.ស ព្រះរាជាខ្មែរទ្រង់បានបញ្ជូនព្រះភិក្ខុ ឥណ្ឌូនាមថា មាន ឬ គុណរតនៈនៃក្រុងអជ្ជជីនី ដែលស្ថិតនៅក្នុងនគរភ្នំ ក្នុងខណៈនោះព្រមទាំងគម្ពីរ ២៤០ បាច់ផងទៅថ្វាយព្រះចៅចិន ។

ក្នុងសិលាចារឹកមួយផ្ទាំងចារឡើងក្នុងរជ្ជការរបស់ព្រះបាទ រុទ្រវរ្ម័ន ដែលគេរកឃើញនៅ តាព្រហ្មណ៍_បាទី យើងអាចកត់ត្រាថា ព្រះអង្គកាន់ព្រះពុទ្ធសាសនាគណៈហីនយាន ។ ព្រោះថានៅក្នុងសិលាចារឹកនេះ មានការអធិប្បាយពី ព្រះធាតុ ។ *ព្រះជាម្ចាស់ដែលមានព្រះធាតុដ៏កល់ទុកតាំងពីបុរាណ*" ផ្តល់អោយសត្វលោក ជួបតែសេចក្តីសុខ ឥឡូវនេះនៅតែផ្តល់តទៅទៀត ។ ជាទីបញ្ចប់ចំពោះវត្តមាន នៃព្រះ_ពុទ្ធសាសនានៅនគរភ្នំ ពង្សាវតារជីខាងត្បូង បានអោយដឹងទៀតថា ព្រះចៅចិនបានបញ្ជូនរាជទូតមួយនៅឆ្នាំ ៥៣៩ ដើម្បីរកព្រះកេសនៃព្រះពុទ្ធអង្គ ។

រួមសេចក្តីមកទាំងសិលាចារឹក ទាំងឯកសារចិន ព្រមទាំងវត្ថុបុរាណដែលគេបានរកឃើញបញ្ជាក់អោយយើងដឹងថា ព្រះពុទ្ធសាសនា "*ហីនយាន និង មហាយាន*" ព្រមទាំងព្រហ្មញ្ញសាសនាមានអនុភាព ខ្លាំងក្លាបំផុតនៅនគរភ្នំ ហើយសាសនាទាំងពីរ



www.budinst.gov.kh www.elibraryofcambodia.org

នេះមានជីវិតរស់រានទៅជិតគ្នា ដោយសុខដុមរមនា "*ចុះចុះតរតា*" ។



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

" La race Khmère très puissante du IIIe au XIIe siècles débordait alors les frontières du Protectorat français et, dès l'an 600 de notre ère, elle avait atteint, sinon dépassé, les limites que les traditions locales donnent au royaume, c'est-à-dire, selon une orientation d'ailleurs défectueuse : Korat au Nord, (28) Attopeu à l'Est, Baria au Sud et Pachim (28) à l'Ouest ( ce dernier nom est la transformation accidentele du sanscrit Paccima ).En effet, les inscriptions ultérieures ne les dépasseront qu'accidentellement. Ce sont les frontières du royaume cambodgien proprement dit et celles de la race Cambodgienne ". A l'apogée de son empire le Cambodge " s'etendait de la Chaine Annamitique au golfe du Bengale et des bouches de l'Irraouadi aux frontières chinoises. C'etait là un immense territoire d'environ un million de kilomètres carrés, divisé en une soixantaine de principautés "

*Capt.Barrault, Les Cambodgiens de Cochinchine ,Revue Indochinoise 1927*

## សម័យចេនឡា

**សេចក្តីផ្តើម ៖**

ការសិក្សាឯកសារនានា បង្ហាញអោយយើងដឹងថា សម័យចេនឡាដែលតពីសម័យនគរភ្នំ សង្គមខ្មែរមានការប្រែប្រួលគ្រប់វិស័យ តែសម័យចេនឡាក៏ដូចជាសម័យមុនដែរ គឺសម័យដែលស្តេចខ្មែរសម្រេចនូវសាមគ្គីភាពទូទាំងប្រទេស ពោលគឺតំបន់នានា ឬទីតាំងនានាដែលពួកខ្មែរ_មនរស់នៅ ។ ព្រឹត្តិការណ៍នេះសំខាន់ណាស់ ពីព្រោះមានអនុភាពទៅលើផ្នែកសង្គមកិច្ច នយោបាយនិងសិល្បៈនៃជំនាន់នោះ ដោយហេតុនេះហើយបានជាច្បាប់ទំនៀមទំលាប់ ក៏ផ្តេកផ្តួលទាំងស្រុងទៅលើទំរង់សង្គមដែលមានអំណាចកណ្តាលគ្រប់គ្រង ។

របបរាជានិយមមិនមែនផុសឡើងដោយឯកឯងទេ ។ របបនេះមានឫសគល់ពីសម័យមុនគឺសម័យបុរេប្រវត្តិ ។ បើនិយាយម៉្យាងទៀត របបរាជានិយមរបៀបឥណ្ឌា ក្នុងសម័យនគរភ្នំ ឬចេនឡានៅតែព្រារព្ធនូវអ្វីៗដែលធ្លាប់មានមកពីមុន ហើយគ្រាន់តែផ្លាស់ប្តូរទ្រង់ទ្រាយថ្មី អោយស្របនឹងកាលៈទេសៈតាមសេចក្តីត្រូវការនៃសង្គម



www.budinst.gov.kh www.elibraryofcambodia.org

ប៉ុណ្ណោះ ។ ដូចរដ្ឋនគរភ្នំ រដ្ឋចេនឡាក៏កើតឡើងដោយការបង្រួបបង្រួមនៃក្កូនសង្គម តូចៗទាំងឡាយដោយកម្លាំងទ័ព និងឥទ្ធិពលសាសនាដែលជាគ្រឹះ ។

ការវិវឌ្ឍន៍នៃសង្គមខ្មែររបៀបក្លិង្គ ប្រព្រឹត្តឡើងសន្សឹមៗ ហើយជួនកាលមាន លក្ខណៈមិនដូចគ្នាតាមទីកន្លែង តែយូរអង្វែងទៅក៏ទ្រង់ទ្រាយរបស់សង្គមថ្មី_របបរាជា និយម_ជ្រួតជ្រាបពេញនគរ ថែមទាំងក្លាយជាទម្លាប់សម្រាប់ខ្មែរ ។ ប្រទេស កម្ពុជា ចាប់តាំងពីសតវត្សទី ១ រហូតដល់សតវត្សទី ២០ មុនបដិវត្តន៍នាឆ្នាំ ១៩៧០ មិនដែល ស្គាល់របបអ្វីក្រៅពីរបបរាជានិយម ដែលជាមូលដ្ឋានជាគ្រឹះនៃសង្គមខ្មែរ ។

គួររំលឹកឡើងវិញថា មុនរបបរាជានិយម រដ្ឋខ្មែរពុំទាន់កើតឡើងទេ មានតែ មេកន្ទ្រាញធំៗ ដែលជាមេទ័ពដ៏ខ្លាំងពូកែ ក្លាហានដឹកនាំត្រួតត្រាស្រុកភូមិ ដោយមាន ចាស់ទុំជាទីប្រឹក្សា ឥឡូវនេះជាពិសេសក្នុងសម័យចេនឡាដែលយើងមានឯកសារច្រើន ហើយច្បាស់ជាងមុន ស្តេចខ្មែរមានរាជបរិពារ ដូចជា នាម៉ឺន មន្ត្រី មេទ័ពតូចធំ ព្រាហ្មណ៍បុរោហិត កវី ទីប្រឹក្សា ។ល។ ក្នុងសម័យនេះក៏ដូចសម័យមុនៗ មាន ការពង្រីកទឹកដីដែលជាកេរ្តិ៍របស់មហាក្សត្រខ្មែរពីអតីតកាល ។

ការសិក្សាសិលាចារឹក ឯកសារចិន និងវត្ថុបុរាណក្នុងអតីតអាណាចក្រខ្មែរ បង្ហាញអោយឃើញថា នៅសតវត្សទី ៥_៦ ប្រទេសកម្ពុជាបុរាណគ្រប់គ្រងដោយ ព្រះរាជវង្សានុវង្សខ្មែរ ពីរក្រុមខុសគ្នា ។ ក្រុមទី១ តាំងព្រះរាជធានីនៅវ្យាធបុរៈសព្វ ថ្ងៃ អង្គរបូរី ស្រុកព្រៃកប្បាស ខេត្ត តាកែវ ដែលជាបីតាំងទាប ។

ព្រះរាជវង្សានុវង្សមួយក្រុមទៀត តាំងនៅប៉ែកខាងលើ" ពារម្ភបុរៈ"សម្បូណ៌



www.budinst.gov.kh www.elibraryofcambodia.org

# ការបែកបាក់នៃនគរភ្នំគ្រាដំបូងបង្អស់នៃប្រទេសកម្ពុជា ឬចេនឡា ( ៥៥០ - ៦៣០ )

កត្តាដែលបណ្តាលអោយឬទ្ធានុភាពរបស់ក្រុងភ្នំចុះទនខ្សោយ គឺវិប័ត្តនយោបាយ នៃប្រទេសជិតខាង គឺចិន និងឥណ្ឌា ដែលជះទៅលើស្រុកខ្មែរ ហើយបានធ្វើអោយសេដ្ឋកិច្ចខ្មែរធ្លាក់ដុនដាប ។

ជាហេតុធ្វើអោយអំណាចកណ្តាលរង្គោះរង្គើ ។ ហើយក្រោយពីសោយទិវង្គតរបស់ព្រះបាទ រុទ្រវរ្ម័ន នគរភ្នំចុះទនខ្សោយដោយការបែកបាក់សាមគ្គីសាមគ្គា ។ ឆ្លៀតឱកាសនេះ ស្តេចខ្មែរមួយព្រះអង្គថ្មី គឺព្រះបាទភវវរ្ម័ន ដែលជាប់ព្រះញាតិវង្សនឹងរាជវង្សមុនៗ ព្រះអង្គបានបង្ក្រាបការបះបោរក្នុងនគរ ហើយក៏ឡើងសោយរាជ្យបល័ង្ក ។

ក្រោយពីព្រះអង្គឡើងសោយរាជ្យភ្លាម រវាង ៥៥០ នៃ គ.ស ព្រះអង្គក៏ផ្លាស់ឈ្មោះ នគរភ្នំ អោយហៅថាចេនឡា ឬប្រទេសកម្ពុជាវិញ ។ សូមរំលឹកថាតាមយោបល់របស់លោក George Coedès ពាក្យកម្ពុជា ដែលជាឈ្មោះរបស់ខ្មែរយើងនេះកើតមកពីពាក្យផ្សំគ្នាគឺ កម្ពុជា *ព្រាហ្មណ៍ កម្ពុ* ឬ *កោណ្ឌញ្ញ* និង មេរា *សោម*,



www.budinst.gov.kh www.elibraryofcambodia.org

*ថ្ងនាងនាគ* ដោយហេតុថា បុព្វបុរសទាំងពីរខាងលើនេះជាអ្នកផ្តើមរាជ្យវង្សានុវង្ស ដំបូងបង្អស់ បន្ទាប់ពីសម័យនគរភ្នំ ។

ទំព័រប្រវត្តិសាស្ត្រចិនបានអោយដឹងថា : ព្រះបាទ ហ្វាន់ ភេម៉ាន់ ពេលដែលព្រះអង្គមានប្រឈួន ព្រះអង្គបានបញ្ជូនរាជបុត្រមួយព្រះអង្គឈ្មោះ គិន ឆេង អោយទៅសោយរាជ្យជំនួសព្រះអង្គ ។ ពេលនោះក្មួនបងស្រីរបស់ព្រះអង្គ ឈ្មោះ ផាន ហ្វាន់ ផាន ដែលជាមេទ័ពនៅឡើយ មេត្រូវទ័ព ២.០០០០ នាក់ បានដណ្តើមរាជ្យ ដោយបានធ្វើគត់ព្រះបាទ គិន ឆេង ទៅ ។ តែព្រះបាទ ហ្វាន់ ភេម៉ាន់ នៅមានព្រះរាជ្យបុត្រមួយអង្គទៀត ដែលនៅជាដោះនៅឡើយ ពេលព្រះអង្គសោយទិវង្គត ហើយមានព្រះនាមថា ឆាង ។ ព្រះរាជបុត្រ ឆាង នេះរស់នៅក្នុងចំណោមប្រជារាស្ត្រ នៃនគរភ្នំ ។ ពេលដែលព្រះអង្គមានព្រះជន្ម ២០ ឆ្នាំ ព្រះអង្គក៏កេណ្ឌទ័ពទៅសម្លាប់ព្រះអង្គ ហ្វាន់ ឆាន ដែលធ្វើឃាតព្រះបិតាព្រះអង្គ តែព្រះបាទ ហ្វាន់ ឆាន ត្រូវព្រះបាទ ហ្វាន់ ស៊ិយុន ធ្វើឃាតហើយឡើងសោយរាជ្យជំនួសព្រះទៅវិញ ជាព្រះមហាក្សត្រ នៃនគរភ្នំ ។ គឺស្តេចអង្គនេះហើយ ដែលបានធ្វើស្ពាយអាការជាស្ពានមេត្រីនឹងប្រទេសចិន ដែលបានចងក្រងឡើងក្នុងសម័យមុន ដោយព្រះបាទ ហ្វាន់ ឆាន ។ រវាងឆ្នាំ ២៤៥ និង២៥០ ព្រះអង្គបានទទួលប្រតិភូទូត ចិន ដឹកនាំដោយលោក កាំង ថៃ និង លោក ឈូ យ៉ិង ។



www.budinst.gov.kh www.elibraryofcambodia.org

បើតាមឯកសារចិន ព្រះអង្គបានផ្ញើរាជទូតខ្មែរនៅចិន ជាច្រើនដងរវាងឆ្នាំ២៦៨ និង ២៦៧ ។ ចំណុចនេះបង្ហាញអោយយើងដឹងថា ការទាក់ទងរវាងខ្មែរ និងចិន នាសម័យនោះ មានសារសំខាន់បំផុតតាមផ្នែកនយោបាយ និងផ្នែកសេដ្ឋកិច្ច។

ក្រោយមកទៀត នៅដើមសតវត្សទី ៤ នៃសតវត្សទី ៣ មេទ័ព ហ្វាន់ ស៊ុន ឬ ហ្វាន់ ស៊ីយុន ប្រកបដោយអំណាចដ៏ខ្លាំងក្លា ក៏បានប្រកាសខ្លួនជាមហារាជនៃព្រះអាណាចក្រនគរភ្នំ ។

ក្នុងរជ្ជកាលរបស់ព្រះអង្គ យើងសង្កេតឃើញមានការស្ថាបនា ព្រះរាជវាំង និងវត្ត ធ្វើអំពីឈើនឹងឥដ្ឋសំរាប់ទ្រទ្រង់ព្រះពុទ្ធសាសនា ។

ក្នុងសម័យនោះ ខ្មែរបានចងសម្ព័ន្ធភាពជាមួយប្រទេសចម្ប៉ា ឬ លិនយី ដែលជាប្រទេសមួយខ្លាំងខ្លា ។ ដើម្បីជៀសវាងសង្គ្រាម ពីព្រោះប្រទេសនេះអាចអោយនគរភ្នំទទួលរងគ្រោះថ្នាក់ដល់អាយុជីវិត ដូចជាការជ្រៀតជ្រែកក្នុងបញ្ហាផ្ទៃក្នុងរបស់ប្រទេសខ្មែរជាដើម ។ ក្នុងន័យនេះហើយបានជានៅឆ្នាំ ២៧០ សម្ព័ន្ធភាពរវាងខ្មែរ និងចាមបានប្រព្រឹត្តធ្វើឡើង ។

គេបានដឹងថា ទ័ពខ្មែរបានចូលរួមជាមួយទ័ពចាម ក្នុងគោលបំណងវាយបំបាក់បន្ទាយរបស់ព្រះចៅចិន នៅតំបន់ សៅឈី នៅយួនខាងជើង ហើយសង្គ្រាមរវាងខ្មែរ_ចាម និងព្រះរាជអាណាចក្រចិន ព្រះនាម "អ៊ូ" បានប្រព្រឹត្តឡើងក្នុងរយៈពេល



www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គសោយរាជ្យដល់ ២៨៩ ហើយរហូតដល់មរណៈភាពរបស់ព្រះអង្គ នៅចុងសតវត្សទី ៨ នៃសតវត្សទី ៣ ដល់សតវត្សទី ៤ គ្មានព្រឹត្តិការណ៍អ្វីសំខាន់កើតឡើងទេ ។ ក្នុងកម្លុងពេលនេះ ចិនមិនបាននិយាយពីនគរភ្នំយើងសោះ ។

នៅក្នុងសម័យកាលនៃសតវត្សទី ៣ និងសតវត្សទី ៤ នៃគ្រិស្តសករាជ បើយើងសំអាងលើឯកសារចិន យើងអាចសង្កេតឃើញថា ព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ជាកត្តាបង្រួបបង្រួមជាតិខ្មែររវាងតំបន់ខ្ពស់ និងតំបន់ទំនាប ។

គួរកត់ត្រាដែរថា គេបានរកឃើញសិលាចារឹក ភាសាសំស្ក្រឹតរបស់ព្រះបាទភវវរ្ម័ន ពីរផ្ទាំង ។ ឯកសារទី១ ដែលគេបានរកឃើញនៅអង្គបូរី ស្តីពីការស្ថាបនានូវសិវលិង្គ ។ ឯកសារទី២ ដែលគេបានរកឃើញនៅស្រីទេព នៅស្រុកថៃសព្វថ្ងៃ មានការរំលឹកពីអភិសេករបស់ព្រះអង្គ នៅឆ្នាំ ៥៩៨ នៃគ្រិស្តសករាជ ។ ដូច្នេះក្រោយពីព្រះអង្គសោយទិវង្គត រវាងឆ្នាំ ៦០០ នៃគ្រិស្តសករាជ ក្មួយរបស់ព្រះអង្គ ព្រះបាទ ចិត្រ សេន ក៏ឡើងសោយរាជក្នុងភូមិភាគដ៏ធំខាងលើនេះ ដែលត្រូវចិនតាំង ឈ្មោះថា ចេនឡាគោក (នគររាជសិមា. សុរិន្ទ្រ. ពេបុរម្យ. អ៊ូបន. ពេជ្យប៊ុន ។ល។ )

ម៉្យាងទៀតនៅតាមដងទន្លេមូនមេគង្គនៅសុរិន្ទ្រ រវាងដងទន្លេមូន និងជួរភ្នំដងរែក គេបានរកឃើញនូវសិលាចារឹករបស់ព្រះបាទ ចិត្រ សេន ឬ មហេន្ទ្រវរ្ម័នជាច្រើនផ្ទាំង ដែលស្តីពីការស្ថាបនាសិវលិង្គ ឬព្រះគោ ។ លើសពីនេះ ដើម្បី



www.budinst.gov.kh www.elibraryofcambodia.org

ហេតុជាតិ ព្រះអង្គបានផ្ញើរាជទូតមួយទៅចងស្ពានមេត្រីជាមួយប្រទេស ចម្ប៉ា ដែរ។

សរុបសេចក្តី ព្រះបាទ ចិត្រសេន ឬមហេន្ទ្រវរ្ម័ន ទ្រង់បន្តស្នាព្រះហស្តពីព្រះបាទ ភវវរ្ម័ន ដែលត្រូវជាព្រះជេដ្ឋា ឬបងប្រុសរបស់ព្រះអង្គ ។ រជ្ជកាលបន្ទាប់មកគឺរជ្ជកាលរបស់ព្រះបាទ ឦសានវរ្ម័នទី១ "៦១៥_៦២៧ " ដែលតាមឯកសារបានកើតឡើងមិនយូរប៉ុន្មានក្រោយពីឆ្នាំ ៦១៦_៦១៧ ពេលដែលព្រះអង្គផ្ញើព្រះរាជទូតទៅស្រុកចិន ។ ព្រះបាទឦសានវរ្ម័នទី១ ទ្រង់ដែលជាព្រះរាជបុត្ររបស់ព្រះបាទ ចិត្រសេន មហេន្ទ្រវរ្ម័ន ព្រះអង្គពង្រីកឥទ្ធិពលរបស់ព្រះអង្គទៅលើទឹកដី ដែលជាកេរ្តិ៍របស់ ព្រះបិតាព្រះអង្គ ព្រមទាំងសម្រេចការគ្រប់គ្រងត្រួតត្រាទឹកដីទាំងមូលរបស់នគរភ្នំ ។ គេបានរកឃើញនូវសិលាចារឹករបស់ព្រះអង្គ ជាច្រើនដូចជានៅខេត្តកំពុងចាម ព្រៃវែង កណ្តាល តាកែវ ច័ន្ទបុរី សុរិន្ទ្រ អ៊ូបន បុរីរម្យ ដែលបានពោលខាងលើរួច ។ ដើម្បីសម្រេចនយោបាយបង្រួបបង្រួមនេះ ឬការត្រួតត្រាទៅលើភូមិភាគដ៏ធំធេងខាងលើនេះ ព្រះអង្គបានចងស្ពានមេត្រីជាមួយចិន ថែមទៀតផង ។

រាជធានីរបស់ព្រះអង្គ គឺឦសានបុរៈ ។ គេអាចវិនិច្ឆ័យបានថា ព្រះអង្គបានសោយរាជ្យសម្បត្តិដល់ឆ្នាំ ៦៣៥ នៃគ្រិស្តសករាជ ពីព្រោះពង្សាវតារ តាំង បានសរសេរថា ព្រះអង្គបានវាយដណ្តើមនគរភ្នំបានជាស្ថាពរ រវាងឆ្នាំ ៦២៧_៦៤៩ នៃគ្រិស្តសករាជ ។

ម្យ៉ាងទៀតរហូតដល់សតវត្សទី៧ ចិនហៅប្រទេសកម្ពុជាថា : ឦសានបុរៈ ដែលត្រូវនឹងតំបន់សម្បូណ៌ព្រៃគុក សព្វថ្ងៃនេះដែលស្ថិតនៅខាងជើងប្រមាណ



www.budinst.gov.kh www.elibraryofcambodia.org

៣៥ គ.ម នៃខេត្តកំពង់ធំ គឺនៅក្នុងតំបន់នេះហើយ ដែលគេបានជួបប្រទះនូវប្រាសាទឥដ្ឋជាច្រើនក្រុមព្រមទាំងផ្ទាំងសិលាចារឹករបស់ព្រះអង្គជាច្រើន ហើយក្នុងចំណោមសិលាចារឹកនោះ មានសិលាចារឹកមួយ ស្ដីពី ឦសានបុរៈ ដែលជាឈ្មោះទីក្រុង ឬរាជធានីរបស់ព្រះអង្គ ។ម្យ៉ាងទៀតគេអាចសន្និដ្ឋានថា គឺក្នុងរជ្ជកាលរបស់ព្រះអង្គនេះហើយដែលគេបានកសាងស្ថាបនាកម្មនៃភ្នំ បាយ៉ង់ នៅខេត្តតាកែវ ដែលមាន លក្ខណៈ មិនខុសពីប្រាសាទខ្លះនៃក្រុមប្រាសាទនៅសម្បូណ៌ព្រៃគុកឡើយ ។

ដើម្បីជៀសវាងនូវការហូរឈាម ឬសង្គ្រាមក្នុងប្រទេស ព្រះអង្គបានចងស្ពានមេត្រីរវាងព្រះរាជវង្សានុវង្សខ្មែរទាំងអស់ តពូជពង្សពីសម័យមុន១។ ជាហេតុនាំអោយព្រះអង្គបង្កើយនូវសមិទ្ធផលរបស់ព្រះអង្គដោយជោកជ័យ ហើយមានលទ្ធិភាពក្នុងការត្រួតត្រាតំបន់នានា របស់នគរភ្នំជាស្ថាពរ ។

ព្រះអង្គឈប់សោយរាជ្យសម្បត្តិ រវាងឆ្នាំ៦៣៥ នៃគ្រិស្តសករាជ សិលាចារឹកខ្មែរ បានធ្វើអោយយើងស្គាល់ស្ដេចខ្មែរមួយអង្គទៀត ព្រះនាមថា ព្រះបាទ ភវវម៌្មនទី២ ។ យើងមិនស្គាល់ប្រវត្តិរបស់ព្រះអង្គយ៉ាងល្អិតល្អនទេ តែយើងគ្រាន់តែដឹងសកម្មភាពរបស់ព្រះអង្គខ្លះ១ តាមសិលាចារឹកមួយផ្ទាំងគត់របស់ព្រះអង្គ ដែលចារឡើង នៅខេត្ត តាកែវ ក្នុងឆ្នាំ៦៣៥ នៃគ្រិស្តសករាជ ។

គេអាចសន្និដ្ឋានដោយមិនភ័ន្តច្រឡំថា គឺព្រះអង្គនេះហើយដែលសាង ប្រាង្គប្រធាននៃភ្នំ បាយ៉ង់ ភ្នំព្រះវិហារនៅខេត្ត កំពង់ឆ្នាំង ។



www.budinst.gov.kh www.elibraryofcambodia.org

ព្រះរាជបុត្ររបស់ព្រះអង្គ គឺព្រះបាទជ័យវរ្ម័នទី១ " ៦៥៥-៦៨១ " ដែលត្រូវសោយរាជ្យសម្បត្តិបន្ទាប់ពីព្រះអង្គ ។ ព្រះរាជ្យបុត្រនេះ បើតាមសិលាចារឹកមួយដែលត្រូវចារឡើងនៅឆ្នាំ៦៥៧ ត្រូវឡើងសោយរាជ្យសម្បត្តិ ប្រហែលជាមុនកំណត់វេលានេះ ហើយទំហំទឹកដី ដែលព្រះអង្គគ្រប់គ្រងនោះធំធេងអស្ចារ្យ ។ បើនិយាយម្យ៉ាងទៀត គេបានរកឃើញសិលាចារឹក ដែលចារឡើងក្នុងរជ្ជកាលរបស់ព្រះអង្គ ពីខាងជើងតំបន់វត្ត ភូ នៅលាវ រហូតដល់ឈូងសមុទ្រសៀម ភាគខាងត្បូងសាន ។ ស្ថិតិវណ្ណកម្មទាំងឡាយរបស់ព្រះអង្គ ដូចជាទេវស្ថាននៅជិតស្រុក ដែលស្ថិតមិនឆ្ងាយពីរាជធានីវ្យាធបុរៈ រវាងបាភ្នំនៃខេត្តព្រៃវែង និងអង្គបុរី នៃខេត្តតាកែវសព្វថ្ងៃនេះ ។ ម្យ៉ាងទៀត ព្រះអង្គក៏បានស្ថាបនាប្រាសាទនៅលើភ្នំជាច្រើន ដូចជាវត្ត ភូ នៅស្រុកលាវ បច្ចុប្បន្នសម្រាប់តំកល់លិង្គ ព្រះ ឥសូរ ឬទេវរូបដូចជាព្រះហរិមារជាដើម ។ ពង្សាវតារ តាំង ក៏បានរៀបរាប់ពីការបួរទូតជាមួយនគរចេនឡាដែរ ជាពិសេសអធិរាជចិនឈ្មោះ កៅ តុង ៦៥០-៦៨៣ បានទទួលប្រតិភូខ្មែរក្នុងរជ្ជកាលរបស់ព្រះអង្គ។

តាមឯកសារចិន ក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី១ នេះប្រទេសខ្មែរស្គាល់នូវភាពស្ងប់ស្ងាត់រុងរឿងក្នុងកម្លុងពេលវេលាជាងសាមសិបប្លាយឆ្នាំ ដល់ឆ្នាំ៦៨១ នៃគ្រិស្តសករាជ ។ ព្រះអង្គចូលទិវង្គតនៅឆ្នាំ ៧១៣ ( ព្រះអង្គស្តេចយាងទៅ សិវបុរៈ ) ដោយគ្មានរាជទាយាទស្នងរាជទេ ។



www.budinst.gov.kh www.elibraryofcambodia.org

ទីបញ្ចប់ យើងអាចសំគាល់ឃើញថា ក្នុងសម័យកាលនេះ មានការស្ថាបនារាជធានីថ្មីមួយទៀតគឺ ឰសានបុរៈ ហើយប្រទេសខ្មែរ ដែនដីខ្មែរ ដែលស្ថិតនៅតាមទីវាលទំនាបនៃទន្លេមេគង្គ និងតាមឆ្នេរសមុទ្រភាគឰសានរួបរួមគ្នាជាធ្លុងមួយ ។ ម្យ៉ាងទៀត ទីតាំងទាំងឡាយ ដែលស្ថិតនៅទិសឧត្តរ ក៏ត្រូវអំណាចកណ្តាលពង្រឹងគ្របសង្កត់ដែរ ។

ក្នុងករណីនេះហើយ បានជាយើងអាចសន្និដ្ឋានថា នាសម័យចេនឡា ទឹកដីដែលត្រួតត្រាដោយសន្តតិវង្សចេនឡាមានទំហំធំធេងអស្ចារ្យ ។



www.budinst.gov.kh www.elibraryofcambodia.org

# ការបែងចែកនៃប្រទេស កម្ពុជា ជាពីរ
# នៅដើមសតវត្សទី ៨
# ចេនឡាគោក និង ចេនឡាទឹក

ដោយសំអាងទៅលើពង្សាវតារនៃរាជវង្ស ចិន តាំង គេអាចសំគាល់ថា រវាងឆ្នាំ ៧០៦ ប្រទេសខ្មែរ ក្រោយពីមរណភាពរបស់ព្រះបាទ ជ័យវរ្ម័នទី ១ ត្រូវបែកជាក់ជាពីរ គឺចេនឡាគោក និងចេនឡាទឹក ។

សូមរំលឹកឡើងវិញថា ក្រោយពីព្រះបាទជ័យវរ្ម័នទី ១ ចូលទិវង្គតទៅ ដោយគ្មានព្រះរាជបុត្រឡើងសោយរាជ្យជំនួស មហេសីរបស់ព្រះអង្គព្រះនាម ព្រះជ័យទេវីក៏ឡើងគ្រប់គ្រងជំនួស ។ ទិដ្ឋភាពនេះបញ្ជាក់អោយយើងដឹងថា ប្រទេសខ្មែរចុះទន់



www.budinst.gov.kh www.elibraryofcambodia.org

ខ្សោយ នៅក្នុងពេលនោះ ។

តាមឯកសារចិន ពាក់កណ្តាលនៃប្រទេសកម្ពុជា ដែលស្ថិតនៅខាងជើង ប្រ-កបដោយភ្នំ និងជ្រលងភ្នំ មានឈ្មោះថា ចេនឡាគោក ។ ពាក់កណ្តាលទៀតដែលស្ថិតនៅខាងត្បូង ហើយប្រកបដោយសមុទ្រនិងពឹងបួរ " *ចំនាបទន្លេមេគង្គ តាប់ពីខោនចុះដល់សមុទ្រសៀម* " មានឈ្មោះថា ចេនឡាទឹកលិច ។

ចំពោះព្រឹត្តិការណ៍នានានៃ ចេនឡាគោក យើងអាចកត់សំគាល់ថា នៅដើមសតវត្សទី ៨ នោះគឺនៅឆ្នាំ ៧១១ ខ្មែរបានផ្ញើទូតខ្មែរទៅស្រុកចិន ហើយបានធ្វើប្រតិបត្តិការសឹកមួយនៅឆ្នាំ ៧២២ នៅស្រុកយួនសព្វថ្ងៃ ក្នុងបំណងជួយអ្នកដឹកនាំម្នាក់ ដែលបះបោរប្រឆាំងនឹងចិន ។ ចំណែកឯចេនឡាទឹកវិញ យើងអាចកត់សំ-គាល់ថា ប្រទេសនេះគ្មានសាមគ្គីធម៌ទេ ព្រោះថាត្រូវបាក់បែក ជាកុលសម្ព័ន្ធតូចៗជាច្រើន ។ បើយើងពឹងផ្អែកទៅលើឯកសារចិន រាជធានីរបស់ចេនឡាទឹកលិចក្នុងជំនាន់នោះ គឺ ពាលទិត្យបុរៈ ដែលសោយរាជ្យដោយព្រះបាទ បលទិត្យ ដែលជាប់ពូជពង្សជាមួយ ព្រាហ្មណ៍កោណ្ឌញ្ញ និងនាងនាគ សោមា ហើយដែលត្រូវជាបុព្វបុរសនៃស្តេចខ្មែរទាំងអស់នៃសម័យអង្គរវត្ត ។

នៅដើមសតវត្សទី ៨ ស្តេចខ្មែរមួយអង្គទៀតព្រះនាម បស្កភាក្យ ឡើងសោយរាជ្យសម្បត្តិតពីព្រះបាទ ពាលទិត្យ ។ ព្រះអង្គបានលាចាកពី អនិន្ទិតបុរៈ ហើយតាំងរាជធានី សម្ភុបុរៈ " សម្បូណ៌ឈើដែលស្ថិតនៅតាមឆ្នេរទន្លេមេគង្គ ។

នៅពាក់កណ្តាលសតវត្សទី ៨ ទីក្រុង សម្ភុបុរៈ ក៏ត្រូវធ្លាក់ក្នុងការគ្រប់គ្រង



www.budinst.gov.kh www.elibraryofcambodia.org

របស់ស្តេចខ្មែរមួយអង្គទៀត គឺ ជ័យវរ្ម័នទី ១ ដែលជាសាច់ញាតិជាមួយព្រះញាតិវង្ស បុស្ករាក្ស ។ ក្រោយពីព្រះអង្គសោយទិវង្គតទៅ ស្ថានភាពស្រុកខ្មែរកាន់តែចុះទន់ខ្សោយ បែកបាក់ជាងមុនជាលំដាប់ រហូតមានការត្រួតត្រាមាតុភូមិដោយប្រទេសជ្វា ។ ការបង្រួបបង្រួមចេនឡាទាំងពីរនឹងត្រូវធ្វើឡើង ដោយព្រះបាទជ័យវរ្ម័នទី ២ ក្រោយឆ្នាំ ៨២០ បើគេសំអាងទៅលើឯកសារចិន ក្នុងកំណត់ហេតុនៃរាជវង្ស តាំងសរសេររវាងឆ្នាំ ៨០៦ និង ឆ្នាំ ៨២០ ។

ទូតខ្មែរយើងបានអញ្ជើញទៅកាន់ស្រុកចិន នៅឆ្នាំ ៨១៣ ។ រាជទូតខាងលើនេះ គឺជារាជទូតរបស់ ចេនឡាទឹក ។

ចំពោះការបង្រួបបង្រួម ចេនឡាទាំងពីរ បានជាស្ថាពរនេះ តាមពិតគឺជាស្នាព្រះហស្តរបស់ព្រះបាទ ឥន្ទ្រវរ្ម័ន ដែលបានបន្សល់សិលាចារឹកមួយនៅឆ្នាំ ៨៦៦នាខេត្តរ្វុប៊ុន ប្រទេស សៀម ។

## ចប្បធម៌ - អារ្យធម៌ នៃ នគរភ្នំ និង ចេនឡា

សេចក្តីផ្តើម :

ការសិក្សាបុរាណវត្ថុ និងកំណត់ហេតុចិនព្រមទាំងសិលាចារឹក អាចឆ្លុះអោយយើងឃើញយ៉ាងច្បាស់លាស់ នូវលក្ខណៈរបស់វប្បធម៌ - អារ្យធម៌ខ្មែរសម័យ



www.budinst.gov.kh www.elibraryofcambodia.org

នគរភ្នំ និង ចេនឡា ដែលជាមូលដ្ឋានវប្បធម៌-អារ្យធម៌ខ្មែរសម័យមុនអង្គរ សម័យអង្គរ និងសម័យក្រោយអង្គរ ឬក៏សម័យបច្ចុប្បន្ននេះ ។

សូមរំលឹកឡើងវិញថា ប្រទេសខ្មែរយើងនៅគ្រាដំបូងបង្អស់បានទទួលអនុភាពវប្បធម៌ក្លឹង្គយ៉ាងសកម្ម ជាហេតុដែលញ៉ាំងអោយបុព្វបុរសខ្មែរជំនាន់នោះកាន់ប្រពៃណី ទំនៀមទម្លាប់បែបឥណ្ឌាជាច្រើន ដែលរកានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុតនឹងផ្នែកជំនឿសាសនា ។

លើសពីនេះទៀត របៀបរៀបចំនយោបាយ ក៏តាមបែបឥណ្ឌាដែរ ។ គួរគប្បីសង្កេតឃើញថា ចាប់តាំងពីនោះមក ខ្មែរយើងបានស្គាល់នូវការល្អតលោស់គ្រប់វិស័យ ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

១_ ផ្នែកសាសនា :

សូមបញ្ជាក់ថា ខ្មែរយើងនៅជំនាន់នោះ ប្រារព្ធជឿសាសនា សិល្បៈឯកសារចិន ក្លឹង្គទាំងពីរ គឺ ព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនា ដែលមានគណៈពីរ គឺ ហីនយាន " *វបភាព* " មហាយាន " *វបភាព* " ដែលប្រើភាសាសំស្ក្រឹត ។

ចំពោះអនុភាពរបស់ ព្រះពុទ្ធសាសនា លើសង្គមខ្មែរយើង អាចយក សិល្បៈកម្ម ដែលគេរកឃើញក្នុងទីតាំងនានាក្នុងព្រះរាជាណាចក្រខ្មែរបុរាណ ជាភស្តុតាង ។ ប្រភពឯកសារមួយប្រភពទៀត ដែលយើងគួរចាប់អារម្មណ៍ដែរ ព្រោះជាមូលដ្ឋាននៃប្រវត្តិសាស្ត្រជាតិយើង គឺ សិលាចារឹកដែលបំភ្លឺយើង នូវជំនឿបុរាណ



www.budinst.gov.kh www.elibraryofcambodia.org

និងចំនៀមទម្លាប់ទាក់ទងនឹងជំនឿ ។

ម៉្យាងទៀត ពង្សាវតារនៃរាជវង្សចិនអានា ក៏អាចជាជំនួយមួយយ៉ាងធំដែរ ផ្នែកសាសនារបស់ជនជាតិខ្មែរបុរាណ ។ ចំណុចមួយទៀតដែលយើងគួរកត់ត្រាគឺសាសនាក្តីងទាំងពីរ ដែលអ្នកដឹកនាំខ្មែរ ចាត់ទុកជាជាតសាសនាជាតិរបស់ខ្លួន មានជីវិតរស់នៅលើទឹកដីខ្មែរ ក្នុងភាតរភាព និង សមភាព ពោលគឺគ្មានភាពអមិត្ត ឬ ប្រទូស្តរ៉ាយ ។ ម៉្យាងទៀតសាសនាក្តីងនេះហើយជារូបមន្តមួយសំរាប់បង្រួបបង្រួមប្រជាពលរដ្ឋជាធ្លុងមួយ ក្រោមការដឹកនាំរបស់ស្តេចខ្មែរ ។

សូមបញ្ជាក់ត្រង់នេះថា ព្រហ្មញ្ញសាសនាបានផ្សព្វផ្សាយចូលមកដល់នគរភ្នំ ជាមួយព្រះពុទ្ធសាសនា តាមរយៈពួកឈ្មួញក្លីង្គ ។ ព្រហ្មញ្ញសាសនា ជាពហុ-ទេវនិយម ខុសពីឯកទេវនិយម ពីព្រោះគេមានជំនឿទៅលើទេវតាជាច្រើនអង្គ ដូចជាព្រះព្រហ្ម ព្រះវិស្ណុ និង ព្រះសិវៈ " *ត្រីមូតិ* " ព្រមទាំងទេវតារងជាច្រើនទៀតដូចជា ព្រះឥន្ទ្រ ព្រះអគ្គី " *អគ្គី* " ព្រះវរុណ ព្រះសូរ្យ ព្រះច័ន្ទ្រ ព្រះយម ព្រះវាយុ ។ ល ។

ក្នុងព្រហ្មញ្ញសាសនាគេជឿថា លោកយើងនេះកើតឡើងដោយសារអាទិទេព ដូចជាបុរស ប្រជាបតិ ព្រហ្ម ។ ព្រះព្រហ្ម គឺ មហាអាទិទេព បង្កើតភ្លើង ខ្យល់ មនុស្ស រុក្ខជាតិ ធម្មជាតិ ។ ម៉្យាងទៀត គេជឿថា ភាវៈទាំងអស់ក្នុងលោកយើងនេះកើតឡើងដោយធាតុល្អិតល្អន់បរិសុទ្ធរបស់ ព្រះព្រហ្ម ដែលមានឈ្មោះថា ព្រហ្ម័ន ។ ក្រៅពីទស្សនៈនេះ គេមានជំនឿទៅលើអត្តន និង កម្មិន



www.budinst.gov.kh www.elibraryofcambodia.org

ដែលជាទ្រឹស្តីយ៉ាងសំខាន់បំផុត ។

តាមគម្ពីរ ឧបនិស័ទ្ធ ព្រហ្ម័ន សំគាល់នូវព្រលឹងសកល ឬមេព្រលឹង ហើយក្នុងព្រលឹងនេះ មានព្រលឹងតូចល្អិតនៅរួមជាមួយគឺអត្មែន ។ រីឯកម្មិន ឬ កម្ម គឺ អំពើអាក្រក់តាមកាយ - ចិត្ត ឬ វាចា ។ កម្មិនសំរាប់ពុទ្ធហេតុនៃការកើតស្លាប់ ជាអំពើដែលបន្តគ្នា ក្នុងការបង្កើតភាវៈគ្រប់បែបយ៉ាងទាំងអស់ ។ ម្យ៉ាងទៀតកម្មិន ក៏សំគាល់ផងដែរ នូវទំនាក់ទំនងរវាងអំពើនិងផល ពោលគឺអ្វីៗដែលធ្វើមិនសាបសូន្យ ឡើយ ។ លើសពីនេះទៀត កម្មិន សំគាល់ក៏ផ្តល់ផលដែលជារង្វាន់ ។

ដូច្នេះដើម្បីចាកផុតពីអវិជ្ជា ដែលជាប្រភពនៃសេចក្តីទុក្ខ ដែលធ្វើអោ យមនុស្សវិលកើតវិលស្លាប់ក្នុងវដ្តសង្សា គេត្រូវបន់ស្រន់បួងសួងអាទិទេព ដែលជាអ្ន បង្កើតលោក ឬជាម្ចាស់របស់ភាវៈទាំងអស់ ខុសពីព្រះពុទ្ធសាសនា ដែលជឿថាខ្លួ ត្រូវទីពឹងខ្លួន ហើយដើម្បីជៀសផុតពីសេចក្តីទុក្ខ ពោលគឺអវិជ្ជា គេត្រូវរកហេតុនិង ផលចំពោះសកម្មភាពទាំងឡាយណាដែលយើងប្រព្រឹត្ត ។



www.budinst.gov.kh www.elibraryofcambodia.org

## របៀបគ្រប់គ្រងរៀបចំស្រុកទេសសម័យ ចេនឡា

រីឯផ្នែកនយោបាយនិងផ្នែករដ្ឋបាលខ្មែរនាសម័យ ចេនឡាវិញ នាដើមសតវត្សទី ៧ យើងក៏នៅតែពឹងផ្អែកទាំងស្រុងទៅលើព្រះរាជពង្សាវតារ ស៊ូដដែល ដែលចំលងដោយលោក ម៉ាតួនលិន ក្នុងសៀវភៅរបស់លោកគឺ ការសិក្សាប្រជារាស្ត្រនៅស្រុកចិន ។

ព្រះបាទ ឦសានវរ្ម័នទី ១ គង់នៅទីក្រុង អ៊ីស្វូណោ " *ឦសានបុរៈ* " ដែលមានប្រជាពលរដ្ឋចំនួនជាងពីរម៉ឺនគ្រួសារ ។ នៅកណ្តាលទីក្រុងនេះ មានអាគារមួយយ៉ាងធំ ដែលព្រះអង្គប្រទានសវនាការ ដោយមានការចូលរួមនៃពួកមន្ត្រីសេនាបតី ។ លើសពីនេះព្រះនគរនេះ នៅមានទីក្រុងធំៗចំនួន ៣០ ថែមទៀត ហើយនៅទីក្រុងនីមួយៗ មានប្រជាពលរដ្ឋរស់នៅរាប់ពាន់គ្រួសារ ដែលដឹកនាំដោយអភិបាលម្នាក់ ។ ឋានន្តរនាមរបស់មុខនាម៉ឺនមន្ត្រី មានដូចនៅប្រទេស លិនយី " *ចម្ប៉ា* " ដែរ ។

ក្នុងបីថ្ងៃម្តង ព្រះបាទ ឦសានវរ្ម័ន ទ្រង់យាងជាអធិបតីយ៉ាងតុគ្រឹកគគ្រេងមកសំណាង់ខាងលើនេះ ប្រទានសវនាការ ហើយព្រះអង្គគង់ប្រថាប់នៅក្នុងព្រះពន្លាមួយ ប្រកបដោយក្រណាត់ដ៏ល្អប្រណិត ។


www.budinst.gov.kh www.elibraryofcambodia.org

ព្រះពន្លានេះ មានសសរធ្វើអំពីឈើ មានឆ្លាក់ហើយជញ្ជាំងខ័ណ្ឌ លំអដោយក្បាច់រចនាធ្វើដោយភ្លុកដំរីព្រមទាំងផ្កាមាស ។

ព្រះទីនាំងនិងព្រះពន្លា មានសភាពដូចកូនព្រះរាជវាំងតូចមួយ ដែលនៅខាងក្រោយមានព្យួរនូវកងចក្រមួយ ដូចនៅ លោកនូ " *វែនទីក្រពេម* " ដែលមានកាំរស្មីមាស និងរាងជាអណ្តាតភ្លើង ។ មានភាជន៍មាសមួយ សម្រាប់ដុតគ្រឿងក្រអូបស្ថិតនៅចំព្រះទីនាំងនិងព្រះពន្លា ហើយមានមនុស្សពីរនាក់ថែរក្សាភាជន៍នេះ ។

ស្តេចពាក់ខ្សែក្រវាត់សំឡីមួយ " *គីពៃ* " ពណ៌ក្រហមភ្លៅធ្លាក់ដល់ជើង ។ ព្រះអង្គពាក់កាតីបមួយ លំអដោយគ្រឿងមាស ត្បូង និងបន្ទោងគុជ ស្បែកជើងសង្រែករបស់ព្រះអង្គដែលពាក់នៅជើង ព្រះអង្គធ្វើអំពីស្បែកសត្វ ជួនកាលអំពីភ្លុកដំរី ។ នៅត្រចៀករបស់ព្រះអង្គមានទំហ៊ូមាស ។

ព្រះអង្គពាក់អាវផាយ កាត់ដោយក្រណាត់សរប៉ុន្តែល្អោះ ពេទ្យ កាលបើព្រះ-អង្គមានព្រះកេសទទេ គេមិនឃើញត្បូងពេជ្រនៅលើព្រះកេសាទេ ។ សម្លៀកបំពាក់របស់នាម៉ឺនជាន់ខ្ពស់ មានលក្ខណៈដូចសម្លៀកបំពាក់របស់ព្រះអង្គដែរ ។ នាម៉ឺនជាន់ខ្ពស់ ឬរដ្ឋមន្ត្រីមានចំនួនប្រាំនាក់ ។ រដ្ឋមន្ត្រីទី ១ មានឋានន្តរនាម តូឡូយីរ " *ត្រូ* " ឋានន្តរនាមរបស់មន្ត្រី ៤ នាក់ទៀត តាមលំដាប់បុខងារ ពីធំដល់តូចគឺ សៀងកៅពីន ប៉ូហ្វូតូលីន តូម៉ូលីន និ ង សានឡូលោ ។ រីឯភ្នាក់ងារថ្នាក់ទាបវិញមានចំនួនយ៉ាងច្រើនអនេក ។

ពេលគាល់ស្តេចម្តង១ រដ្ឋមន្ត្រីត្រូវក្រាបថ្វាយបង្គំព្រះអង្គ ដោយថ្វាសមើសដី



www.budinst.gov.kh www.elibraryofcambodia.org

តម្រប់បិដងនៅខាងក្រោមកាំជណ្តើរនៃព្រះរាជបល្ល័ង្ក ។ បើព្រះអង្គទ្រង់ត្រាស់បញ្ជាហៅពួកនាម៉ឺនមន្ត្រីអោយឡើងគាល់ព្រះអង្គ ដែលគង់ប្រថាប់នៅលើបល្ល័ង្ក ពួកនាម៉ឺនមុខមន្ត្រីត្រូវលុតជង្គង់ ហើយអោបដៃប្រណមដោយគោរព ។ បន្ទាប់មកគេអង្គុយ ដឹកង់គ្នាជារង្វង់មូលជុំវិញព្រះរាជា ហើយគេពិភាក្សាដោះស្រាយបញ្ហាស្រុកទេស ។ កាលណាព្រះអង្គប្រជុំចប់សព្វគ្រប់ គេក៏លុតជង្គង់ម្តងទៀត ហើយក្រាបថ្វាយបង្គំសំពះលាព្រះអង្គ ។

ក្នុងព្រះរាជវាំង មានឆ្មាំចំនួនជាងមួយពាន់នាក់ ដែលពាក់អាវក្រោះ ហើយប្រដាប់ដោយលំពែង ដែលគេរៀបដាក់ជាជួរបញ្ឈរតាមកាំជណ្តើរព្រះរាជបល្ល័ង្ក ក្នុងអាគារនានានៃព្រះរាជវាំង នៅតាមទ្វារនិងអាគារនានា ដែលបាំងដោយជួរសសរម្ខាងជញ្ជាំងម្ខាង ។ល។

ទំនៀមទម្លាប់អ្នកស្រុក គឺដើរប្រដាប់ដោយអាវក្រោះនិងអាវុធជានិច្ច ដូច្នេះសូម្បីតែឈ្លោះគ្នាបន្តិចបន្តួច ក៏បណ្តាលអោយមានការប្រយុទ្ធបង្ហូរឈាម ភ្លាមមួយរំពេចដែរ ។

ចំពោះការផ្ទេររាជសម្បត្តិ " គឺមានតែព្រះឱរសនៃព្រះមហាក្សត្រិយានី ដែលជាព្រះអគ្គមហេសីពេញលក្ខណៈច្បាប់ទេដែលត្រូវឡើងគ្រងរាជ្យជំនួសព្រះបិតា ។ នៅថ្ងៃប្រារព្ធពិធីអភិសេក ស្តេចគ្រងរាជ្យថ្មី តែងធ្វើកាយវិកលកម្ម ទៅលើព្រះអនុជរបស់ព្រះអង្គទាំងអស់ ដោយខ្លះត្រូវព្រះអង្គបញ្ជាអោយគេដកម្រាមដៃ ខ្លះត្រូវគេកាត់ច្រមុះ ។ រួចពីនេះ គេយកទៅឃុំទុកនៅកន្លែង មិនមែន១ឆ្ងាយពីគ្នា ។ គេគ្រាន់តែ



www.budinst.gov.kh www.elibraryofcambodia.org

ផ្គត់ផ្គង់ម្ហូបអាហារ និងសំភារៈប្រើប្រាស់ តែមិនអោយកាន់មុនងាររឿទាំងអស់ ។

មនុស្សមានមាឌតូចហើយសម្បុរខ្មៅ " *ស្រអែម* " តែភាគច្រើនស្រីមានសម្បុរស ។ ទាំងប្រុសទាំងស្រីគេសុទ្ធតែរុំតឬជ្រងសក់ឡើងលើ " *ប្ញងសក់* " ហើយថែមទាំងពាក់ទំហ៊ូផង ។ ផ្ទះសម្បែងគ្រឿងប្រើប្រាស់របស់គេ មានលក្ខណៈដូចនៅស្រុក ឈេម្ង ដែរ ។ គេចាត់ទុកថាដៃស្តាំបរិសុទ្ធដោយដៃឆ្វេងមិនបរិសុទ្ធ ។ រៀងរាល់ព្រឹកគេជំរះកាយ ដុះធ្មេញនិងសំបកស្លា ហើយចូលចិត្ត អានសៀវភៅធម៌ និងសូត្រធម៌ ។ មុននិងបរិភោគអាហារគេដុសលាងខ្លួនប្រាណសាជាថ្មី ហើយក្រោយពីទទួលទានបាយរួចហើយ គេចាក់ធ្មេញ ឬសូត្រធម៌ថែមទៀត ។ ក្នុងម្ហូបអាហារគេចូលចិត្តប្រើខ្លាញ់ ទឹកដោះខន់ ស្ករគ្រាប់ម្សៅ បាយ ហើយនិង បាយដំណើបដែលគេចូតជាពំនូត សម្រាប់យកមកទទួលទាន ដោយជ្រលក់ក្នុងខ្ទិះសាច់ មុនពេលបរិភោគម្តង១ ។

ក្នុងពិធីមង្គលការ ឯកសារចិនបន្ថែមទៀតថា : " ប្រុសណាដែលចង់បានប្រពន្ធ ត្រូវលើកជំនូន ជូនទៅស្រីដែលខ្លួនស្រលាញ់ ប្រាថ្នាចង់បានជាភរិយា ។ បន្ទាប់មកឪពុកម្តាយខាងស្រី កំណត់ថ្ងៃមានឫទ្ធិ ដើម្បីនាំកូនក្រមុំរបស់ខ្លួនទៅផ្ទះខាងប្តីដោយមានអ្នកចែចូវជាអ្នកនាំផ្លូវ ។ កម្លុងរៀបការ គ្រួសារខាងប្តីនិងខាងប្រពន្ធ នៅក្នុងគេហដ្ឋានអស់រយៈពេល ៨ ថ្ងៃ ដោយពុំដើរចេញទៅខាងក្រៅឡើយ ។ ថ្ងៃក៏ដូចយប់ គេដុតចង្កៀងមិនអោយរលត់ ។

កាលណាពិធីមង្គលការចប់សព្វគ្រប់ហើយ ប្តីទទួលមតិកមួយភាគពីឪពុក ម្តាយ



www.budinst.gov.kh www.elibraryofcambodia.org

របស់ខ្លួន ហើយគេក៏នាំប្រពន្ធរបស់គេទៅនៅផ្ទះដោយឡែក ។

ដល់ពេលឪពុកម្តាយទទួលអនិច្ចកម្មទៅ ប្រសិនជាកូន១មិនទាន់គ្រប់វ័យមានគូស្រករនៅឡើយ ទ្រព្យសម្បត្តិត្រូវបានទៅកូនទាំងអស់នោះ តែប្រសិនបើកូនទាំងអស់នោះមានប្តីប្រពន្ធហើយ ថែមទាំងមានធនធានស្តុកស្តម្ភផង ទ្រព្យសម្បត្តិរបស់ ឪពុកម្តាយ ត្រូវប្រគល់ទៅឃ្លាំងប្រាក់ជាតិ ។

ក្នុងពិធីបុណ្យបូជាសព ត្រូវអត់បាយ ៧ ថ្ងៃ កោរសក់សំរាប់កាន់មរណៈទុក្ខហើយត្រូវទ្រហោយំ ។ ក្រុមគ្រួសាររបស់អ្នកចែកស្ថាន ក្រោមអធិបតីភាពរបស់ព្រះភិក្ខុនិងព្រះភិក្ខុនីនៃព្រះពុទ្ធសាសនា ហែសពដោយមានសូត្រធម៌អភិធម្ម និង លេងភ្លេងខ្មោចផង ។ សពត្រូវគេបូជាក្នុងបច្ឆា សង់ដោយឈើក្រអូបច្រើនយ៉ាង ។ រួចគេរើសធាតុដាក់ក្នុងកោដ្ឋមាសឬប្រាក់ ហើយគេយកទៅទម្លាក់ក្នុងទឹកយ៉ាងជ្រៅ ។ អ្នកក្រីក្រគេប្រើកោដ្ឋធ្វើអំពីដីដុត ដោយមានលាបពណ៌ផ្សេង១ ។ មានមនុស្សខ្លះគេគ្រាន់តែយកសពទៅដាក់ចោលក្នុងព្រៃស្មសានទុកអោយសត្វព្រៃស៊ីជាអាហារ ។

## ធំនៀមធម្លាប់ប្រពៃណី

អាងទៅលើកំណត់ហេតុចិន និងបុរាណវត្ថុ យើងអាចដឹងថា ក្លិង្គមិនមែនជា



www.budinst.gov.kh www.elibraryofcambodia.org

អ្នកបង្ហាត់បង្រៀនខ្មែរអោយចេះស្លៀកពាក់ដូចគេបានពេលនោះទេ តាមពិតគឺគ្រាន់តែបង្ហាត់អោយខ្មែរស្លៀកពាក់ តាមលក្ខណៈឥណ្ឌាប៉ុណ្ណោះ ដូចជាស្លៀកចងក្បិនការប្រើសំពត់ចរបាប់ ការតុបតែងដោយប្រើគ្រឿងអលង្ការ សម្រាប់ព្រះ រាជា ឬអ្នកតន្ត្រី ។ ល ។ ដូចជាម្កុដ ខ្សែ ក ខ្សែដៃ ខ្សែរសង្វា ។ ល ។

ម្យ៉ាងទៀតគេក៏អាចសំគាល់បានដែរ នូវទំនៀមទម្លាប់ខ្លះៗទៀតនៃសម័យនោះ ដែលមានដូចខាងក្រោមនេះ ។

- ពិធីបូជាសព ខុសពីសម័យបុរេប្រវត្តិ ដែលកុលសម្ព័ន្ធខ្មែរ-មន កប់ខ្មោច ក្នុងសម័យនេះគេបូជាសពដូចជាភ្លើង ។

ម្យ៉ាងទៀតខ្មែរយើងជំនាន់នោះ ក៏មានទម្លាប់ចោលសពក្នុងទន្លេឬទុកអោយបក្សីឬសត្វសាហាវស៊ីដែរ ។ ទំនៀមនេះពឹងផ្អែកទៅលើសាសនា ជាពិសេសទៅលើទ្រឹស្តីបុណ្យឬកុសលជា មូលដ្ឋាននៃសាសនាឥណ្ឌា ។

យើងក៏អាចដឹងយ៉ាង ប្រាកដដែរថាស្ត្រីខ្មែរចេះនិយមស៊ីស្លាម្លូ ហើយនាសម័យនោះ ។ ក្រៅពីនេះគេអាចកត់សំគាល់ផងដែរ នូវការរាំរែក , ការលោតខ្សែរព្ធ ដែលជាទំនៀមទម្លាប់ប្រជាប្រិយប្រចាំស្រុក ។

**សម័យនគរភ្នំ :**



www.budinst.gov.kh www.elibraryofcambodia.org

ប្រទេសខ្មែរនាសម័យនគរភ្នំ តាមលោក កាំង ថៃ និងលោក ជូ អ៊ីង មានក្រុងព័ទ្ធជុំវិញដោយលំពែង មានព្រះរាជវាំង និងអ្នកស្រុក ។" *ចំពោះចិន ដែលមានរាងកាយខុសខ្មែរ ហើយមានស្បែក ស* " ប្រជាជនខ្មែរមានមុខមាត អាក្រក់ " សាច់ខ្មៅស្រអែម សក់រួញ ។ " *ខ្មែរជំនាន់នោះ* " ស្រីស្លៀកសំពត់ប្រុសស្លៀកប៉ុង តែចំពោះខ្មែរ" *មិនស្លៀកពាក់ខោអាវដូចចិនទេ* " និងដើរដោយជើងទទេ ។ ប្រ-កបដោយអធ្យាស្រ័យល្អ ហើយចិត្តគំនិតក៏ស្លូតបូត " *ខ្មែរ* " មិនចេះលួចប្លន់ ។ *គេ* " សាបព្រោះតែម្តងក្នុងមួយឆ្នាំ បណ្តុះដាំ លទ្ធផលដែលបានមកអាចទប់ទល់ទៅដល់បីរដូវ ។ គេចូលចិត្តឆ្លាក់ជាក្បាច់ក្បូរប្រដាប់ប្រដាប្រើប្រាស់និងឆ្លាក់ភាជន៍ សំ-រាប់ទទួលមានអាហារ ដោយប្រាក់ ។ ដើម្បីបង់ពន្ធដារ " *ទៅរដ្ឋ* " គេបង់ជាមាស ប្រាក់ គ្រឿងក្រអូប ។ ខ្មែរមានសៀវភៅបណ្ណាល័យ កំណត់ហេតុ និងរបស់ផ្សេងៗទៀតជាច្រើន ។ រីឯតួអក្សរដែលគេប្រើ មានលក្ខណៈស្រដៀងនឹងតួអក្សររបស់ជនជាតិហ្វូ " ឥណ្ឌា" ។

ម៉្យាងទៀតកំណត់ហេតុរបស់រាជវង្សស៊ុី ភាគខាងត្បូងនៃ ប្រទេស ចិន ក៏បានបន្ថែមទៀតថា " *ប្រជាជននគរភ្នំកាចសាហាវ ហើយចិត្តមិនទៀងត្រង់* " ។ គេចូលចិត្តធ្វើការវាយសំរុកទៅលើក្រុងជិតខាង ដែលមិនព្រមរណប ហើយសង្កត់សង្កិនប្រជារាស្ត្រ ដើម្បីយកមាសប្រាក់ ។ ដើម្បីបង់ថ្លៃទំនិញ គេប្រើប្រាស់មាសប្រាក់ ឬសំពត់សូត្រ ។ មនុស្សដែលមានត្រកូលខ្ពស់ ស្លៀកសារុងធ្វើអំពីសំពត់ចរបាប់ ។



www.budinst.gov.kh www.elibraryofcambodia.org

ឯស្ត្រីភេទវិញ ស្លៀកសំពត់បញ្ច្រកពីលើក្បាល មានអ្នកខ្លះទៀតស្លៀកប៉ឹង ដែលជាសំពត់មួយផ្ទាំងតូច " *សំរាប់ពិទពាំងនៅពីមុខកេរ្តិ៍ ខ្មាស់* " ចំពោះអាកប្បកិរិយាមិនគួរគប្បីរបស់ខ្មែរខាងលើនេះ គួរបញ្ជាក់ថា ជាការធម្មតាទេ ដែលលក្ខណៈវប្បធម៌ ឬទំនៀមទម្លាប់ប្រពៃណី ពីសង្គមមួយទៅសង្គមមួយមានលក្ខណៈខុសៗគ្នាទាំងអស់ ។ យ៉ាងណាមិញអ្វីៗដែលអាក្រក់ចំពោះចិន មិនមែនមានន័យថាអាក្រក់ចំពោះខ្មែរទេ ។ ផ្ទុយទៅវិញ អ្វីៗដែលអាក្រក់ចំពោះខ្មែរ មិនមែនមានន័យថាអាក្រក់ចំពោះចិនទេ ។ ដោយហេតុថាការអោយតម្លៃខុសគ្នាឬផ្ទុយគ្នា ។ សេចក្ដីសន្និដ្ឋានតាមចិន ស្ដីពីជីវិតខ្មែរ មិនស្របតាមលក្ខណៈវិទ្យាសាស្ត្រ ។

ខ្មែរជំនាន់នោះមានជំនឿងប់ទៅលើការស្បថស្បែរ ឬវិធីផ្សេងៗ ឧទាហរណ៍ៈ *ដើម្បីសំដែងនូវការស្មោះត្រង់បរិសុទ្ធ អ្នកជាប់ចោទត្រូវកាន់ដែកមួយដុំ ដែលត្រូវគេដុតអោយក្រហមឆ្អៅនៅដៃហើយដើរ ៧ ជំហាន ហើយបោះដែកនោះទៅក្នុងឆ្នាំងទឹកក្តៅ ។ បើប្រសិនជាអ្នកជាប់ចោទនេះជាអ្នកស្លូតត្រង់មែន គេអាចលូកដៃនោះទៅចាប់យកដែកនោះពីឆ្នាំងដោយមិនរលាកដៃ ។* សូមបញ្ជាក់ថាៈ ទំនៀមនេះនៅរស់រវើកដល់សព្វថ្ងៃនេះ ឧទាហរណ៍ៈ *គេលោកសំណដាក់ក្នុងឆ្នាំងដាំអោយពុះ បើអ្នកប្រព្រឹត្តអំពើអយុត្តិធម៌ ពេលលូកដៃចូលដល់ក្នុងឆ្នាំង សំណមិនលោតពោងដៃទេ ។* ចំពោះទំនៀមទំលាប់ខ្មែរសម័យនោះយើងអាចកត់សំគាល់ទៅលើពិធីផ្សេងៗទៀតដូចជា ពិធីអភិសេកស្តេច ពិធីរអភិសេក ឬបើកភ្នែកទេវរូប ឬពុទ្ធរូប ពិធីច្រត់ព្រះនង្គ័ល ពិធីភោរជុក ពិធីបញ្ចុះសីមា ។ល។



www.budinst.gov.kh www.elibraryofcambodia.org

ឯកសារចិនបានអោយពតិមានថា ៖ " រាស្ត្រនៃនគរភ្នំសិតចិញ្ចៀន និង កាខ្សែដោយមាស ។ គេធ្វើភាជន៍ដោយប្រាក់ ។ គេកាប់ដើមឈើយកមកសង់ផ្ទះសំវែង ។ ព្រះរាជាគង់ក្នុងដំណាក់ធ្វើអំពីឈើដែលមានច្រើនជាន់ ។ ផ្ទះអ្នកស្រុកធ្វើអំពីឈើ ដែលមានរបងព័ទ្ធជុំវិញផង ។ នៅតាមមាត់ទន្លេ គេឃើញមានគុម្ពឫស្សីធំៗ ជាច្រើនដែលមានស្លឹកវែងប្រមាណប្រាំបីឬប្រាំហ្វូតដុះ ។ ប្រជាជនក្រងស្លឹកឫស្សីទាំងនេះ ដើម្បីយកមកប្រក់ដំបូលផ្ទះរបស់គេដែលសង់ខ្ពស់ផុតពីដី គេមានទូកវែងប្រមាណ ៨៥ចាំង " *១ចាំងស្មើ ១០ហ្វូត* " ។ ទទឹងរបស់ទូក ៦_៧ ហ្វូត ក្បាលនិងកន្ទុយទូកមានរាងដូចក្បាលនិងកន្ទុយត្រី " *នាគ ?* " ។ ពេលព្រះរាជាស្តេចយាងចេញទៅក្រៅព្រះរាជវាំងម្តងៗ ព្រះអង្គទ្រង់ប្រថាប់ដំរី ។ ស្ត្រីក៏អាចជិះដំរីបានដែរ ល្បែងកំសាន្តមានការជល់មាន់ និង ជល់ជ្រូក ។ ក្នុងអាណាចក្រភ្នំ គ្មានពន្ធនាគារ រីឯការពិភាក្សាកាត់ក្តី " *គេពោះចិញ្ចៀនមាស ឬ ពងមាន់ចុះទៅក្នុងទឹកក្តៅកំពុងពុះ ហើយអោយគូវិវាទចាប់យកចេញពីក្នុងទឹកពុះ ។ ជនស្មោះត្រង់មិនរលាកដៃ ។ បើពុំដូច្នោះទេ គេដុតច្រវ៉ាក់អោយក្តៅ ហើយគូវិវាទកាន់ដើរទៅ ៧ ជំហាន ។ អ្នកដែលខុសត្រូវរលាកដៃ ។ រីឯអ្នកសុចរិតមិនមានគ្រោះភ័យអ្វីឡើយ ។ បើពុំដូច្នោះទេគេយកគូវិវាទទៅពោះក្នុងទឹក អ្នកដែលត្រង់មិនលិច អ្នកចិត្តវៀចវេរលិចចុះក្នុងទឹក ។*

រីឯកំណត់ហេតុចិនសម័យរាជវង្សលាង ក៏អានអោយយើងដឹងដែរថា នៅទីកន្លែងដែលប្រជាពលរដ្ឋភ្នំរស់នៅ គេមានជីកអណ្តូង និងស្រះទឹកសំរាប់ប្រើរួមគ្នាជា



www.budinst.gov.kh www.elibraryofcambodia.org

ច្រើនគ្រួសារ ។ ទំលាប់របស់ប្រជារាស្ត្រ គឺជំនឿទៅលើទេវតាដែលមានរូបធ្វើដោយសំរឹទ្ធ ។ បើរូបណាមានមុខរូបពីរ ត្រូវមានដៃបួន ។ បើរូបណាមានមុខបួនត្រូវមានដៃប្រាំបី ហើយនៃនិមួយៗកាន់របស់ផ្សេងៗគ្នា ដូចជា ក្អែង បក្សី ឬសត្វចតុប្បាទ ឬដួងព្រះអាទិត្យ ឬដួងព្រះច័ន្ទ ។ ចំពោះព្រះរាជា ពេលដែលស្តេចយាងចេញទៅក្រៅម្តងៗ ទ្រង់ប្រថាប់ដំរីដោយមានស្នាំកំណាន់ និង មន្ត្រីរាជតំណាក់ជិះដំរីជាមួយព្រះអង្គ ។ ពេលព្រះអង្គប្រថាប់ ព្រះអង្គផ្អែកលើព្រះខ្នើយទាំង បញ្ឈរជង្គង់

ស្តាំឡើង ហើយសណ្តូកជង្គង់ឆ្វេងអោយត្រង់ស្មើ មុខទីប្រថាប់មានសំពត់ ឈើគឺមានកែវមាសប្រកបដោយក្បូរក្បាច់រចនាជាផ្ការហូតទៅដល់គ្រឿងសំអាង មានគ្រឿងមានគ្រឿងក្រអូបផ្សេងទៀតផង ។ ក្នុងការកាន់មរណៈទុក្ខ គេកោរសក់ កោរពុកមាត់ ។ ចំពោះការបូជាសពមាន ៤ យ៉ាងតាមរបៀបឥណ្ឌាគឺ គេយកសពចោលក្នុងទឹក កប់ក្នុងដី បូជាភ្លើង និងយកសពទៅចោលក្នុងព្រៃអោយសត្វស៊ី ។ គួររំលឹកថាក្នុងកំណត់ហេតុរបស់ ម៉ាតួនលិន ក៏មានការអធិប្បាយ អំពីប្រពៃណីខ្មែរខ្លះៗដែរនាសម័យចេនឡា " ដើម្បីការកូនចៅមុនដំបូង គេជ្រើសរើសពេលវេលាល្អសំរាប់កំ-ណត់ថ្ងៃ " ។ មុនពេលការប្រាំថ្ងៃ គេធ្វើបុណ្យជប់លៀង ។ ថ្ងៃទី ៦ ឪពុកខាងកូនស្រីដឹកដៃកូនក្រមុំ យកទៅប្រគល់ជូនកូនប្រសា ថ្ងៃទី ៧ គឺជាថ្ងៃដែលគេបញ្ចប់ពិធីអាពាហ៍ពិពាហ៍ ។

ក្រោយពិធីនេះបានចប់សព្វគ្រប់ហើយ ភ្ញៀវបែកគ្នា ។ រីឯគូស្វាម៉ីភរិយា



www.budinst.gov.kh www.elibraryofcambodia.org

វិញគេនាំគ្នានៅឆ្ងាយពីឪពុកម្តាយ បើកលែងតែល្អឹកណា ដែរឪពុកខាងប្រុសមិនទាន់បាត់បង់ជីវិត ។

ពេលដែលឪពុកម្តាយទទួលមរណភាពទៅ កូន១ការសក់ កាន់ទុក្ខដោយស្លៀកពាក់ស ។ គេសង់រោងមួយធ្វើអំពីឫស្សី ខ្ពស់ពីទឹកសំរាប់ផ្ទុកឧសនិងតម្កល់សព ។ គេលើកទង់ព្រលឹងគេដុតសព ផ្សំជាមួយគ្រឿងក្រអូប គេផ្លុំស័ង្ខ គេវាយស្គរ ព្រមជាមួយគ្នានោះគេបង្កាត់ដុតឧសដែលគរលើសាកសព ហើយភ្លើងក៏ចាប់ឆេះសន្ធោសន្ធៅឡើង ។ នៅពីបញ្ចប់អ្វី១ក៏លិចក្នុងទឹក ។ ពិធីបូជាសពនេះ គ្មានការផ្លាស់ប្តូរអ្វីទេ ចំពោះនាម៉ឺនមន្ត្រី រាស្ត្រសាមញ្ញដែរ ។ តែចំពោះព្រះរាជាវិញ ពិធីនេះគ្រាន់តែមានសភាពអធិកអធមជាងប៉ុណ្ណោះ ហើយគេរើសព្រះអដ្ឋិធាតុដាក់ក្នុងកោដ្ឋមាសដើម្បីយកទៅតម្កល់ក្នុងប្រាសាទ ។

យើងត្រូវកត់សំគាល់ថា ក្នុងកំណាយ នៅបុរាណស្ថានអង្គរបុរី ឬ វ្យធបុរៈ គេឃើញមានសត្វអច្ឆរិយជាច្រើន ( Bestiaire sacré ) ដែលជាសត្វស្រុកដូចជា សត្វគោ កណ្តុរ អណ្តើក គោ មាន់ កូនក្រួច ដំរី ទន្សាយ ស្វា សេះ ត្រីផ្សោត ជាដើម ដែលធ្វើអំពីដីដុត ហើយដែលជានិមិត្តរូបនៃភាពត្រជាក់ត្រជុំ ឬ សិរីមង្គល ឬ ក៏ឥទ្ធិពលនៃធម្មជាតិ ដែលជាប្រភពនៃជីវិត ។ សូមបញ្ជាក់បន្ថែមថា ៖ ខ្មែរបុរាណមិនមែន គោរពបូជាសត្វដោយងងឹតងងុលទេ គេបូជាសត្វក៏ដោយសារនិមិត្តរូប



www.budinst.gov.kh www.elibraryofcambodia.org

ដែលតំណាងសត្វទាំងអស់នោះ ដូចជាទឹក ដី ភ្លើង ខ្យល់ ។

ក្រៅពីនេះ យើងមានឃើញ នូវសត្វអច្ឆរិយ ដែលមានក្នុងទេវកថា ( mythologie indienne ) ដែលបានហូរចូលស្រុកខ្មែរព្រមគ្នា និង សាសនាក្លីង្គ ដូចជាហង្ស គ្រុឌ រាជសី ហនុមាន មករ ។ ល ។

អ្វីទេ ចំពោះនាម៉ឺនមន្ត្រី រាស្ត្រសាមញ្ញដែរ ។ តែចំពោះព្រះរាជាវិញ ពិធីនេះគ្រាន់តែមានសភាពអធិករធមជាងប៉ុណ្ណោះ ហើយគេរើសព្រះអដ្ឋិធាតុដាក់ក្នុងកោដ្ឋមាស ដើម្បីយកទៅតម្កល់ក្នុងប្រាសាទ ។

យើងត្រូវកត់សំគាល់ថា ក្នុងកំណាយ នៅបុរាណស្ថានអង្គរបុរី ឬ វ្យាធបុរៈ គេឃើញមានសត្វអច្ឆរិយជាច្រើន ( Bestiaire sacré ) ដែលជាសត្វស្រុក ដូចជា សត្វគោ កណ្ដុរ អណ្ដើក គោ មាន់ កូនក្រួច ដំរី ទន្សាយ ស្វា សេះ ត្រីផ្សោត ជាដើម ដែលធ្វើអំពីដីដុត ហើយដែលជានិមិត្តរូបនៃភាពត្រជាក់ត្រជុំ ឬ សិរីមង្គល ឬ ក៏ឥទ្ធិពលនៃធម្មជាតិ ដែលជាប្រភពនៃជីវិត ។ សូមបញ្ជាក់បន្ថែមថា : ខ្មែរបុរាណមិនមែន គោរពបូជាសត្វដោយងងឹតងងុលទេ គេបូជាសត្វក៏ដោយសារនិមិត្តរូប ដែលតំណាងសត្វទាំងអស់នោះ ដូចជាទឹក ដី ភ្លើង ខ្យល់ ។

ក្រៅពីនេះ យើងមានឃើញ នូវសត្វអច្ឆរិយ ដែលមានក្នុងទេវកថា ( mythologie indienne ) ដែលបានហូរចូលស្រុកខ្មែរព្រមគ្នា និង សាសនាក្លីង្គ ដូចជាហង្ស គ្រុឌ រាជសី ហនុមាន មករ ។ ល ។ ដែលបានហូរចូលស្រុកខ្មែរព្រមគ្នាជាមួយនឹងក្បួនខ្នាត នៃសាសនាក្លីង្គ ។



www.budinst.gov.kh www.elibraryofcambodia.org

# ពិស័យអក្សរសិល្ប៍

វប្បធម៌ខ្មែរសម័យនគរភ្នំ និង សម័យចេនឡា ជាវប្បធម៌សំស្ក្រឹត ការសិក្សាសិលាចារឹក និង កំណត់ហេតុចិន បានបង្ហាញឱ្យយើងដឹងថា ភាសាសំស្ក្រឹតជាភាសា ដែលគេប្រើជាផ្លូវការក្នុងសម័យនោះ ។ រីឯប្រជាពលរដ្ឋវិញប្រើភាសាដែលស្ថិតក្នុងអំបូរ ខ្មែរ_មន គឺភាសាខ្មែរ ។ ចំពោះបញ្ហានេះ ផ្ទាំងសិលាចារឹក នៅអង្គបុរីដែលបានប្រតិស្ឋានឡើងនៅឆ្នាំ ៦១២ នៃគ្រិស្តសករាជ ជាភស្តុតាងស្រាប់ ។

ដោយអាស្រ័យហេតុនេះហើយ បានជាយើងហ៊ានចាត់ទុកថា ខ្មែរមានអក្សរសិល្ប៍ប្រចាំជាតិរបស់ខ្លួនហើយ ។ មយ៉ាងទៀតគេក៏ត្រូវបញ្ចូលដែរ ក្នុងវិស័យអក្សរសិល្ប៍ខ្មែរ នូវផ្ទាំងសិលាចារឹក វ៉ូកាញ់ ដែលត្រូវចារឡើងនៅសតវត្សទី ៣ នៃគ.ស ហើយដែលជាសិលាចារឹកខ្មែរចាស់ជាងគេបំផុត ។

មយ៉ាងទៀតដោយសំអាងទៅលើ វត្ថុបុរាណជាច្រើនដូចជាមាសសន្លឹកដែលមានឆ្លាក់ រូបស្វា ហនុមាន ឬរូបព្រះពលរាម ព្រះលក្ស្មណ៍ធ្វើអំពីថ្ម ដែលស្ថិតក្នុងរចនាបទភ្នំដា ចុងសតវត្សទី ៥ ដើមសតវត្សទី ៦ នៃគ.ស យើងអាចសន្និដ្ឋានថា ខ្មែរយើងបានស្គាល់រឿង រាមកេរ្តិ៍ តាំងតែពីសម័យនោះ រហូតដល់សព្វថ្ងៃម្លេះ ។

រួមសេចក្តីមក ពីសតវត្សទី ១ ដល់សតវត្សទី ៦ នៃ គ.ស ភាសាដែលគេ



www.budinst.gov.kh www.elibraryofcambodia.org

ប្រើតាមផ្លូវការ គឺជាភាសាសំស្ក្រឹត ។ រីឯភាសាបាលីវិញក៏ត្រូវគេចាប់ផ្តើមប្រើដែរ តែក្រោយនេះបន្តិច ពោលគឺនៅដើមសតវត្សទី ៧ ដូចជាផ្ទាំងសិលាចារឹក ជាអក្សរបល្លវៈ ដែលគេបានរកឃើញនៅក្នុងអតីតខេត្តខ្មែរមួយ នៅព្រះរាជាណាចក្រថៃសព្វថ្ងៃនេះ គឺនៅស្រុក ស្រីមហាពោធិ នៃខេត្ត បច្ចុមបុរី ជាភស្តុតាងស្រាប់ ។ សូមជំរាបថា នៅទីនោះ នៅមានជនជាតិខ្មែររស់នៅយ៉ាងច្រើនកុះករ ហើយនៅនិយាយភាសាខ្មែរនៅឡើយ ស្ថាបត្យកម្ម ដូចជា ការកសាងប្រាសាទ និង រូបចម្លាក់គ្រប់ប្រភេទ ដែលផុសចេញពីជំនឿដ៏មាំមួន ទៅលើសាសនា ។ ផ្នែកស្ថាបត្យកម្មនៃសម័យនគរភ្នំ ដែលស្ថាបនាឡើងដោយឥដ្ឋ ហើយជាពិសេស ក្នុងរចនាបទភ្នំដា គ្មានប្រាសាទឯណាមួយទេ ដែលនៅស្ថិតស្ថេរគង់វង្សរហូតដល់សព្វថ្ងៃនេះ ក្រៅពីប្រាសាទអាស្រមមហាឥសី ដែលសាងសង់អំពីថ្ម ។ ដើម្បីឈ្វេងយល់អំពីលក្ខណៈ របស់ប្រាសាទនាសម័យនោះ យើងត្រូវអញ្ជើញទៅខេត្តកំពតសព្វថ្ងៃយើងនេះ ទើបឃើញ ពីព្រោះថ្មីៗនេះ យើងបានស្រាវជ្រាវ រកឃើញ នូវប្រាសាទពីរ ដែលធ្វើអំពីឥដ្ឋ ហើយមានទ្រង់ទ្រាយ ប្រហាក់ប្រហែល និង អាស្រមមហាឥសី នៅស្រុកអង្គរបុរី នាខេត្ត តាកែវ ។ វត្តមានរបស់ប្រាសាទទាំងពីរនេះ ដែលសាងឡើងក្នុងវង្សភ្នំ ជាមរតកវប្បធម៌ ដែលយើងត្រូវតែថែរក្សាឱ្យបានគង់វង្ស ។ ក្រៅពីនេះ យើងបានជួបប្រទះតែខឿនសំណង់ ធ្វើអំពីឥដ្ឋ ដែលមានចំនួនច្រើនលើសលប់នៅ អូរកែវ ( កម្ពុជាក្រោម ) នៅខេត្ត យ៉ាឡា ប៉ាតានី ( សៀមសព្វថ្ងៃ ) និង នៅ ខេត្ត តាកែវ ស្វាយរៀង និង ព្រៃវែង ។ ល ។



www.budinst.gov.kh www.elibraryofcambodia.org

•

ក្រៅពីប្រាសាទដែលខ្មែរបានសាងឡើងនៅសម័យនគរភ្នំ ដោយឥដ្ឋ នៅមានការកសាងបដិមាករទៀត ដូចជា ព្រះកេស តំណាងព្រះពុទ្ធព្រះអង្គ នៅវត្ត រំលក តំបន់ភ្នំដា ខេត្ត តាកែវ ស្រុកព្រៃកប្បាស ព្រមទាំងរបស់ប្រើប្រាស់ដូចជា កាក់រូបព្រះ–អាទិត្យ ចិញ្ចៀនរូបគោ បន្តោងក ទំហ៊ូ ចង្រ្កង់ អាវុធ ។ ល ។

ម្យ៉ាងទៀតយើងនៅចាំបានថា ឯកសារចិន បាននិយាយអំពីការបូជា នៃព្រះ មហេស្វរៈ « *ភទ្រេស្វរៈ* » នៅលើកំពូលភ្នំលិន ប៉ូផូ « *លិង្គបវិត* » គឺវត្តភូនៅ នៅស្រុកលាវសព្វថ្ងៃនេះ ដែលជាមជ្ឈមណ្ឌលវប្បធម៌នាសម័យចេនឡា ។

ថ្មីៗនេះ ការរកឃើញ នៅស្រុកអង្គបុរី នូវឯកសារមួយចំនួនធំ ជាពិសេសព្រះបដិមាតំណាងព្រះពុទ្ធសាសនា បានបញ្ជាក់ឱ្យយើងដឹងថា ខ្មែរយើងបានទទួលឥទ្ធិ–ពលសិល្បៈបែប ហ្ក្រិចកូ – ឥណ្ឌា ( art gréco-indien ) នាសតវត្សទី ២–៣ នៃ គ.ស ពីទីក្រុង ហ្គែនដារា ( Gandhara ) ដែរ ។

សូមបញ្ជាក់ថា នាសម័យចេនឡា ការកសាងប្រាង្គប្រាសាទ មានភាពចំរើនល្អណាស់ ។ ប្រាសាទទាំងអស់នោះ លំអរទៅដោយក្បូរក្បាច់រចនា គ្រប់បែបយ៉ាងទាំងអស់ ដូចក្បាច់រឿងនៅលើផ្តែរ ក្បាច់ខ្សែរហៀន ក្បាច់ភ្ញីទេស ក្បាច់ស្លឹក–លាភ ក្បាច់ផ្កាច័ន្ទ នៅលើសសរពេជ្រ ។ ល ។

គឺនៅក្នុងសម័យនោះហើយ ដែលគេអាចឃើញ នូវប្រាសាទជាច្រើន ដូចជា ប្រាសាទសម្បូណ៌ព្រៃគុក ព្រះធាតុតូច ព្រះធាតុធំ ប្រាសាទប្រាំល្វែង



www.budinst.gov.kh www.elibraryofcambodia.org

( កម្ពុជាក្រោម ) ប្រាសាទស្រីទេព ប្រាសាទភ្នំមិត្តូន ( នៅសៀម ) ប្រាសាទព្រៃក្មេង ប្រាសាទភ្នំប្រាសាទ ប្រាសាទអណ្ដែត ប្រាសាទអកយំ ប្រាសាទបាសិទ្ធ ។

ឯវត្តអារាមវិញ ដែលស្ថាបនាដោយឈើ គេសង្កេតឃើញតែសំណល់ផ្ទាំងសីមាទេ ដូចជាផ្ទាំងសិលានៅលើភ្នំគូលេនជាដើម ដែលជាសក្ខីភាព ដ៏ជាក់ស្ដែងនៃការកសាងវត្តអារាម នាជំនាន់នោះ ។ វត្តមានរបស់សីមាទាំងនោះ មានប្រយោជន៍សម្រាប់យើងជាអនេក ពីព្រោះវាមិនគ្រាន់តែឆ្លុះបញ្ចាក់ជូនយើង នូវចំណាស់របស់ព្រះពុទ្ធសាសនានៅកម្ពុជាយើងតែប៉ុណ្ណោះទេ វាថែមទាំងបង្ហាញ នូវទំនាក់ទំនងផ្នែកសិល្បៈ និង សាសនា រវាងខ្មែរ និង បងប្អូនជនជាតិមន នៃទ្វារវតីផង ។

ទន្ទឹមជាមួយគ្នានេះ យើងក៏បាចកត់សំគាល់ដែរថា ការប្រើផ្ទាំងសិលាធំៗ សម្រាប់យកមកផ្លាក់ធ្វើជាសន្និកសីមាវត្ត គឺជាប្រពៃណីយ៍មួយ ដែលសេសសល់ពីសម័យបុរេប្រវត្តិសាស្ត្រ ដោយហេតុថាបុព្វបុរសខ្មែរ នាសម័យមុនកឹង្គចូលស្រុកក៏មានជំនឿលើភាពស័កសិទ្ធរបស់ថ្មរួចទៅហើយដែរ ។ ឧទាហរណ៍ជាក់ស្ដែង គឺគេបានលើកផ្ទាំងថ្មធំៗ បញ្ឈរឡើងជាជួរសម្រាប់គោរពសក្ការៈ នៅក្នុងភូមិភាគខាងត្បូងនៃស្រុកលាវបច្ចុប្បន្ន ។

មយ៉ាងទៀតគេអាចបញ្ចូលក្នុងលក្ខណៈសិល្បៈ ផ្នែកព្រះពុទ្ធសាសនាមហាយាន នូវរូបព្រះ អវលោកកេស្វរៈ នៅរ៉ាច់យ៉ា និង នៅកាប់សាំងហ្សក់ នៅកម្ពុជាក្រោម ។


www.budinst.gov.kh www.elibraryofcambodia.org

•

ចំណែកបដិមាសម័យចេនឡាវិញ ក៏មានលក្ខណៈមិនខុសពីជំនាន់មុនប៉ុន្មានដែរ ដូចជា ព្រះហរិហរៈ ( ព្រះវិស្ណុ និង ព្រះសិវៈ ) រួមគ្នា នៃប្រាសាទអណ្តែត ព្រះវិស្ណុ នៃអាស្រមមហាឥសី ព្រះវិស្ណុភ្នំដា ព្រះវិស្ណុទូលដៃប្អូន ព្រះកល្កិន ព្រះលក្ស្មី នៅពេល ព្រះសូរិយានៃប្រាសាទប្រាំល្វែង នៅកម្ពុជាក្រោម ព្រះលក្ស្មីនៃកោះគ្រៀង ខេត្ត ក្រចេះ ព្រះក្រឹស្ណគោវធន ភ្នំដា ។ ល ។



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# សង្គមខ្មែរ

ដូចបានពោលរួចមកហើយ ក្នុងសង្គមខ្មែរ នាសម័យនគរភ្នំ និងចេនឡាខ្មែរស្គាល់ នូវវណ្ណៈទាំងបួន តែការបែងចែកវណ្ណៈរបៀបនេះ មិនមានលក្ខណៈតឹងរឹងដូចនៅស្រុកភ្លឹងទេ ។ បុព្វហេតុបណ្ដាលមកពីឥទ្ធិពលនៃព្រះពុទ្ធសាសនា ដែលពោរពេញទៅដោយព្រហ្មវិហារធម៌ចំពោះសត្វលោក ។

ការសិក្សាឯកសារផ្សេងៗ បង្ហាញឱ្យដឹង នូវរបៀបគ្រប់គ្រងក្នុងប្រទេសខ្មែរ ។ របបនយោបាយខ្មែរ គឺរបបរាជានិយម ពោលគឺព្រះអធិរាជ ឬស្ដេចសោយរាជ្យដោយមានការឧបត្ថម្ភពីសំណាក់នាម៉ឺន មន្ត្រី គ្រប់ជាន់ថ្នាក់ ព្រាហ្មណ៍បុរោហិត និងប្រជាពលរដ្ឋ ឬរាស្ត្រ ។

សិលាចារឹកខ្មែរ បានឱ្យដឹងថា ស្ដេចខ្មែរជាម្ចាស់ដែនដី ។ ដោយហេតុនេះហើយ បានជាព្រះអង្គធ្វើអំណោយ ដីភូមិស្ថាន ដល់នាម៉ឺន ឬ ព្រាហ្មណ៍ សម្រាប់កសាងវត្តអារាម ឬ ទេវស្ថាននានា ដូចជា ប្រាង្គប្រាសាទជាដើម ។ ឧទាហរណ៍ ៈ ពីសតវត្សទី ៨ ដល់សតវត្សទី ៦ នៃគ្រិស្តសករាជ គេសង្កេតឃើញនៅស្រុកខ្មែរយើងនូវពួកខ្ញុំ ដែលមាននាទីធ្វើស្រែចំការ ។ រីឯដីធ្លីវិញក៏មានម្ចាស់ដែរ ។

ចំពោះបញ្ហានេះ គួរសំគាល់ថា សិលាចារឹកខ្មែរ បានឱ្យការណ៍ថែមទៀត



www.budinst.gov.kh www.elibraryofcambodia.org

ថា ស្រែ ដីធ្លីទាំងឡាយ ជាកម្មសិទ្ធរបស់អ្នកដឹកនាំខ្មែរ ។ លើសពីនេះ មានការអភិសេកដីភូមិ ឱ្យក្លាយជាកម្មសិទ្ធរបស់វង្សត្រកូលសំខាន់ ១ ក្នុងព្រះរាជាណាចក្រខ្មែរទាំងមូល ។

បើនិយាយម្យ៉ាងទៀត គឺអ្នករាជការសំខាន់១ ឬភ្នាក់ងារ ឬក៏វង្សត្រកូលស្ដេច មានលទ្ធភាពក្នុងការបែងចែក ឬទទួលបន្តកេរ្តិ៍មរតកជាដីភូមិ ស្រុក ពិបុព្វបុរសរបស់ខ្លួន ។



www.budinst.gov.kh www.elibraryofcambodia.org

## នយោបាយទឹក

ការធ្វើស្រែចំការមិនអាចប្រព្រឹត្តឡើងបាន ដោយផលផ្លែ បើប្រសិនជាគ្មាននយោបាយទឹក ដែលនាំមកចំពោះ ព្រះរាជាណាចក្រខ្មែរបុរាណ នូវភាពចំរើនល្អណាស់ រុងរឿង ថ្កុំថ្កើង ។ គួររំលឹកជាពតិមានថា សម័យអង្គរវត្ត ជាសម័យមួយដ៏រុងរឿងបំផុត នៃប្រវត្តិសាស្ត្រខ្មែរ ក៏បានទទួលបច្ចេកទេសនយោបាយទឹក ដែលបានផ្តើមឡើងតាំងពីសម័យនគរភ្នំ និង ចេនឡាម្លេះ ។ នៅត្រង់នេះ យើងអាចពិពណ៌នាអំពី រាជធានីល្វសានបុរៈ ដែលសាងដោយព្រះបាទ ល្វសានវរ្ម័ន ស្ថិតនៅក្បែរស្ទឹងសែនជាឧទាហរណ៍ ពីព្រោះមានការប្រើប្រាស់ ប្រព័ន្ធបង្ហូរទឹក ខ្វាត់ខ្វែងព័ទ្ធជុំវិញទីក្រុងនេះសំរាប់បង្ហូរទឹកចូលក្នុងស្រះ និង ក្នុងអាងទឹក ក្នុងផ្ទៃទីក្រុង ។

ក្រោពីនេះ គេអាចសង្កេតឃើញ នូវការការជីកព្រែកគ្រប់ទីកន្លែងនៅកម្ពុជាក្រោម សំរាប់សំអាតភក់ល្បាប់ និង បន្សាបអំបិលដែលជ្រួតជ្រាបនៅក្នុងទីក្រុង និង សំរាប់គមនាគមន៍ រវាងទីកន្លែងមួយ ទៅកន្លែងមួយ ក្នុងព្រះរាជាណាចក្រខ្មែរ ។ គេក៏អាចជួបប្រព័ន្ធទឹក ដ៏ខ្វាត់ខ្វែងខាងលើនេះ នៅស្រុកអង្គរបុរី និង តាមឆ្នេរសមុទ្រសៀមសព្វថ្ងៃ ដូចជានៅខេត្ត នគរស្រីធមរាជ សុផានបុរ ជាដើម ។ ទាំងនេះបញ្ជាក់ឱ្យឃើញ នូវពាណិជ្ជកម្ម យ៉ាងសកម្ម នាអតីតកាល ។



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ទិសំយសេដ្ឋកិច្ច

ក្នុងទំព័រមុនៗ យើងបានដឹងហើយថា ក្នុងផ្នែកនយោបាយក្រៅប្រទេស ខ្មែរមានការទាក់ទងតាមផ្លូវទូត និង ផ្លូវពាណិជ្ជកម្មជាមួយ និង ឥណ្ឌា ។ ជាការពិតណាស់ ពាណិជ្ជកម្មមិនអាចធ្វើឡើងនឹងបរទេស បើប្រសិនជាគ្មាននិមិត្តសញ្ញាសំរាប់ការដោះដូរ ទំនិញនោះទេ ពោលគឺប្រាក់ ឬ លុយកាក់ ។

យ៉ាងណាមិញខ្មែរយើង ក៏មានការទាក់ទងជាមួយពួកឈ្មួញ រ៉ូម៉ាំង ឬក្រិក ដែរ ។ បុព្វហេតុនៃការសន្និដ្ឋានបែបនេះ មកពីវត្ថុបុរាណជាច្រើន ដែលគេបានរកឃើញ ដូចជា កាក់ធ្វើអំពីប្រាក់ សំណ ទង់ដែង ឬ មាស ជាដើម ជាពិសេសនៅកំពុងផែ អន្តរជាតិ អូរកែវ ដែលជាកំពង់ផែមួយ ដ៏ធំជាងគេបំផុតរបស់នគរភ្នំ រីឯនៅស្រុកអង្គរ បុរី ខេត្ត តាកែវ និង អូរទង ( ខេត្ត ស៊ុផាន់បូរី នៅសៀមសព្វថ្ងៃនេះ ) គេក៏បាន ជួបប្រទះនូវកាក់បុរាណទាំងអស់នោះដែរ ដែលភាគច្រើន មានរូបព្រះអាទិត្យមួយ កំណាត់ រូបស្រីវត្ស ខ្យងស័ង្ខ ។

សូមបញ្ជាក់ថា កាក់ទាំងអស់នេះ ដែលមានលំនាំតាមបែបឥណ្ឌា ក៏ត្រូវ គេជួបប្រទះនៅ បេកថះណូតេ ស្រីក្សេត្រ ( ភូមា ) និង នៅនគរមន ទ្វារវតី ដែល មានទំនាក់ទំនងជាមួយនគរភ្នំ ក្នុងកំឡុងគ្រីស្តសករាជ ៣០០-៦៦០ ។


www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះហើយ បានជាក្នុងវិស័យពាណិជ្ជកម្ម ក្នុងកំណត់ហេតុចិនបានរាយការណ៍ឱ្យដឹងថា អាណាចក្រភ្នំបានផលិតនូវទ្រព្យសម្បត្តិ ដូចជាមាស ស្ពាន់ សំណប៉ាហាំង ភ្លុកដំរី កុយរមាស ក្រមួន គុជ គ្រឿងឈើក្រអូប ។ល។ ម្យ៉ាងទៀត ក្នុងវិស័យនេះ ក៏ត្រូវបញ្ចូលផងដែរ នូវអង្កាំធ្វើអំពីកែវ ស្ទួរអង្កាំថ្ម និងមាសយ៉ាងល្អប្រណិត ដែលមានចំនួនច្រើន សន្ធឹកសន្ធាប់ ។

ប្រភពឯកសារចិនបានបញ្ជាក់បន្ថែមទៀតថា ដើម្បីរកគុជ គេត្រូវមុជទៅក្នុងបាទសមុទ្រ ។ គុជដែលបានមកពីនោះរឹងជាងដែកទៅទៀត ពីព្រោះដំមិនចេះខូច គឺដែកទេដែលត្រូវកំពិតទៅវិញ ។

លើសពីនេះទៀត ខ្មែរនាសម័យនគរភ្នំ ក៏ដូចជាខ្មែរនាសម័យបច្ចុប្បន្ននេះដែរ គេជាជាងទង « ជាង មាស ប្រាក់ » យ៉ាងស្ទាត់ជំនាញបំផុត ។ ដូច្នេះហើយបានជាខ្មែរបុរាណជំនាន់នោះ ប៉ិនប្រសប់ក្នុងការធ្វើ ចិញ្ចៀន កងដៃ ក្រវិលត្រចៀកអំពីមាស ប្រាក់ ស្ពាន់ និង សំណ ព្រមទាំងគ្រឿងចានក្បានប្រាក់ ឬក៏ប្រសប់ក្នុងរបស់នូវប ត្បាញសូត្រ ចរបាប់ និង ស្ទួកែវ ដើម្បីធ្វើកងដៃ ធ្វើអង្កាំសំរាប់ពាក់ជាវង់នៅដៃ ឬនៅក ជាគ្រឿងអលង្កា ។ ចំពោះបញ្ហានេះ វត្ថុបុរាណជាច្រើនឥតគណនា ដែលយើងបានរកឃើញ នៅរាជធានី វ្យាធបុរៈ ឬអង្គរបុរីក្នុងខេត្តតាកែវសព្វថ្ងៃនេះ ជាភស្តុតាងស្រាប់ ។

ចំពោះការជំនួញជួញព្រៃជាមួយខ្មែរយើង ចិនបានស្តាបនាសំពៅធំៗ


www.budinst.gov.kh www.elibraryofcambodia.org

•

សំរាប់ឆ្លងកាត់ពីសមុទ្រចិនទៅឈូងសមុទ្រខ្មែរ ។ ម្យ៉ាងទៀតសំពៅរបស់ចិន ដែលមកកាន់ស្រុកខ្មែរនោះ មានប្រវែងប្រមាណជា ៣០ ម៉ែត្រ ក្បាល និង កន្សៃរបស់សំពៅ ទាំងអស់នោះ មានរាងជាក្បាល និង កន្ទុយ សត្វត្រី ឬ ម្ករ ។

គួររំលឹកឡើងវិញថា ខ្មែរយើងមាននាវាសំរាប់ចម្បាំងផងតាំងពីសតវត្សទី ៣ នៃគ.ស ។ ការមាននាវាសំរាប់ច្បាំង ឬ ធ្វើជំនួញ សបញ្ជាក់ឱ្យឃើញថា ខ្មែរយើងក្នុងអតីតកាលមានបច្ចេកទេស ផ្នែកកសាងនាវាចរ យ៉ាងខ្ពង់ខ្ពស់បំផុត សំរាប់ឆ្លងមហាសមុទ្រ ។ ជាហេតុ ដែលនាំឱ្យខ្មែរមានកេរ្តិ៍ឈ្មោះ បោះសម្លេងយ៉ាងឆ្ងាយក្នុងចក្រភពចិន ឥណ្ឌា ឥណ្ឌូណេស៊ី និង រាជធានីរ៉ូម ។

សរុបសេចក្តីមក ខុសពីមតិខ្លះថា អាណាចក្រភ្នំជាអាណាចក្ររបស់ខ្មែរបុរាណដ៏ពិតប្រាកដ ហើយជាអាណាចក្រមួយ ដែលសំខាន់បំផុតក្នុងអាស៊ីអាគ្នេយ៍ ។ ម្យ៉ាងទៀត ភាពរុងរឿងថ្កុំថ្កើងខាងលើនេះ ក៏ជាអំណោយផល នៃភូមិសាស្ត្ររបស់នគរភ្នំ ដែលស្ថិតនៅក្នុងឈូងសមុទ្រ គឺឈូងសមុទ្រសៀមសព្វថ្ងៃនេះ ដែលជាសំណាកមួយយ៉ាងសំខាន់សម្រាប់ កប៉ាល់ធំ ១ មកចតសម្រាក ដើម្បីធ្វើដំណើរឆ្ពោះទៅប្រទេសឥណ្ឌា និង ចិន ។

ឥទ្ធិពលរបស់នគរភ្នំ បានចុះទន់ខ្សោយនៅចុងសតវត្សទី ៦ នៃគ្រិស្តសករាជ ហើយបន្តិចម្តង១ ពោលគឺនៅចុងសតវត្សទី៧ ដើមសតវត្សទី៨ សន្តិវង្សចេនឡាក៏គ្រប់គ្រង នគរភ្នំវិញទៅ។ មូលហេតុនៃការចុះខ្សោយនៃនគរភ្នំ មកពីវិបត្តិផ្ទៃក្នុងនៃ



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

ឯកសារស្ដីអំពី សន្តិចឲ្យនគរភ្នំ និង ចេនឡា

របស់ ក្លូដ ម៉ាដ្រូល

www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃនេះ ទោះបីទំហំទឹកដីរបស់ខ្លួន ត្រូវគេបង្រួញអោយស្ថិតតូចយ៉ាងណាក៏ដោយ ។

សូមរំលឹកឡើងវិញថា សន្តិវង្សរបស់នគរភ្នំ និង សន្តិវង្សរបស់ចេនឡា ដែលប្រសូត្រចេញពីបុព្វបុរសតែមួយ មានឫទ្ធានុភាពយ៉ាងខ្លាំងក្លា អស្ចារ្យ គឺព្រះបាទកោណ្ឌិញ ដែលបានយាងមកពីស្រុកក្លឹង្គខាងត្បូង ក្នុងអតីតកាល ។ ម្យ៉ាងទៀតបើយើងសំអាងទៅលើប្រវត្តិសាស្ត្រនាសម័យនោះ ការដណ្តើមអំណាច ពោលគឺគ្មានលក្ខណៈវាតទីនិយម បំផ្លិចបំផ្លាញមនុស្ស ឬទ្រព្យសម្បត្តិនោះទេ ។ ក្នុងន័យនេះហើយ ដែលឯកសារចិនឈប់និយាយពីព្រះរាជណាចក្រនគរភ្នំ ក្រោយពីសន្តិវង្សចេនឡាបានកាន់កាប់ ដឹកនាំប្រទេស ក្រោយពីបានឈ្នះសង្គ្រាម ។

សូមបញ្ជាក់ថា មុនឆ្នាំ ៦៤៣ នៃស.គ នគរភ្នំ ពុំទាន់បាត់បង់អធិបតេយ្យភាពទាំងស្រុងរបស់ខ្លួននៅឡើយទេ ពោលគឺ នគរភ្នំ នៅតែរក្សាបាន នូវអធិបតេយ្យភាពរបស់ខ្លួននៅឡើយ ។ តាមឯកសារចិនចេហ្លូយ៉ួនបានឱ្យដឹងថា « នគរភ្នំ វាយលុកនគរលិនយី នៅឆ្នាំ ៦៤៣ » ។ តាមពិត ឯកភាពជាតិ ឬ ចំណុះការបង្រួបបង្រួមរវាងចេនឡា ដែលជាស្រុកចំណុះ របស់នគរភ្នំដើមឡើយ និង នគរភ្នំ ត្រូវបានធ្វើឡើងនៅចុងសតវត្សទី ៧ ដោយព្រះបាទភវវរ្ម័នទី ២ និង ជ័យវរ្ម័នទី ១ ដែលសោយរាជ្យនៅអង្គរបុរី នៅចុងសតវត្សទី ៧ នៃ គ.ស ។ ក្រោយពីបានធ្វើការវាយលុកទៅលើរាជធានីនគរភ្នំ ដែលស្ថិតជិតបាភ្នំ ព្រះបាទភវវរ្ម័នទី ១ ដែលជាញាតិវង្សរបស់នគរភ្នំ តែព្រះជាយាររបស់ព្រះអង្គ ជាព្រះក្សត្រីយ៍របស់ចេនឡា បានបង្រួបបង្រួមប្រទេសទាំង



www.budinst.gov.kh www.elibraryofcambodia.org

គិរនៅចុងសតវត្សទី ៦ ។ ព្រះអង្គបានទទួលការឧបត្ថម្ភពីសំណាក់ព្រះបាទ ចិត្រសេនា ដែលជាព្រះអនុជរបស់ព្រះបាទ ចិត្រសេនា បានបង្ក្រាប តែការផ្សះផ្សារជាតិនេះពុំទាន់ពេញលេញ ។ ព្រះអង្គបានបង្គាប់តំបន់បះបោរ ដែលស្ថិតតាមដងទន្លេមេគង្គ ហើយបានពង្រីកឥទ្ធិពលរបសព្រះអង្គនៅក្នុងភាគខាងត្បូង និង លាតសន្ធឹងដល់ភាគខាងជើង។ ព្រះអនុជរបស់ព្រះអង្គសោយរាជបល្ល័ង្គ បន្ទាប់ពីព្រះអង្គបានសោយទីវង្គត់ ដោយមានព្រះនាមថា មហេន្ទ្រវរ្ម័ន ។ គឺស្តេចខ្មែរអង្គនេះហើយ ដែលបានបញ្ចុះបញ្ចូលខេត្តនានា នៃព្រះអតីតណាចក្រកម្ពុជា ជាពិសេសខេត្តនានាដែលស្ថិតនៅតាមខ្ពង់រាបហើយបានចារសិលាចារឹកជាច្រើនផ្ទាំងនៅតាមប្រាសាទ ខេត្ត ច័ន្ទបុរី បុរីរម្យ សុរិន្ទ្រ អ៊ុបន់ភេជ្ជបុន ។ ល ។ ដើម្បីរំលឹកនៃជ័យជំនះរបស់ព្រះអង្គ ។

ព្រះបាទឥសានវរ្ម័ន ដែលជាព្រះរាជបុត្ររបសព្រះអង្គ បានបន្តការពង្រីកពង្រឹងជាតិកម្ពុជា ។ ស្តេចអង្គនេះបានគ្រប់គ្រងប្រទេសគ្រប់គ្រងប្រទេសរវាងឆ្នាំ ៦១៦-៦៣៥ ដោយបានកសាងនូវរាជធានីឥសានបុរៈ ឬ សម្បូរព្រៃគុក នៅខេត្តកំពង់ធំសព្វថ្ងៃនេះ និង បានផ្ញើទូតខ្មែរទៅប្រទេសចិន ដើម្បីពង្រីកស្ពានមេត្រីរវាងប្រទេសទាំងពីរទៀតផង ។

ចំណុចមួយទៀតដែលយើងត្រូវកត់ត្រា ឬ កែតម្រូវ គឺព្រះបាទជ័វរ្ម័នទី២ មិនមែនជាស្តេចជ្វាមកសោយរាជ្យនៅកម្ពុជាដូចសំដីរបស់ Claude Madrolle នោះទេ ។ ព្រះអង្គគឺជាស្តេចខ្មែរ ដែលបានភៀសខ្លួន ទៅនៅស្រុកជ្វាតែប៉ុណ្ណោះ ដែល



www.budinst.gov.kh www.elibraryofcambodia.org

សម័យនោះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយជនជាតិខ្មែរ ។ សូមរំលឹកឡើងថា រហូតដល់រជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី ៧ ចុងសតវត្សទី ១២ ដើមសតវត្សទី ១៣ នៃគ.ស ពោលគឺមុនការជន្លៀសខ្លួនពីជនជាតិថៃ ពីស្រុកចិនខាងត្បូង ចូលព្រះរាជាណាចក្រថៃបច្ចុប្បន្ន ខ្មែរយើងនាសម័យនោះ នៅកាន់កាប់ខេត្តនានាជាច្រើនដូចជា សៃយះ និង ខេត្តកញ្ចនៈបុរី ជាដើមនៅឡើយ ដូចជាវត្តមានរបស់ប្រាសាទមឿងសិង្ហជាភស្តុតាងស្រាប់ ។ រួមសេចក្តីមក ថ្វីត្បិតតែនគរស្រីវិជ័យ បានកកើតឡើងនៅលើអតីតទឹកដីរបស់នគរភ្នំក៏ដោយ ហើយការបង្កើតទីក្រុងនេះ ដែលជាមុខសញ្ញាមួយបង្ហាញនូវភាពចុះទន់ខ្សោយរបស់អំណាចកណ្តាលរបស់នគរភ្នំក៏ដោយ ក៏ឥទ្ធិពលខ្មែរនាសម័យនោះ មិនទាន់រលត់សាបសូន្យនៅឡើយ ជាពិសេសនៅជ្រោយម៉ាឡាយូ ។



www.budinst.gov.kh www.elibraryofcambodia.org

# កម្ពុជា ៖ កាលប្បវត្តិវិទ្យា នៃព្រះមហាក្សត្រខ្មែរ រហូតមកដល់ពាក់កណ្តាលស.ត ទី ១៥

« ការរកឃើញសិលាសិលាចារឹកថ្មីទាំងឡាយ ភ្ជាប់ជាមួយ និង ការបកស្រាយនូវអត្ថន័យដ៏ល្អប្រសើរបំផុតពីសិលាចារឹក ដែលគេបានយល់ដឹងរួចមកហើយនោះ បានធ្វើឱ្យលោក L. Finot និង លោក G. Coedès កែតំរូវបញ្ជីនៃសន្តិវង្សខ្មែរ ដែលបានផ្សព្វផ្សាយក្នុងព្រឹត្តិបត្ររបស់សាលាបារាំងបច្ចិមប្រាច្យតាំងពីឆ្នាំ ១៩១៥ ។ ហេតុដូច្នេះ លោកទាំងពីរអាច កែប្រែសម័យកាលនៃរជ្ជកាលខ្លះ និងបានបង្កើតព្រះនាម នៃព្រះមហាក្សត្រ ដទៃ ១ ទៀតជាច្រើន ។ កាលប្បវត្តិវិទ្យាត្រូវបានបំពេញខ្លឹមសារ ដែលបានដកស្រង់ចេញពីឯកសារប្រទេសចិន ដោយលោក Pelliot ។

ប្រទេសចិនបានស្គាល់ជាយូរលង់ណាស់មកហើយ ពីប្រទេសកម្ពុជា ក្រោមឈ្មោះថា ហ្វូ–ណន រួចមក មានឈ្មោះថា ចេន–ឡា ។

ដើម្បី នឹង ធ្វើឱ្យប្រវត្តិសាស្ត្រ នៃប្រទេសនេះរស់រវើក យើងបានបំពេញនូវការខ្វះខាតជាច្រើន ដែលបង្ហាញពីការបន្តរាជ្យ នៃព្រះមហាក្សត្រនៅស.តទី ៣ ក្រោយគ.ស ដោយកំណត់យកអក្សរ អ៊ិច ( X ) សំរាប់កត់សំគាល់ព្រះនាមនៃស្តេចខ្លះ ១ ដែលគេនៅមិនទាន់ច្បាស់លាស់ ឱ្យស៊ីគ្នាទៅនិងស្តេចអង្គណាមួយ ដែលបានឡើងគ្រងរាជ្យបន្ត ។



www.budinst.gov.kh www.elibraryofcambodia.org

គេបានសង្កេតឃើញថា មេនៃខ្សែស្រឡាយទាំងនោះ សុទ្ធសឹងជាបរ-ទេស បានមកដល់កម្ពុជា ដោយច្បាំងដណ្តើមយកជ័យជំនះ ។

ពាក្យថាខ្មែរ និង កម្ពុជា គឺជាវេវចនសព្ទ ។ ពាក្យពីរម៉ាត់នេះបានបញ្ជាក់ជានិច្ចកាលពីជនជាតិតែមួយ ដែលបានកាន់កាប់ ក្នុងវិស័យនយោបាយ នៅក្លោងរបស់ទន្លេមេគង្គ និង មេណាម ។ សម័យបច្ចុប្បន្ន ប្រទេសខ្មែរមានតែផ្ទៃដីដ៏តូចមួយ ក៏ប៉ុន្តែជនជាតខ្មែរជាច្រើនបានរស់នៅជានិរន្ត ក្រៅពីព្រំសីមានេះដែលជាដែនដីរបស់ពួកអាណាមនៅជ្រោយឥណ្ឌូចិន និង ពួកថៃនៅប្រទេស សៀម បានដណ្តើមយក ។ ពួកខ្មែរបានបន្សល់ទុកនៅលើមាតុភូមិនៃមហាធិរាជណាចក្ររបស់ខ្លួន នូវប្រាង្គប្រាសាទជាច្រើន ២ទីចាប់អារម្មណ៍ ជាពិសេសប្រាង្គប្រាសាទអង្គរវត្ត ដែលជាប្រាសាទមួយត្រូវបានពួកទេសចរមកទស្សនា នឹង ស្ងើចសរសើរ ក្នុងចំណោមប្រាសាទដ៏ទៃ ១ ទៀត ។

ក្នុងអត្ថបទនេះ ពាក្យដើមទាំងឡាយនៃអរបស៊ី ពុំមានការប្រែប្រួលទេ ។

## អំពីសាសនា

ក្នុងសម័យកាលដែលយើងកំពុងនិយាយនេះ មានសាសនា ជាសំខាន់នៅកម្ពុជា គឺ ព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនា ។



www.budinst.gov.kh www.elibraryofcambodia.org

# ព្រាហ្មណ៍សាសនា

•

ព្រាហ្មណ៍សាសនា ដែលត្រូវបានគេនាំចូលពីប្រទេសឥណ្ឌា មកប្រទេសខ្មែរក្នុងសម័យកាល ដែលប្រហាក់ប្រហែលជាមុន គ.ស បន្តិច ។ គឺជាជំនឿផ្លូវការរបស់ព្រះមហាក្សត្រខ្មែរ ។

និមិត្តរូបផ្នែកទេវកថារបស់វាគឺ ត្រីមុំកិ ត្រិមូរ្តិៈព្រះព្រហ្ម ព្រះវិស្ណុ ព្រះសិវៈ ។

ព្រះព្រហ្ម ជាអ្នកបង្កើតលោក ព្រះវិស្ណុ ជាអ្នកការពារចក្រវាឡ ។ គេបានស្គាល់ព្រះអង្គដោយ អវតា ទាំង ១០ ។

ព្រះសិវៈ ជាភ្លើង សំរាប់បំផ្លាញ ។ ព្រះអង្គធ្វើទោស ក៏ប៉ុន្តែចំពោះករណីចាំបាច់ ព្រះអង្គធ្វើពហុផល ។ ព្រអង្គជាព្រះអទិទេពខាងបង្កើតលោក ត្រូវបានគេតំណាងដោយលឹង្គ ។

ភាពជាមនុស្សវិញ ព្រះត្រូវបានគេឧទ្ទិស ក្នុងភាពជាស្រីភេទ ដោយមហិទ្ធិឫទ្ធិ របស់ព្រះអង្គ ។

ក្នុងត្រិមូរ្តិនេះ គេត្រូវបន្ថែមព្រះអទិទេពមួយទៀត គឺព្រះឥន្ទ្រ ជាព្រះអទិទេពដ៏ធំបំផុតក្នុងសម័យវេទ ។

ព្រះរាជសន្តិវង្សខ្មែរ គោរពបូជាជំនឿផ្នែកសិវៈ ដែលតំណាងឱ្យលឹង្គ ។



www.budinst.gov.kh www.elibraryofcambodia.org

សន្តិវង្សរបស់ហ្វូ-ណាន និង សន្តិវង្សជាច្រើនទៀតនៅខាងដើមសម័យចេនឡាបានរួមបញ្ចូលគ្នាជាមួយព្រះសិវៈ នូវរូបព្រះវិស្ណុ ក្រោមពាក្យថា ហរិហរៈ ។ សាសនាខ្លះបានលើកតំកើងព្រះព្រហ្ម ។

## ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា បានលេចឡើងនៅកម្ពុជាជំនាន់ដើម នូវនិកាយដែលគេហៅថា មហាយាន ដែលបានកើតឡើងនៅប្រទេសឥណ្ឌានៅសម័យដើមនៃ គ.ស សាសនានេះត្រូវបានជនជាតិខ្មែរ គោរពបូជាជាខ្លាំង តាមរយៈព្រះអទិទេព ដែលមានធមិករុណា ( ព្រះពោធិសាត់ ) ។

ត្រីមូរិរបស់វាគឺ ព្រះពុទ្ធ លោកេស្វរៈ និង ប្រាជ្ញាបារមិតា ។ ក្រោយមក Bhaishayaguru ជាអ្នកការពារគ្រប់គ្រង អាគារដែលជា ស មា វ ស ថ ។

## អំពីសិលាចារឹក

សិលាចារឹក ដែលបានដកស្រង់ចេញពីសិលាស្តម្ភ សុទ្ធសឹងជាអក្សរសំស្ក្រឹត ពាក្យពេជន៍ចេញពីព្រហ្មញ្ញសាសនា និង ពុទ្ធសាសនា ផ្នែកមហាយាន ។


www.budinst.gov.kh www.elibraryofcambodia.org

សិលាចារិកទាំងនោះ បានបញ្ជាក់ពីព្រឹត្តិការណ៍នៅសម័យហិណ្ឌូ ដែលត្រូវបានគេ ហៅ ថា ស័ក ដែលមានរយៈកាសតិចជាង-គ.ស ចំនួន ៧៨ ឆ្នាំ ។

សំណល់វប្បធម៌ នៃរបស់ក្រុងបុរាណ មានយ៉ាងសន្ធឹកសន្ធាប់ នៅ ប្រទេសខ្មែរ ។ ឈ្មោះក្រុងទាំងនោះត្រូវបានរៀបរាប់ ដោយសិលាចារឹក ក៏ប៉ុន្តែទី តាំងទាំងនោះ ពុំត្រូវបានគេស្គាល់ជាផ្លូវការឡើយ ។ គេផ្លាស់ប្តូរទីតាំងទាំងនោះ ក៏ ដោយសារតែការផ្លាស់ប្តូរសន្តិវង្ស ឬក៏ដោយសារតែជំនឿ សាសនាថ្មី និង ព្រឹត្តិការណ៍ នយោបាយ ។

យើងសូមធ្វើការរៀបរាប់ខ្លះ ១ នូវរាជធានីបុរាណទាំងនោះ ៈ-

- ព្យាធបុរៈ ៖ អង្គរបុរី សតវត្សទី ៤ រហូតដល់ចុងបញ្ចប់ សតវត្សទី ៦ រាជធានីរបស់ស្តេចខ្មែរដែលមកពីផ្នា ( P'an-p'an ) ។

- ស្រេស្ឋបុរៈ ៖ បាដោម ចម្ងាយ ១២ គ.ម ពីស្ទឹងត្រែង សតវត្សទី ៦ រាជធានីរបស់ស្តេចចេនឡា ។

- ភវបុរៈ ៖ ព្រៃនគរ សតវត្សទី ៦ រាជធានីព្រះបាទភវវរ្ម័ន

- សំបូរបុរៈ ៖ សំបូរទន្លេមេគង្គ សតវត្សទី ៦ រហូតដល់ទី ៧ រាជធានីរបស់ព្រះបាទ មហេន្ទ្រវរ្ម័ន ។

មហាយានត្រូវបានបាត់នៅប្រទេសឥណ្ឌា ក្រោយពីការលុកលុយរបស់ ពួកម៉ុលស៊ុលម៉ង់ នៅចុងបញ្ចប់នៃសតវត្សទី ១២ ។ ពុទ្ធសាសនិជន កម្ពុជាចាប់យក



www.budinst.gov.kh www.elibraryofcambodia.org

សាសនានៅសិរីល័ង្កា ដែលកំពុងរីកចំរើន នៃព្រះពុទ្ធសាសនាផ្នែកហិនយាន ។

- អនិន្ទិតបុរៈ : ម្តុំអង្គរ សតវត្សទី ៨ រាជធានីរបស់ព្រះបាទបុស្ករៈ ។

- ឥន្ទ្របុរៈ : ម្តុំភូមិមៀន សតវត្សទី ៨ រាជធានី Xh ។

- ហរិហរាល័យ : លលៃ សតវត្សទី ៨ រាជធានីរបស់ព្រះបាទជ័យវរ្ម័នទី ២ ប្រាសាទធ្វើនៅសតវត្សទី ៩ ។

- អមរេន្ទ្របុរៈ : ភ្នំស្រុក សតវត្សទី ៨ សង់ឡើងដោយស្តេចជំនាន់មុន ។

- មហេន្ទ្របព៌ត : ភ្នំគូលេន សតវត្សទី ៩ រាជធានីធ្វើនៅលើភ្នំរបស់ព្រះបាទជ័យវរ្ម័នទី ២ ។

- យសោធរបុរៈ : អង្គរធំ កសាងនៅសតវត្សទី ១១ ដោយព្រះបាទយសោវរ្ម័ន ទី ១ ជួសជុលឡើងវិញ ដោយព្រះបាទជ័យវរ្ម័នទី ៧ នៅស.តទី១២

- ជោគគិរ្យៈ : កោះកេរ សតវត្សទី ១០ កសាងដោយព្រះបាទជ័យវរ្ម័នទី ៤ ។

- ព្រះខ័ន : ព្រះខ័នកំពង់ស្វាយ សតវត្សទី ១០ កសាងឡើងដោយព្រះបាទជ័យវរ្ម័នទី ៥ ។


www.budinst.gov.kh www.elibraryofcambodia.org

# អំពីភ្នំដែលជាទីសក្ការៈបូជា

ក្នុងព្រះរាជាណាចក្រនេះ ដែលពោរពេញទៅដោយវាលរាប និង ជលសារ កំពូលភ្នំខ្លះ ៗ ដែលបានលេចឡើង តាំងពីមុនមក ជាមួយនិងប្រជាជន ដែលអ្នកទាំងនោះចាត់ទុកថាជាវត្ថុស័ក្តិសិទ្ធិ ។ ព្រះមហាក្សត្រខ្មែរបានដាក់ព្រះរាជសន្តិវង្ស និង ប្រទេសរបស់ទ្រង់ ក្រោមមហិទ្ធិឫទ្ធិ ( ការ ការពារ ) របស់វត្ថុទាំងនោះ តាមឆន្ទៈរបស់រាស្ត្រ ដែលគេបានជ្រើសរើស ដើម្បីការពារ ខ្សែក្រវាត់ប្រទេសជាតិឱ្យមានសុវត្ថិភាព ។

ក្នុងចំណោមភ្នំទាំងនេះមាន ៖-

- ណួយ បាដែង : ( ជាភាសាយួន ) ព្រះភ្នំ នាងខ្មៅ ប្រហែលជាភ្នំដែលគេគោរពមុនគេបង្អស់ ។

- បាភ្នំ : ជាភ្នំដែលរាជសន្តិវង្ស នគរភ្នំគោរព ។

- ភូខាវ ( វត្តភូ នៅលាវ ) : ( លឹង្គបិពត ) ជាភ្នំសម្រាប់រាជសន្តិវង្សដំបូងរបស់ចេនឡា ។

- ភ្នំគូលេន : ភ្នំសក្ការៈបូជា របស់ស្តេចជ័យវរ្ម័នទី ២ ( ដែលបានមកកម្ពុជាដំបូងគេបង្អស់ ) មកពីប្រទេសជ្វា ( ហើយបានឡើងសោយរាជ្យ ) ។

- ភ្នំបាខែង : ភ្នំស្ថិតនៅក្នុងកសិណរបសយសោធរៈបុរៈ ។



www.budinst.gov.kh www.elibraryofcambodia.org

រាជសន្តិវង្សដំបូងរបស់ខ្មែរបានភ្ជាប់ទៅនឹងប្រពៃណីពៃកំណើតរបស់គេ នូវទ្វិបភាព របស់តារា ដែលត្រូវបានគេដាក់ផ្ទុយគ្នា ព្រះច័ន្ទ និង ព្រះអាទិត្យ ច័ន្ទវង្ស សោមាវង្ស និង សូរ្យវង្ស ។

រាសន្តិវង្សទាំងពីរនេះ បានចេញមកពីសម្ព័ន្ធភាព នៃគំនិត មួយចេញពីព្រាហ្មណ៍កោណ្ឌិញ ជាមួយនាង នាគីសោមា មួយទៀតចេញពីមហាឥសី កម្ពុសាយម្ភវះ ជាមួយ និង អប្សរមេរា ។

រឿងនិទានពីព្រះអាទហ៊ុនទៀន បានចែកជាខ្សែស្រឡាយដល់កោណ្ឌិញ ( នៃព្រះច័ន្ទ ) លុះចំណោះក្រោយមក ព្រះបាទស្រេស្ថវរ្ម័ន ដែលជាក្សត្រមុនគេ បាននន្ទិសដល់ជីដូន ជីតា កម្ពុ ( នៃព្រះអាទិត្យ ) វិញ ។



www.budinst.gov.kh www.elibraryofcambodia.org

## សន្តិវង្ស និង ព្រះមហាក្សត្រខ្មែរ

### ១- ខ្សែស្រឡាយ ឬ សន្តិវង្ស

### នគរភ្នំ ( ហ្វូ-ណាន )

- ចំនួន : ពីឆ្នាំ ៣៥៧ រហូតដល់ចុងបញ្ចប់ ១ភាគ ៤ ទី ១ នៃសតវត្សទី ៥
- ស្រិន្ទ្រ : ១ ភាគ ៤ ទី ២ នៃ សតវត្ស ទី ៥ រហូតដល់ ៤៧០
- ហ្វាន់ ( គោណ្ឌិញ្ញ ) : ប្រហែល ២២០ រហូតដល់ ២៤៨
- ហ្វាន់ ស៊ុយុន : ប្រហែល២៤៨ រហូតដល់ ២៨៨
- ហ៊ុន ធៀន ( គោណ្ឌិញ្ញ ) : ប្រហែលឆ្នាំ ២២០

គឺចាប់ពីពេលនេះហើយ ដែលមានពាក្យថាកម្ពុជា ពីសិលាចារឹកដែលគេបានបង្កើតពាក្យ ( កាំបូជ ) កម្ពុជា ។

- ចំយ៉ាន P'an-p'an : ប្រហែល ៤៧០ រហូតដល់ ៥៤៥

### ចេនឡា

- គច : ប្រហែល ៥៦៥ រហូតដល់ ៧០៥



www.budinst.gov.kh www.elibraryofcambodia.org

- ស្រេស្ឋៈ : ប្រហែល ៥៤៥ រហូតដល់ ៥៦៥
- ជ័យមកពីកោះជ្វា : ប្រហែល ៧៨០ រហូតដល់ ៨២២
- ជ័យនៅកោះកេរ : ៩២១ រហូតដល់ ៩៤៤
- ជ័យនៅមហិធរបុរៈ : ១០៨២ រហូតដល់សម័យបច្ចុប្បន្ន
- បុស្ករះ : ប្រហែល ៧០៦ រហូតដល់ ៧៨០
- រាជេន្ទ្រ : ៩៤៤ រហូតដល់ ១០០២
- សូរ្យវានៅសិកោ : ១០០២ រហូតដល់ ១០៨២

## អំពីមហាក្សត្រ

- កោណ្ឌិន្យ : ពាក់កណ្ដាលសតវត្សទី ៨
- ភវវរ្ម័នទី ១ : ប្រហែល ៥៦៥ រហូតដល់ ៥៨៥
- ភវវរ្ម័នទី ២ : ប្រហែល ៦៣៩ រហូតដល់ ៦៥០
- ចន្ទធន : ប្រហែល ៣៥៧ រហូតដល់
- ស្រេស្ឋវរ្ម័ន : ប្រហែល ៥៤៥ រហូតដល់ ៥៦៥
- ស្រីន្ទ្រវរ្ម័នទី ៥.១ : ១ ភាគ ៤ ទី ២ នៃសតវត្សទី ៥
- ស្រីន្ទ្រវរ្ម័នទី ២ : ១២៩៥ រហូតដល់ ១៣០៧



www.budinst.gov.kh www.elibraryofcambodia.org

- ស្រិន្ទ្រជ័យទី ៥ : ១៣០៧ រហូតដល់ ១៣២៧
- ធរណិន្ទ្រវរ្ម័ន ១ : ប្រហែល ១១០៧ រហូតដល់ ១១១៣
- ធរណិន្ទ្រវរ្ម័នទី ២ : ១១៤៥ រហូតដល់ ១១៥៥
- ហ្វានចេម៉ាន ( កោណ្ឌិញ ) : ប្រហែល ២២០ រហូតដល់ ២៣០
- ហ្វាន់គិនចេ : ប្រហែល ២៣០
- ហ្វាន់-ចាន់ : ប្រហែល ២៣០ រហូតដល់ ២៤៨
- ហ្វាន់-ចង់ : ប្រហែល ២៤៨ រហូតដល់ ២៨៨
- ហស្សវរ្ម័ន ៥-១ : ប្រហែល ៩១១ រហូតដល់ ៩២១
- ហស្សវរ្ម័ន ២ : ៩៤២ រហូតដល់ ៩៤៤
- ហស្សវរ្ម័ន ៣ : ១០៦៥ រហូតដល់ ១០៨០ - ១០៨១
- ហ៊ុនទៀន ( កោណ្ឌិញ )..........
- ហ៊ុន ប៉ាន់-ប៉ាន់ : ប្រហែល ២១៧ រហូតដល់ ២២០
- ឥសានវរ្ម័ន ១ : ប្រហែល ៦១០ រហូតដល់ ៦៣៥
- ឥសានវរ្ម័ន ២ : ៩២១ រហូតដល់ ៩២២
- ឥន្ទ្រវរ្ម័ន ១ : ៨៧៧ រហូតដល់ ៨៨៩
- ឥន្ទ្រវរ្ម័ន ២ : ប្រហែល ១២០៥ រហូតដល់ ១២៤៣
- ជ័យវរ្ម័ន A : ១ ភាគ ៤ ទី ២ នៃសតវត្សទី ៥
- ជ័យវរ្ម័ន B : ប្រហែល ៤៧០ រហូតដល់ ៥១៤


www.budinst.gov.kh www.elibraryofcambodia.org

- ជ័យវរ្ម័ន ១ : ពាក់កណ្តាលទី ២ នៃសតវត្សទី ៧
- ជ័យវរ្ម័ន ២ : ប្រហែល ៧៨០ រហូតដល់ ៨៥៤
- ជ័យវរ្ម័ន ៣ : ៨៥៤ រហូតដល់ ៨៧៧
- ជ័យវរ្ម័ន ៤ : ៩២១ រហូតដល់ ៩៤២
- ជ័យវរ្ម័ន ៥ : ៩៦៨ រហូតដល់ ១០០១
- ជ័យវរ្ម័ន ៦ : ១០៨២ រហូតដល់ ១១០៨
- ជ័យវរ្ម័ន ៧ : ១១៨១ រហូតដល់ ១២០៩
- ជ័យវរ្ម័នបរមេស្វរៈ : ១៣២៧ រហូតដល់ ១៣៤០
- ជ័យវីរៈវរ្ម័ន : មើលសូរ្យវរ្ម័នទី ៥
- មហេន្ទ្រវរ្ម័ន : ចុងបញ្ចប់សតវត្សទី ៦ រហូតដល់ ៦១០
- ចុស្ករស្ស : ១ ភាគ ៤ទី នៃ សតវត្ស ទី ៨
- រាជេន្ទ្រវរ្ម័នទី ១ : ចុងបញ្ចប់សតវត្សទី ៧ រហូតដល់ ៧០៦
- រាជេន្ទ្រវរ្ម័ន ២ : ៩៤៤ រហូតដល់ ៩៦៨
- រុទ្រវរ្ម័ន : ៩៤៤ រហូតដល់ ៩៤៥
- សូរ្យវរ្ម័ន ១ : ១០០២ រហូតដល់ ១០៤៩
- សូរ្យវរ្ម័ន ២ : ១១១៣ រហូតដល់ ១៤៤៥
- ភវនាទិត្យវរ្ម័ន : ១១៦៣ រហូតដល់ ១១៧៧
- ឧទយាទិត្យវរ្ម័ន ១ : ១០០១ រហូតដល់ ១០០២


www.budinst.gov.kh www.elibraryofcambodia.org

- ឧទយាទិត្យវរ្ម័ន ២ៈ ១០៤៩ រហូតដល់ ១០៦៥
- យសោវរ្ម័ន ១ ៖ ៨៨៩ រហូតដល់ ៩១១
- យសោវរ្ម័ន ២ ៖ ១១៥៥ រហូតដល់ ១១៦៣ »



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# សន្តិវង្សរបស់ នគរភ្នំ

( ពី ... ? ដល់ឆ្នាំ ៥២៧ ក្រោយគ្រិស្តសករាជ )

សម័យកាលដែលជាប់ពាក់ព័ន្ធនឹងរឿងព្រេង គេមិនបានដឹងអ្វីឱយបានច្បាស់លាស់ទាំងអស់ចំពោះអតីតប្រវត្តិរបស់ប្រជាជនខ្មែរ ក៏ដូចជាប្រទេសនេះដែលមានអាយុកាលប្រហាក់ប្រហែលនឹងគ្រិស្តសករាជ ដែលបានតាំងជាប្រទេសរួចស្រេចទៅហើយនោះដែរ ។

១ . **លីវ យី** ( Lieou Ye ) ឬ **យី យី** (Ye Ye) ជាអប្សរក្សត្រិយ៍សោយរាជ្យ នៅ *នគរភ្នំ* ។

## សន្តិវង្ស ហ៊ុន ( Houen ) ឬ ប៉ាន់ ( Pan )

( ពី.....? ដល់ឆ្នាំ ប្រមាណ ២២០ ក្រោយ គ្រិស្តសករាជ )

### សោមាវង្សា

២ . **ហ៊ុន ធៀន** ( Houen tien ) ឬ **ហ៊ុន ចេន** ( Houen chen ) ពីឆ្នាំ ....? ដល់ឆ្នាំ .....? មានដើមកំណើតមកពីប្រទេស



www.budinst.gov.kh www.elibraryofcambodia.org

ព្រាហ្មណ៍ឈ្មោះ **ម៉ូធី** ( *Motie* / Insulinde) ព្រះអង្គបានបើកនាវាហើយច្បាំងឈ្នះទព័ព្រះនាង **លីវ យី** ជាក្សត្រិយ៍នៃប្រទេសដែលស្ថិតនៅតាមតំបន់ទំនាបនៃទន្លេមេគង្គ រួចឡើងធ្វើជា ស្តេចសោយរាជលើ*នគរភ្នំ* ក្នុងពេលនោះដែរ។

មេដឹកនាំនេះ ជាអ្នកសិរីសនិកជន ដូចគ្នានឹង ***កោណ្ឌិញ្ញ*** (Kaundinya) តួឯកក្នុងព្រេងនិទានរបស់ **ចន្ទ្រ ចង** ( សោមា វង្ស )

៣ . **ហ៊ុន** X.....

ព្រះអង្គ ជាអ្នកគ្រងរាជបន្ត បានផ្ទេរអំណាចប្រហែលនៅឆ្នាំ ២២០ក្រោយគ្រិស្តសករាជ ។

**៤ .ហ៊ុន ប៉ាន់ ហាង** ( Houen p'an - houang ) ប្រសូតក្នុងកំឡុងឆ្នាំ ១២៧ សុគត ក្នុងវ័យចំណាស់អាយុ ៩០ ឆ្នាំ ក្នុង១ ភាគ ៤ ទីមួយនៃសតវត្ស ទី៣ ប្រហែល ២១៧ នៃ គ.ស ។

កូន និង ចៅរបស់ព្រះអង្គ បានត្រូវគេតែងតាំងឱយធ្វើជាមេដឹកនាំតាមបណ្តាផ្នែកនានា ។

**៥ . ហ៊ុន ប៉ាន់ ប៉ាន់** (Houen Pan - Pan ) រវាង ២១៧ . ២២០ ជាកូនពៅរបស់ព្រះអង្គសោយរាជ្យបាន ៣ ឆ្នាំ ។



www.budinst.gov.kh www.elibraryofcambodia.org

# សន្តតិវង្សរបស់ហ្វាន់ ( វរ្ម័ន Varman )

( ពីឆ្នាំ ២២០ ១/៤ ទី២ នៃសតវត្សទី៥ )

**៦ . ហ្វាន់ ចេ ម៉ាន់** ( Fan che man ឬ *ស្រី មារៈ* / ស្រី មារាញ ) រវាង ២២០ និង ២៣០ ជាឧត្តមសេនីយ៍របស់ស្តេចអង្គមុន ( បានឡើងគ្រងរាជ្យ។ ព្រះអង្គបានពង្រីងឥទ្ធិពលរបស់ខ្លួនទៅលើតំបន់ជិតខាង ។

ដោយមាននាវាចម្បាំង ព្រះអង្គបានកាន់កាប់ *ក្យូ ទូ* (Kiu - tou) រួចឆ្លងកាត់សមុទ្រសៀម ( បច្ចុប្បន្ន ) ហើយព្រះអង្គបានដណ្តើមបានជាង ១០ប្រទេស ។ រដ្ឋទាំងឡាយដែលស្ថិតនៅតាមជ្រលងភ្នំ *មេណាម* និង នៅលើជ្រោយកោះ *ម៉ាឡាយូ* រហូតដល់តំបន់ *ទួន សួន* ( Touen - souen ) តំបន់ *លីគ័រ* ( Ligor) ត្រូវបានចុះចូលនឹងព្រះអង្គ ។ បន្ទាប់មក ព្រះអង្គបានច្បាំងជាមួយប្រទេស គិនលិន ( Kin lin ) *ម៉ាឡេស៊ី* ក៏ប៉ុន្តែ ព្រះអង្គ ទ្រង់ប្រឈួន រួចចាត់ចែងកូនជាទីទុកព្រះទយ័បន្តសមរភូមិប្រយុទ្ធ ។

ភ្នាក់ងារទូតខ្មែរ ប្រចាំព្រះរាជវាំងចិន នៅក្នុងកំឡុងឆ្នាំ ២២៨ ។

**៧ . ហាន់ ការ៉ង ចេង** ( ២៣០ ) ជារាជបុត្រច្បងត្រូវបានអ្នកគ្រងរាជបន្ត ធ្វើគត់ ។



www.budinst.gov.kh www.elibraryofcambodia.org

៨ . **ហ្វាន់ ចាន់** ( Fan Tchan ) រវាង ២៣០.២៤៨ នៃគ.ស ជាឧត្តមសេនីយ៍ និង ជាក្មួយរបស់អ្នកបង្កើតសន្តិវង្ស បានដណ្តើម រាជ្យព្រះអង្គ ហើយត្រូវក្មួយរបស់ព្រះអង្គឈ្មោះ ***ហ្វាន់ ចង់*** ( Fan Tchang ) ធ្វើគត់ ។

កិត្យានុភាពកម្ពុជា លាតសន្ធឹងរហូតដល់ជ្រោយនៃឈូងសមុទ្រ *បង់ហ្គាល់* (Bengale) និងមានទំនាក់ទំនងសេដ្ឋកិច្ចរហូតដល់ *ប្រទេសឥណ្ឌា* ។

ភ្នាក់ងារទូតខ្មែរមានវត្តមាននៅក្នុងរាជវាំងនៃស្តេច ***មុរុន្ឌ*** ( Murunda ) ( 244 A.D ) ភ្នាក់ងារទូតខ្មែរ នៅប្រទេសចិនក្នុងឆ្នាំ ២៤៣ នៃគ.ស ( បាននាំអ្នកសិល្បៈ និង ភោគផលរបស់ប្រទេសទៅថ្វាយ )

៩ . **ហ្វាន់ ចង់** ( FanTchang ) ប្រហែល ឆ្នាំ ២៤៨ ជាកូនពៅរបស់ ***ព្រះបាទ ហ្វាន់ ចេ ម៉ាន់*** ត្រូវបាន ***ហ្វាន់ ស៊ុំ យុន*** ធ្វើគត់ ។



www.budinst.gov.kh www.elibraryofcambodia.org

# សន្តិវង្សរបស់ ហ្វាន់ ស៊ី យុន ( F an Siun )

( រវាងពី ២៤៨ - ៣៥៧ )

១០ . **ហ្វាន់ ស៊ី យុន** ( 248 -288 A.D ) ជាឧត្តមសេនីយ៍បានឡើងគ្រងរាជ្យ។ តាមវិសាលភាពនៃដែនដីរបស់ខ្លួន *នគរភ្នំ* ជាប្រទេសមួយយ៉ាងសំខាន់ផ្នែកនយោបាយ នៅសមុទ្រប៉ែកខាងត្បូង ។ នៅក្នុងជ្រោយកោះ *ម៉ាឡាយូ* មានស្តេចប្រាំអង្គដែលសុទ្ធតែជាស្តេចចំណុះរបស់ *នគរភ្នំ* គឺនៅក្នុងតំបន់ *ទួន ស៊ួន* ។ ***ព្រះបាទ ហ្វាន់ ស៊ី យុន*** បានធ្វើទំនាក់ទំនងជាមួយនឹង ***ពី កៀន*** ( Pi Kien ) និង ក្សត្ររបស់គេ ដែលបានបញ្ជូនជាញឹកញយមកស្តេច *នគរភ្នំ* នូវភាជន៍មាសសុទ្ធ សំរាប់មនុស្សហាសិបនាក់ ។

សន្តិវង្ស ***វូ*** ( Wou ) នៃប្រទេសចិនបានស្នើមកព្រះរាជវាំងខ្មែរ ក្នុងកំឡុងឆ្នាំ ២៤៨ - ២៥០ ដើម្បីដាក់ភ្នាក់ងារទូតជាមួយ ***កាង តៃ*** (KangTai ) និង ***ជូ យីង*** (Tchou ying ) ។ ភ្នាក់ងារនេះ បានមកដល់ដែនដី *នគរភ្នំ* ចំពេលនៃការវិលត្រឡប់របស់ ***ស៊ូ វូ*** (Sou Wou ) ពីបេសកកម្ម ។ ***កាង តៃ*** បានយកពត៌មាន ផ្សេង ៗ ពីប្រទេសឥណ្ឌា ហើយបញ្ជូនមកប្រទេសចិន តាមរយៈ អ្នកដែលគេបញ្ជូនមករបស់ស្តេច ***មុរុន្ឌ*** ( Murunda ) ។ ***ហ្វាន់ ស៊ី យុន***



www.budinst.gov.kh www.elibraryofcambodia.org

១៧ . Xf .....( ជយវរ្ម័ន ? ) ( ពាក់កណ្ដាល សតវត្ស ទី ៥ ) បិតារបស់ **គុណវរ្ម័ន** ( Gunavarman ) មេដឹកនាំស្ថិតនៅតំបន់មេគង្គភាគចំណាប ហើយ ជាគ្រួសាររបស់ ***កោណ្ឌិញ្ញ*** មួយ » ។

## សន្តិវង្សជយ៉ ( Jaya ) របស់ ប៉ាន់ ប៉ាន់ ( Pan - Pan )

( រវាង ៤៧០ - ៥៤៥ )

### សោមា វង្សា

១៨ - **ជ័យវរ្ម័ន** ( Jayavarman /Chö - ye pa mo ) ហៅក្រោ Kiao tchen jou ( kaundinya ) : រវាង ២៧០ - ៥៤១ នៃគ.ស ។

ព្រហ្មញ្ញជន ទ្រង់បានមកសោយរាជ្យនៅ *នគរភ្នំ* ក្រោយពីបានស្នាក់នៅ ប្រទេស*ប៉ាន់ ប៉ាន់* ( Pan Pan ) ដែលជាប្រទេសមួយនៅក្បែរតំបន់ *លីគ័រ* ( Li g o r ) ។ ព្រះអង្គគោរពលទ្ធិព្រះពុទ្ធសាសនា នៅពេលនោះ លទ្ធិសិវៈ គ្របដណ្ដប់លើព្រះរាជាណាចក្រ *នគរភ្នំ* ។ ប្រពៃណី ទំនៀមទំលាប់ គឺការបូជាដល់ លទ្ធិសិវៈ ( អាទិទេពមហេស្វរៈ ) ដើម្បីញាណឈានដល់មហិទ្ធិឫទ្ធិដ៏អស្ចារ្យ នៅ លើភ្នំដ៏ពិសិដ្ឋដែលមានឈ្មោះថា *ម៉ូ តន* ( Mo Tan ) គឺ ៣ភ្នំ ។ ស្ដេចទាំង អស់បានទទួលនូវគុណធមិរបស់ទ្រង់ ប្រជារាស្ត្ររស់នៅស្ងប់ស្ងាត់ ព្រោះថា នៅ កន្លែងនោះ គេគោរពព្រះពោធិសត្វ ( ពុទ្ធសាសនា មហាយាន ) តាមគន្លងករុណា



www.budinst.gov.kh www.elibraryofcambodia.org

ធម៌របស់លោកេស្វរៈ ។

ព្រះរាជបុត្ររបស់ព្រះអង្គនាម *គូ ជូ លូ* ( Kieou Tcheou Lo ) បានបះបោរឡើង ( ច្បាំង ) ដណ្តើមបាន *នគរលិន យី* ដែលជាកន្លែងធ្វើសកម្ម-ភាពនយោបាយ រួចឡើងធ្វើស្តេចនៅរវាងឆ្នាំ ៤៨០ - ៤៩២ ។

ក្នុងវិសយ័ការងារទូត *ព្រះបាទជ័យវរ្ម័ន* បានទទួលព្រះសង្ឃមួយព្រះអង្គមានព្រះនាមថា *សាក្យានាគសេន* ( Çakyanagasena ) រួចគេបញ្ជូនព្រះអង្គទៅប្រទេសចិន ក្នុងរាជវង្ស *ស៊ី* ( T'si ) របស់អធិរាជ *វូ ធិ* ( Wou Ti ) ឆ្នាំ៤៨៤ ។

ភ្នាក់ងារទូតខ្មែរម្នាក់ បានទៅប្រទេសចិននៅឆ្នាំ ៥០៣ នៃគ.ស ដើម្បីថ្វាយដល់ស្ថាបនិករបស់សន្តិវង្ស *លាង* ( Leang ) នូវពុទ្ធរូបមួយអង្គធ្វើអំពីផ្កាថ្ម ។ ភ្នាក់ងារនេះ បានកោះហៅព្រះសង្ឃ ពីរអង្គ នៅឆ្នាំ ៥០៦ ព្រះនាម *មន្ទ្រសេនៈ* (Mandrasena ) និង *សង្ឃបាល* ( Sanghpāla ) ឬ *សង្ឃវរ្ម័ន* ( ៤៦០ - ៥២៤ ) ។ ព្រះសង្ឃទាំងពីរអង្គនេះមានដើមកំណើតពី *នគរភ្នំ* បានបញ្ជូនអោយទៅធ្វើការបកប្រែនូវ ព្រះគម្ពីរទាំងឡាយជាភាសាសំស្ក្រឹតទៅជាភាសាចិន ។

នៅឆ្នាំ ៥០៧ ព្រះចៅអធិរាជ *វូធិ* របស់រាជវង្ស*លាង* បានបញ្ជូន( ថ្វាយ ) ជានន្ទរសក្តិដល់ *ព្រះបាទជ័យវរ្ម័ន* ដែលជាស្តេច *នគរភ្នំ* ជា « ឧត្តមសេនីយ៍



www.budinst.gov.kh www.elibraryofcambodia.org

សន្តិភាពប៉ែកខាងត្បូង » ។

នៅឆ្នាំ ៥០៩ ព្រះសង្ឃឈ្មោះ *ពោធិភទ្រៈ* ( Bodhibhadra ) បានឆ្លងកាត់ប្រទេសកម្ពុជា ជាប្រទេសដែលកាន់ព្រះពុទ្ធសាសនា ទៅកាន់ព្រះរាជវាំង *លាង* ។ សួយសារអាករថ្មីរបស់ *នគរភ្នំ* បញ្ជូនទៅប្រទេសចិន នៅឆ្នាំ ៥១២ និង នៅឆ្នាំ ៥១៤ ជាឆ្នាំដែល *ព្រះបាទជ័យវរ្ម័ន* សុគត ។

១៩ . **រុទ្រវរ្ម័ន** ( Rudravarman / Lieouto pa - mo ( 514-545)ជាព្រះរាជបុត្រប្រសូតចេញពី មហេសីក្រៅច្បាប់ របស់ព្រះរាជា ។ ព្រះអង្គបានធ្វើគត់ប្អូនពៅរបស់ទ្រង់ ដែលជាអ្នកបន្តរាជ្យស្របច្បាប់ រួចឡើងសោយរាជ្យ ។

រាជធានី គឺ *វ្យាធបុរៈ* ( Vyadhapura ) ដែលស្ថិតនៅចំងាយពីសមុទ្រ ៥០០ លី ហើយ ជាភ្នំរបស់ស្តេច ពោលគឺ *បាភ្នំ* ( Ba Phnom ) ។ « មានទន្លេធំហូរពីខាងជើងឆៀងខាងលិច ( ទិសពាយ័ព្យ ) ទៅទិសខាងកើត ឆ្ពោះទៅរកសមុទ្រ » គឺជាទិសដៅរបស់ ទន្លេមេគង្គ តាមដៃទន្លេ *មី ថូ* ( My - tho ) ( កម្ពុជាក្រោមសព្វថ្ងៃ ) ដែលគេប្រើប្រាស់សំរាប់នាវាចរ ។

ផ្នែកភ្នាក់ងារទូត : *ព្រះបាទរុទ្រវរ្ម័ន* បានបញ្ជូនភ្នាក់ងារទូតទៅព្រះរាជវាំង *លាង* នៅឆ្នាំ ៥១៧ នៅ *ណានកាំង* ( Nankin ) ដែលដឹកនាំដោយព្រាហ្មណ៍ម្នាក់ឈ្មោះ *តង់ ប៉ាវ ឡៅ* ( Tang Pao lao ) រួច



www.budinst.gov.kh www.elibraryofcambodia.org

បញ្ជូនភ្នាក់ងារទូត ថ្មី១ទៀត នៅឆ្នាំ ៥១៩ , ៥២០ , ៥៣០ , ៥៣៥ , ៥៣៩ នៃគ.ស ។

# រាជាណាចក្រ នគរភ្នំ

អត្ថបទបកប្រែពីសៀវភៅចិនបុរាណ បានបញ្ជាក់ថា ពីសតវត្សទី៣ ដល់សតវត្សទី ៦ ឥទ្ធិពលរបស់ *នគរភ្នំ* មិនមែនស្ថិតនៅចង្អៀតត្រឹមថ្នាក់កណ្តាល និង ថ្នាក្រោមទន្លេមេគង្គនោះទេ គឺបានលាតសន្ធឹងជាច្រើនសម័យកាល រហូតដល់ទន្លេ *តេណាស៊ើរីម* ( Ténasserim ) នៃឈូងសមុទ្រ *បង់ហ្គាល់* ( Bengale ) ។ តាមបណ្តោយខេត្ត ដែលជាប់នឹងសមុទ្ររបស់ប្រទេសដែលស្រោចស្រប់ទៅដោយសមុទ្រកម្ពុជានេះ *នគរភ្នំ* បានទាក់ទងជាមួយនឹងប្រទេសជាច្រើននៅតាមជ្រោយកោះ *ម៉ាឡាយូ* « *សិង្ហបូរី - លិនគោរសៃយៈ ( Xaiya )* » ដែលមានស្តេចជាច្រើនទទួលស្គាល់អធិរាជភាពរបស់ *នគរភ្នំ* ។ នៅក្រៅប្រទេស អតីតព្រះរាជាណាចក្រខ្មែរ បានធ្វើទំនាក់ទំនងផ្នែកសេដ្ឋកិច្ច និង ការទូតជាមួយនឹងប្រទេសចិនមួយផ្នែកទៀត ជាមួយនឹងប្រទេសឥណ្ឌា ។



www.budinst.gov.kh www.elibraryofcambodia.org

# ចម្បាំងគយុទ្ធរវាង នគរភ្នំ និង ចេន ឡា

ការសោយព្រះទិវង្គតរបស់ ***ព្រះបាទរុទ្រវរ្ម័ន*** បានបញ្ជាក់ឱ្យដឹងថា ជាការបញ្ចប់នៃសន្តិវង្ស ធំៗរបស់ *នគរភ្នំ* ដែលធ្លាប់មានកេរ្តិ៍ឈ្មោះល្បីល្បាញបំផុត អស់កាលជាច្រើនសតវត្សមកហើយ នៅលើជ្រោយឥណ្ឌូចិននេះ ។

ភាពហ៊ឹកវរ បានផ្ទុះឡើងពេញផ្ទៃប្រទេស គឺរដ្ឋសមន្តរាជខ្លះៗ ក្នុងនោះរដ្ឋដែលនៅជ្រលងភ្នំ *មេណាម* តាម*ទន្លេមេគង្គ* បានប្រកាសឯករាជ្យភាពរបស់ខ្លួន ។ ស្តេចដែលសកម្មជាងគេក្នុងចំណោមស្តេចទាំងនោះ គឺស្តេចរបស់ប្រទេស *ចេន ឡា* ដែលបានកាន់កាប់ភាគកណ្តាលនៃ*ទន្លេធំ* ( មេគង្គ ) និង *ល្បាក់ខោន* ។ ការតស៊ូស៊ីសាច់ហុតឈាមមានរយៈកាលយូរអង្វែង *ចេន ឡា* តស៊ូអស់រយៈកាល ៧៥ ឆ្នាំ ដើម្បីទទួលបានអធិរាជភាពលើ *នគរភ្នំ* ។

## អវសានរបស់ នគរភ្នំ

ពេលបាត់បង់*ចេន ឡា* *នគរភ្នំ* បានបន្តជីវិតរស់នៅរហូតដល់ឆ្នាំ ៦២៧ ។ នៅក្នុងសម័យនោះ មានស្តេច ៤អង្គចង់ឡើងសោយរាជ្យបន្តខ្សែ***វរ្ម័ន*** ( **ប៉ាំ ម៉ុ**)



www.budinst.gov.kh www.elibraryofcambodia.org

២០ . Xg a .... ភាពហ៊ឹករវេផ្ទេកនយោបាយ នៅឆ្នាំ ៥៤៥ នៃគ.ស

២១ . Xg b.....*ចេន ឡា* ប្រកាសឯករាជ្យ ។ នៅពេលនេះ *នគរភ្នំ* រក្សា បាននូវខេត្តទាំងឡាយជាប់នឹងសមុទ្រខាងលិច និង ខេត្តទាំងឡាយនៅ *ណាសាក់* ។

២២ . Xg c.....*នគរភ្នំ* បានបាត់បង់តំបន់ *ហ៊ីងធំ* និង ការទាក់ទងទៅនឹង *មេណាម* ។

**ត្វាធមុះ** ( Tö mo ) រាជធានីបានត្រូវគេដណ្តើមយក ។ ចំណែកឯ ខេត្តនៅវាលទំនាប*ទន្លេមេគង្គ* បានទទួលស្គាល់អធិរាជភាពរបស់ *ចេន ឡា* ។

**ចេ ទូ** (Tche tou) ( សៀមក្រោម ) ជាក្រុមមួយចេញពី *នគរភ្នំ* បានទៅជារដ្ឋឯករាជ្យ ហើយទទួលបេសកកម្មរបស់ចិន នៅឆ្នាំ ៦០៧ ។ ក៏ដូចគ្នា នឹង **ត្សាន់ប៉ាន់** ( Tsan pan ) ដែរ បានបញ្ជូនភ្នាក់ងារទូតម្នាក់ទៅប្រទេសចិន និង **តៅមីង** (Tao ming ) នៅឆ្នាំ ៦២៥ ។

២៣ . Xg d..... មេដឹកនាំ *នគរភ្នំ* ត្រូវតែរត់ភៀសខ្លួនមកតំបន់ប៉ែកខាង ក្រោម *ណាសាក់* ( Na Fou Na , ជា Navanagara ទេដឹង ? )

ភ្នាក់ងារទូតប្រចាំប្រទេសចិន នៅឆ្នាំ ៦១៦ ប្រហែល ៦៦២ និងលើក្រោយ បង្អស់នៅឆ្នាំ ៦២៧ ដើម្បីសុំជំនួយទប់ទល់នឹង*ចេន ឡា* ដែលជាអ្នកមានជោគជ័យ។



www.budinst.gov.kh www.elibraryofcambodia.org

# សន្តិវង្សរបស់ ចេន ឡា

**ចេន ឡា** តាំងនៅក្បែរ *ល្បាក់ខោន* បានផ្តាច់ខ្លួនចេញពីមហាអំណាចនៅឆ្នាំ ៥៤៥ រួចបានពង្រីកខ្លួនឯង បន្តិចម្តងៗ នឹងបានរីកចំរើន នៅផ្ទៃចិន លើផ្នែកនយោបាយ ដែល *នគរភ្នំ* បានអនុវត្ត ។

## រជ្ជកាលស្រេស្ឋ ( Creshtha )

( ពាក់កណ្តាលសតវត្ស ទី៦ , រវាង ៥៤៥ - ៥៦៥ )

**សង្ខេប ចង្ស :**

១ . **ស្រេស្ឋវរ្ម័ន** ជាបុត្ររបស់ក្សត្រ ***ស្រុតវរ្ម័ន*** ( Çrutavarman) បានប្រសូតនៅ*ជយាទិត្យបុរៈ* (Jayadityapura ។ វង្សត្រកូលរបស់ព្រះអង្គមានសារលោហិតនឹង ***មហាឫសិកម្ពុ*** និង ***អប្សរមេរា*** ( ទេវកថាផ្នែកព្រះអាទិត្យ )។

នៅឆ្នាំ ៥៤៥ ***ស្រេស្ឋ*** ស្តេចចេន ឡា )នៅតែឯកឯង។ ព្រះអង្គទទួលបន្ទុកកាន់កាប់ដែនដីកម្ពុជា និងរំដោះប្រជារាស្ត្រ នៅជួរភ្នំរបស់កុលសម្ព័ន្ធ ពី *នគរភ្នំ* ។

ព្រះរាជធានីគឺ *ស្រេស្ឋបុរៈ* ដែលតាំងនៅរមណីយដ្ឋាន*បាដោម* ( Bâ dom) ខាងកើតស្ទឹងត្រែងជាកន្លែងដែលត្រូវបានគេស្រង់នូវការវិនាស នាជំនាន់ដើម ។

ភ្នំជាទីសក្ការៈ « នេះគឺនៅប្រទេសកម្ពុជា » គឺភ្នំ *ភទ្រេស្វរៈ*



www.budinst.gov.kh www.elibraryofcambodia.org

( Bhadrecvara ឬ លិង្គបពិត ( ពាក្យលាវ : ភូខាវ ) ចំងាយ ១៥០ គ.ម ត្រង់ ពី ជាដោម ។

ភ្នាក់ងារទូតនៅប្រទេសចិន នៅឆ្នាំ ៥៥៧ ។

## សន្តិវង្ស ភវៈ ( Bhava )

( ប្រហែល ៥៦៥ . ៧០៥ )

### សោមាវង្ស

២ . **ភវៈវរ្ម័ន ទី១** ជារាជបុត្ររបស់ ***វីរៈវរ្ម័ន*** ( Viravarman ) និង ជាចៅរបស់ ***រុទ្រវរ្ម័ន*** ( Rudravarman )(នៃនគរភ្នំ) នៅពាក់ កណ្តាល ទី ១/៣ ទៅ ១/៤ នៃសតវត្ស ទី៦ ជាស្តេចដ៏ធំជាគេបង្អស់ ( *សារភូមឬអធិរាជ* )។ រាជត្រកូលនេះកើតចេញពីត្រកូល ***កោណ្ឌិញ្ញ*** *និង* ***នាគី សោម*** ( ទេវកថា ផ្នែកព្រះចន្ទ្រ ) ។

**ភវៈវរ្ម័ន ទី១** កាន់កាប់ ចេន ឡា ដែលបង្កើតឡើងដោយបុព្វបុរស របស់ព្រះអង្គ និង ដណ្តើមរាជ្យអំណាចដោយសារឫទ្ធានុភាពរបស់ព្រះអង្គផ្ទាល់ ។ បន្ទាប់មក ព្រះអង្គ បានបង្កើតជាលំដាប់កំលាំងរបស់ *ចេន ឡា* ជាជំនួយនិយ *នគរភ្នំ* ដែលត្រូវបានកាត់បន្ថយ រួចក៏បានកាន់កាប់តំបន់ *បឹងធំ* ( ទន្លេសាប ) រហូត



www.budinst.gov.kh www.elibraryofcambodia.org

មកចលរ៉ែនឹង *ពាត់ដឹបង* ។ ប៉ែកខាងត្បូង ព្រះអង្គកាន់កាប់ *ខេត្ត ត្រាំង* ( Treang ) និង តំបន់ដែល ប្រហែលជា *ព្រៃនគរ* ( Saigon ) រាជធានី *ភវៈបុរៈ* ។

ភ្នាក់ងារទូតបានផ្ញើ ទៅនៅប្រទេសចិននៅឆ្នាំ ៥៧២ ។

៣ . **មហេន្ទ្រវរ្ម័ន** ( Mahendravarman ឬ **ចិត្រសេនៈ**Tche drasseuna ) ចុងសតវត្ស ទី៦ ប្រហែលឆ្នាំ ៦១០ ជាព្រះអនុជដ៏ក្មេងរបស់ ទ្រង់ « *រាជសិរីនៅលើភពដែនដី ជាអ្នកកំទេចកំលាំងសត្រូវឈ្លានពានឥទ្ធិពល បានបង្កើតហេមពល និង មានការកំណាត់ព្រះរាជកិត្តិយសដូចព្រះអាទិត្យ និងមានការត្រួតត្រាដូចព្រះឥន្ទ្រ* ។ » ព្រះអង្គនេះហើយ ដែលពីមុនមានព្រះនាមជា ***ស្រីចិត្រសេនៈ*** ( Çricitrasena ) បានទទួលព្រះនាមជា ***ស្រីមហេន្ទ្រវរ្ម័ន*** ( Çrimahendravarman ) ចាប់តាំងពីការឡើងគ្រងរាជ្យរបស់ព្រះអង្គ ។

ព្រះអង្គ បានដណ្ដើមយកប្រទេសរបស់សត្រូវ នៅតាមដងទន្លេ *សេមូន* ( Se mun , នៅខាងជើងតំបន់ *ដងរែក* ) ។ ប៉ែកខាងត្បូង ព្រះអង្គច្បាំងជាមួយស្ដេច *នគរភ្នំ* ក្នុងរយៈពេលខ្លីដណ្ដើមកាន់កាប់ទីក្រុងសត្រូវ *វ្យាធបុរៈ* ( Vyādhapura ) ។ បច្ចុប្បន្ន នៅ *បាភ្នំ* គឺជាកន្លែងដែលពួកសត្រូវគោរពបូជាដល់ព្រះអាទិទេព « *ព្រះអង្គបាន កសាងនៅលើភ្នំនេះនូវ លិង្គ* របស់ *គិរិសៈ* (Giriça ) *ដែលទុកជានិមិត្តរូបនៃជ័យជំនះ* » ស្ដេច *នគរភ្នំ* ត្រូវគេចខ្លួនទៅខាងត្បូង



www.budinst.gov.kh www.elibraryofcambodia.org

គឺក្រុង *ណា ហ្វូ ណា* ។

រាជធានី គឺ *សត្ថបុរៈ* ( សំបូរ . តាមជងទន្លេមេគង្គ )

ភ្ជាក់ងារទូតទៅប្រទេសចិននៅឆ្នាំ ៥៨៨

**៤ . ឥសានវរ្ម័ន ទី១ ( យី ចូ ណា** Yichônâ រវាង ៦១០-៦៣៥ )

ទ្រង់ជាព្រះរាជបុត្ររបស់ព្រះអង្គ ។ « *ព្រះរាជាក្សត្រិយ៍**ឥសានវរ្ម័ន** ទ្រង់ធ្វើអនុក្ខលភាគសេសសល់របស់ នគរភ្នំ និង កាន់កាប់ដែនដី* » ។ ព្រះអង្គបានធ្វើអធិរាជលើស្តេចទាំង ៣ ដែលមានរាជធានី ៣ ។ « *ព្រះរាជាណាចក្រ មានរាជរដ្ឋាភិបាល ចំនួន ៣០ គឺ ក្រុងច័ន្ទបូរណ៍* Chanthabaur *ជាកន្លែងដែលព្រះរាជាប្រមានបុត្រី (ព្រះអង្គម្ចាស់ក្សត្រិយ* ***សាវ៉ានី*** ( Çarvani ) *ដើម្បីរៀបអភិសេកជាមួយនឹងក្សត្រចាម* ***ជគណ ធម៌*** (Jagadadharma ) ។

រាជធានី ឥសានះបុរៈ ( សំបូរ . នៅស្ទឹងសែន )

ភ្ជាក់ងារទូតទៅប្រទេសចិន នៅឆ្នាំ ៦១៦ ចុងរាជ្យស្តេច***ស៊ូអេ*** ( Souei ) រួចត្រូវរំលឹកឡើងវិញ ៤ដង ក្នុងរជ្ជកាល ***តាំង*** ( Tang ) ក្នុងចន្លោះឆ្នាំ ៦២៧ . ៦៥៨ ។

ស្តម្ភ ចារឹក :លេខ ៦១៦ , ៦២៤ , ៦២៦ , ៦២៧



www.budinst.gov.kh www.elibraryofcambodia.org

៥ . **ភវវរ្ម័ន ទី២** រវាងឆ្នាំ ៦៣៩ . ៦៥០ ( ស្តម្ភ លេខ ៦៣៩ ) ។

៦ . **ជយវរ្ម័ន ទី១** ( ពាក់កណ្ដាល ទី២ នៃសតវត្ស ទី៧ , ស្តម្ភ លេខ ៦៥៧ ,៦៦៤ , ៦៦៥ , ៦៦៧ ) ។

៧ . **រាជេន្ទ្រវរ្ម័ន ទី១** ( ចុងបញ្ចប់សតវត្សទី៧ ប្រហែល ៧០៦ , ស្តម្ភលេខ ៦៨៧ ) ។

# ការបាក់បែករបស់ចេនឡា

( ៧០៦ . ប្រហែល ៧៨០ )

## ចេន ឡាដីគោក និង ចេន ឡាដីទឹក

នៅក្រោយឆ្នាំរបស់ *ចេន ឡុង* Chen long ឆ្នាំ ៧០៥ . ៧០៦ ស្តេចនៃនគរសមន្តរាជទាំងឡាយ បានលោស់ចំណងរបស់ *ចេន ឡា* រួចមក មហា. អំណាចខ្មែរ ត្រូវបែកបាក់ជាពីរ ។ នៅសតវត្ស ទី៨ *ចេន ឡា* ដីគោក ( វេន តាន/ Wen Tan ) ស្ថិតនៅខាងជើងភ្នំដងរែក រីឯ *ចេន ឡា* ដីទឹក ស្ថិតនៅក្នុងអាងនៃ ទន្លេមេគង្គ ។



www.budinst.gov.kh www.elibraryofcambodia.org

**ចេន ឡាដីគោក** ( WenTan ) អាងរបស់ដងទន្លេ *ជី* ( *ណាំ សិ* Nam si ) ជាដៃខាងឆ្វេងនៃទន្លេ *ស៊ូល* ( Se mun ) ត្រូវបានរួមបញ្ចូលក្នុងភូមិភាគនេះដែរ ។ តំបន់នេះ ត្រូវបានគេស្គាល់ឈ្មោះថា *វ៉េ តាន* បន្ទាប់មកឈ្មោះ *ប៉ូ លាវ* ( Po leou ) ។

ភ្នាក់ងារទូតនៅប្រទេសចិន នៅឆ្នាំ ៧១៧ , ៧៣៣ ? , ៧៩៩ ។

ភ្នាក់ងារទូតទាំងនោះ ស្ថិតនៅ *គាវ ចេ* ( Kiao Tche តាមភស្តុតាងដែលយើងបានឃើញនៅ *ខ្យា តាន* ( Kia Tan ) ។

វត្តមានរបស់***ជ័យវរ្ម័ន ទី២*** ក្នុងការគ្រងរាជ្យនៅ *នគរភ្នំ* ( ចុងសតវត្ស-ទី៨ ) បានធ្វើឱ្យប្រទេសទាំងអស់ ដែលស្ថិតនៅក្នុងអាងរបស់មេគង្គស្ថិតក្រោមការត្រួតត្រារបស់ខ្មែរសារជាថ្មីទៀត ។

**ចេន ឡាដីទឹក** វាលទំនាបនៃផ្នែកទំនាបរបស់ *មេគង្គ* នៅចន្លោះភ្នំដងរែក ប៉ែកខាងជើង និង សមុទ្រប៉ែកខាងត្បូង បង្កើតបានជា *ចេន ឡាដីទឹក* ។



www.budinst.gov.kh www.elibraryofcambodia.org

# សន្តិវង្សរបស់ បុស្ករៈ ( Pushkara )

( រវាង ៧០៦ - ៧៧០ )

## សោមា វង្សា

៨ - **បុស្ករាក្សា** ( Pushkākshā ) ( ១/៤ ទី១ នៃសតវត្ស ទី៨ ) ព្រះអង្គជាម្ចាស់របស់ ***អនិន្ទិតៈបុរៈ*** ( Aninditapura ) ទ្រង់បានលួកលាន់អំណាច និង ឡើងធ្វើជាស្តេចគ្រប់គ្រង *សម្ភុបុរៈ* ដែលជាកន្លែងដែលព្រះអង្គបានបង្កើតព្រះរាជសន្តិវង្ស ( ស្តម្ភ លេខ ៧១៦ ) ។

៩ - **បាលាទិត្យា** ( Bāladityā , ពាក់កណ្តាលសតវត្ស ទី៨ ) ជាក្សត្ររបស់ *អនិន្ទិតៈបុរៈ* ដែលបានប្រសូតឡើងក្នុងវង្ស ***សោមា*** និង ***កៅណ្ឌិញ្ញ*** ( Kaundinya )

ភ្នាក់ងារទូតរបស់ *ចេន ឡាងីគោក* នៅឆ្នាំ ៧៥០ ក្នុងរជ្ជកាល ព្រះមហាក្សត្រចិននៃរាជវង្ស ***តង់*** ( Tang )

ក្នុងសម័យនេះព្រះរាជាណាចក្រមួយនៅប៉ែកខាងត្បូងគឺប្រទេស*ជ្វា* ជាម្ចាស់នៅ *អាំងស៊ុឡាំង* ( Insulinde ) បានពង្រីកឥទ្ធិពលនយោបាយរបស់ខ្លួន នៅភាគខាងជើងនៃជ្រោយ *កោះម៉ាឡាយូ* គឺជាកន្លែងដែលគេបានទទួលឥទ្ធិពល


www.budinst.gov.kh www.elibraryofcambodia.org

នយោបាយរបស់ស្ដេចនៅក្រុង *ស្រីវិជយ័* (Çrivijaya ) ។ អធិរាជនៃប្រទេស *ជ្វា* (Java ) បានកាន់កាប់ *លិគ័រ* ( Ligor ) រួចគ្រប់ សង្កត់ភូមិភាគពាក់សមុទ្រ *បាន ដុង* ( Ban don ) ដោយរួមបញ្ចូលទៅនឹងរដ្ឋអាំងឡាយរបស់គេ ( សៃយ៉ា Xaiya ស្លឹករឹត ៧៧៥ ) ដែលបានទទួលឥទ្ធិពលវប្បធម៌ ប្រទេសកម្ពុជា ។ ការបះបោរតស៊ូមួយ បានកើតមានឡើងរវាង ***ពួកម៉ាឡាយូ*** និង ***ខ្មែរ*** ចំពោះរឿងអនុត្តរភាពនយោបាយ ។

## រាជ្យ Xh

១០ - Xh... ៣/៤ នៃ សតវត្ស ទី៨ ប្រហែល ៧៨០ ក្សត្រមួយព្រះអង្គនៅក្មេងហើយគាប់បេល់ការណ៍របស់ *ឥន្ទ្របុរៈ* ប្រហែលត្រូវគេធ្វើគត់ នៅ*ឥន្ទ្របុរៈ* ក្នុងពេលធ្វើសង្គ្រាមដ៏ខ្លីមួយរបស់ស្ដេចអធិរាជនៃប្រទេស ***ជ្វា*** Java ឬ ***ហ្សាបាក*** ( Zabag ) ស្ថិតអល់នឹងកម្ពុជា ប្រមាណឆ្នាំ ៧៨០ ។

ភ្នាក់ងារទូតនៅប្រទេសចិន នាឆ្នាំប្រមាណ ៧៧៨ របស់ក្សត្រ ***ប៉ូ មិ*** ( *Po mi)* ដែលទៅជាមួយភរិយារបស់ព្រះអង្គ ។ រួចហើយ ពោធិ៍ថ្វាយដំរី ១១ ក្បាលដោយគ្រឿង លង្ការ ដល់អធិរាជ ***ថៃ សុង*** ( Tai song ) ។ »



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ឯកសារយោងស្តីអំពីបុរេប្រវត្តិសាស្ត្រនៃ កម្ពុជា


## ១. ប្រទេសកម្ពុជាបច្ចុប្បន្ន

ROSLIER , B-PH . 1966 , Découvertes archéologiques récentes au Cambodge,Kambuja , No. 16

OURER .R . 1977 . Aperçu sur la préhistoire du Cambodge , in Le paysan khmer . Exposition au Musee de Saint-Lambert-Sur-Loire,Avril-octobre.
1977 Laang Spean and the prehistory of Cambodia, in Modern quaterly researeh in Southeast-Asia, 3.
1978.préhistoire du Cambodge, Archeologia, 233

ARBONNEL.J-B 1972, Le quaternaire cambodgien. Structure and stratigraphie. ORSTOM , 60

AURIN , E . Le paléolitique du Cambodge oriental, Asian perspectives , IX
1963. Premiers élémemts sur la présence des galets aménagés et les vieux galets paléolithiques au Cambodge. Compte-Rendu de la Francaise .

ANSUY,H. 1923, Résultats de nouvelles recherches effectuées sur le gisement préhistorique de Samrong Sen, Mémoire de Société Géologique de l'Indochine, X .

ARTAILHAC,E. 1890, Les bronzes préhistoriques du Cambodge et les recherches de Mr.James Ludovic. Anthropologie.

CHAUVET. 1924. Objets préhistoriques trouves a Samrong Sen. Bullrtin d'Archéologie, Paris .

LEVY,P. 1943, Recherches préhistoriques dans la region de Mlu-prei. PEFEO, XXX . Hanoi.

CORRE,A. 1880. Sur les instuments de pierre au Cambodge, Bulletin et Memoires de la societe d'Anthropologie de Paris.

TRANET,M. 1992. A propos d'un bronze représentant un homme assis sur son éléphant Southeast Asian Archeology 1990, Hull University.
1995, La préhistoire du Cambodge . Bibliotheque Nationale de Phnom Penh ( en cambodgien ) .
1996, Récentes decouvertes archéologiques préhistoriques au Cambodge : des vestiges prehistoriques à Angkor Borei , Apsarama,3,15 janvier .
- Origine des disques auriculaires des Khmers ( en cambodgien ) Apsarama, 3,15 janvier

ETELLIER. 1895. Nouvelles d'objets préhistoriques du Cambodge, Bulletin de la société historique et d'Archeologie de l'orne .

ANSUY,H. 1902,Stations préhistoriques de Samrong Sen et Long Prao ( Cambodge ), Bulletin du service de Géologie de l'Indochine, Hors Serie .
1923. Résultats de nouvelles recherches effectuées sur le gisement préhistorique de Samrong Sen , Mémoire de la Société Géologique, X , I , Hanoi.

OULET, J.-B.1879,L'âge de la pierre polie et du bronze au Cambodge après les découvertes de Mr. Jean Moura, Toulouse .

## ២. ប្រទេសវៀតណាមខាងត្បូង ឬ កម្ពុជាក្រោម

ANSE ,B. 1961,Somes notes on the Sa Huynh , Asian Perspectives, III




www.budinst.gov.kh www.elibraryofcambodia.org

SAURIN, E. 1973,Le champ de jarres de Hang Gon, pres de Xuan-Loc ( Sud-Vietnam ), BEFEO, LX, Paris .

HA VAN TAN 1980, Recherches préhistoriques et proto-historiques au Vietnam, BIEH, VI.

NGUYEN PHUC LONG 1975, Les nouvelles recherches archéologiques au Vietnam,AA, XXXI,P

PARMENTIER,H.1928, Vestiges mégalithiques à Xuan - Loc , BEFEO,2e. semestre.

FROMAGET, J.1938, Les récentes découvertes archéologiques anthropologiques dans les formations de la Chaine Annamitique. congrès de la préhistoire Far East, Singapour.

GENET-VARCIN. 1958. Les restes osseux des Cants-Rues, ( Sud-Vietnam ), BEFEO XLIX, Paris

CHIN YOU DI, 1967, Prehistorics cultures Bangkok.
1969, L'homme préhistorique en Thailande, Bangkok .
1975, Ban Chieng prehistoric culture, Bangkok.

TRANET. 1991, Ban prasat : un site mon-khmer protohistorique à Nagara Rajasima dans l'actuelle Thailande. Khméritude, 1. Paris.
1996, Note sur une urne funéraire récemment découverte à Ban Chieng et son importance symbolique dans la culture Khmère, Apsarama 3,15 janvier.
- Quelques précisions sur l'urne funéraire récemment découverte a Ban Chieng . Apsarama, 7,15 janvier .

WATSON and LOOFS.1967, The Thai-British archeological expedition. A preliminary reort report on the work of thefirst sea.son. Siam Society journal, part2, July, Bangkok.

BRONSON,BENNET and NAPAPINTU. 1988, Don Noi : A new flaked tool industy of the Middle Holocene in Western Thailand, in The Stone and Metal ages in Thailand, Bangkok.

BRONSON and BENNET 1979, The late prehistory ans Early History of Central Thailand with special reference to Chansen, Early South East Asia,Oxford University Press

CHAROENWONGSA, BRONSON and BENNET ,1988 Introduction chronology in Thailand,Bangkok

SOLHEIM, II and AYRES 1979, The late prehistoric and early historic pottery of the Khorat plateau, with special reference of phimai, Early Southeast Asia, Oxford University press.

SORENSEN,P. 1967, Archaeological excavations in Thailand, vol. II . Ban Kao. Copen hagen.
1985, La prehistoire de la Thailande in Encyclopaedia Universalis Le Grand Atlas de l'archeologie.

WHITE,J. 1982, Discovery of a last bronze age : Ban Chieng. philadelphia University of pennsylvania .

KRAIRIKSH, P. 1973 , Provisional classification of painted pottery from Ban Chieng, Artibus Asiae XXXV,1/2 .
1990-1992 . Histoire de l'art et de l'archéologie de la Thailande, Bangkok ( en thai

CHAKRABO CHITRABONGS. 1985, Earthware and glazed ceramic ware in the social and econo



www.budinst.gov.kh www.elibraryofcambodia.org

developpment of Siam, Fine Art Depertment, Bangkok.
Art treasures of Thailand, Exhibition Tokyo National Museum, August 25-oct. 4, 1987.

COLANI,M.1933, Champs de jarres monolithiques et des pierres funéraires du Tran-ninh ( Haut-Laos ), PEFEO,XXXIII, Hanoi.
1935-1936, Megalithes du Haut-Laos, PEFEO, XXI-XXVI, Paris.

MANSUY,H.1920, Contribution à l'étude de la préhistoire de l'Indochine. L'industie de la pierre et du bronze dans la région de Luang Prabang ( Haut-Laos ),Bull. Serv. Geol. de l'Indochine , VII,1.

### III. ឯកសារយោងទូទៅ នៃប្រទេសយួន ឬ វៀតណាមខាងជើង

MANSUY,H.1919-1920, Contribution à l' étude de la préhistoire de l'Indochine, III , Mémoire du Service de Géologie l'Indochine, VI ,1.

MANSUY,H.1898, Préhistoire et proto-histoire, in PAVIE, Mission Pavie en Indochine ( 1879-1895 ), paris.
1924, Contribution à l'étude de la préhistoire de l'Indochine,IV. Stations préhistoriques dans les cavernes de massif de Bac Son (Tonkin ) ,Mémoire du Service de Geologie de l'Indochine, XI,2 .
1925, La caverne sepulcrale néolithique de Hamrong, près de Thanh Hoa, Memoire du service de Géologie de l'Indochine, Hanoi.

COLANI,M. 1927, L'âge de la pierre dans la province de Hoa Binh ( Tonkin ), Memoire du Service de Géologie de l'Indochine, XIV, 1, Hanoi.
1931, Recherches sur le préhistorique indochinois, BEFEO . XXX, Hanoi.
1932, Divers modes de sépultures néolithiques et proto-historiques en Indochine, Praehistorica Asiae Orientalis, Hanoi .
1940, Emploi de la pierre en des temps recoulés, Bull. des vieux Amis de Hue, Hanoi.

JANSE,O. 1946 .Mission archéologique en Indochine, 3e. Partie, AA, X , 1 .

### IV. ឯកសារយោងស្ដីអំពី នគរភ្នំ ឬ ហ្វូ - ណន , ចេន-ឡា និង ចម្ប៉ា

BRIGGS,L.-P, 1951. The ancien Khmer Empire, Transactions of the American philosophical Society, 41 .

PELLIOT, P. 1904, Deux itinéraires de Chine en Inde à la d fin du VIII e. s. ,BEFEO, IV .

FINOT,L. 1969, L'inscription dite " de Vo- Canh " , BEFEO, LV .
1903, Le Fou-nan, BEFEO.
1925, Quelques textes chinois concernant l'Indochine hindouisés, EA, T. II .
1904, Le Fou-nan et les théories de Monsieur Aymonier, BEFEO, IV .

AYMONIER, E. 1903, Nouvelles observations sur le Fou-nan, JA .
1903, La Fou-nan, JA .

BOISSELIER, J. 1966. Manuel d'Archéologie d'Exteme-Orient Le Cambodge, Paris.

COEDES, G. 1947, Fouilles en Cochinchine : le site de Go Oc Eo, Ancien port du Fou-nan, A rtibus Asiae X, 3 .

CHRISTIE, A-H.1979,Lin-I,Fou-nan, Java, Early South-East Asiae ,Oxford.



www.budinst.gov.kh www.elibraryofcambodia.org

LEVY,P. 1986, L'étymologie de Fan, le titre donné par les Chinois aux souverains du Fou-nan et du Champa, JA, CCLXXIV.

COEDES,G. 1961, Nouvelles inscriptions de Si Thep . Inscriptions du Cambodge VII ,Bangkok.
1943-1946. Quelques précisions sur la fin du Fou-nan, EFEO, TXLIII, Hanoi.
1931, Deux inscriptions sanskrites du Fou-nan, BEFEO, XXXI .
1936, A propos du Tchen-la d'Eau : trois inscriptions de Cochinchine, BEFEO, Hanoi.

LECLERE, A.1914. Histoire du Cambodge depuis le premier siècle de notre ère, Paris .

ISHIZAWA,Y. 1993, Etude critique sur le Zhenla Zhuan du Sui Shu, avec commemtaire et traduction française.

MASPERO,H.1904:L'empire khmer , Phnom-Penh.

NOR NA PAKNAM,1976, Art of Funan and Chenla, Muang Boran Journal 3,1, October-december, Bangkok .

GROSLIER,B.-PH.1973, Pour une géographie historique du Cambodge, Les cahiers d'Outre-Mer, 104, 53-56 .

JACQUES,C. 1989, The Khmers in Thailand : what the inscriptions inform us, SPAFA , X , 1 .

LEUBA, J. 1923. Un royaume disparu : les Chams et leur art, Paris.

V. ឯកសារយោង ស្តីអំពីភូមិសាស្ត្រ , សិល្បៈ , វប្បធម៌ ខ្មែរបុរាណ

PARMEMTIER,H.1916, Cartes de l'empire khmer, d'apres la situation des inscriptions datees, BEFEO, XVI , 3 .

MASPERO,H. 1918, " La frontière de l'Annam et du Cambodge au VIIe. s., BEFO, XVIII, 3 .

MASPERO, G .1904. L' empire Khmer. Histoire et Document.

AYMONIER,E. 1900-1904, Le Cambodge actuel. 4 volumes.

COEDES, G. 1948,Les Etats hindouisés d'Indochine et d'Indonésie. Toulouse.
1944, Histoire ancienne des Etats d'Extrême-Orient, Hanoi.
1962, Les peuples de la Péninsule indochinoise, Paris .

DUPONT,P. 1959, L'archéologie mone de Dvaravati, BEFEO.
1935, Art de Dvaravati et art khmer. Les Bouddhas debout du Bayon, AA, IX ,3.
1951, Les premières images brahmaniques de l'Indochine, BSEI, XXVI , 2.
1949, Tchen-la et Panduranga, BSEI , XXIV , Saigon.
1955, La statuaire préangkorienne, Artibus Asiae, XV, Ascona.
1952, Les linteaux khmers du VIIe. s. ,Artibus Asiae, XV, 1/2.

SRISADARA et VALLIBHOTAMA. 1976, Some forgotten sites in Udorn and Nongkai, Muang Boran journal, vol. II, 4 , July-september, Bangkok.

MOURA.J. 1982- 1983, Le royaume du Cambodge, Paris.

KENNEDY, V. 1978, Langkasuka and the early history of Pattini,in Muang Boran Journal, vol. 5,2. December 1978- January 1979.



www.budinst.gov.kh www.elibraryofcambodia.org

MALLERET, L. 1960, L'archéologie du Delta du Mekong, Tome I ,II ,III, et IV, PEFEO, Paris.
1958, Ouvrages circulaires en terre dans l'Indochine méridionale, BEFEO, XLIX .
1959, L'exploration archéologique et les fouilles d'Oc-Eo, Paris, 2 volumes.

BHATTACHARYA,K. 1961. Les religions brahmaniques dans l'ancien Cambodge d'après l'épigraphie et l'iconographie, PEFEO, XLIV , Paris .
1958, An unuspublished Ganesa Image from I Cambodia, Artibus Asiae, XXI, 3/4.

DE LANJONQUIERE,L.1912, Essai d'inventaire Archeologique de Siam.

VI. ឯកសារយោង ស្តីអំពីការបាត់បង់ដែនដីកម្ពុជាក្រោម

AUBARET,G. 1863, Histoire et desciption de la Basse-Cochinchine.

MALLERET,L. 1948, La minorité cambodgienne de Cochinchine, Bulletin de la Societe des Etudes Indochinoises.

BARAULT(capt)1927, Les Cambodgiens de Cochinchine. Revue Indochinoise. 14, 15 et 16.

NEPOTE,J. 1982, Combien sont les Khmers Krom ? in Suksa Khmer, 5.

BOUDET,P. 1942, Le conquête de la Cochinchine par les NGUYEN et le rôle des emigrés chinois, Bulletin de l'Ecole francaise d'Extreme-Orient, XLII.

RIEUNER. 1861, Aperçu de la Basse-Cochinchine, Revue Maritime et Coloniale , 1.

VII. ឯកសារយោង ស្តីអំពីប្រភពដើម នៃជនជាតិយួន ឬ វៀតណាម

AUROUSSEAU,L.1923. La première conquête des pays annamites, BEFEO, XXIII.
1923, Notes sur les origines du peuple annamite, BEFEO, XXIII .
